**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ក្របខណ្ឌគតិយុត្តសម្រាប់ការពារម៉ាកសម្គាល់ ភូមិសាស្ត្រទំនិញ ក្នុងបរិបទជាតិ និងអន្តរជាតិ

សរសេរសារណាពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២០ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **ទេង គួងហេង**

**ម៉ិច ភាតា**

សាស្ត្រាចារ្យណែនាំ

លោក **ឃឹម ឧត្តម**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# **សេចក្តីធានាអះអាង**

យើងខ្ញុំឈ្មោះ **វេង គួងហេង** ជាភាសាឡាតាំង VENG KOUNGHENG កើតថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ មានអាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៩១E2 ផ្លូវលេខ ៩៣ ក្រុមទី ៣៤ ភូមិទី៥ សង្កាត់អូរឬស្សីទី៤ ខណ្ឌ ៧មករា រាជធានីភ្នំពេញ និងឈ្មោះ **ពេជ្រ ភាតា** ជាភាសាឡាតាំង PECH PHEATA កើតថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ១៩៩៨ មានអាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៣A ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលបច្ចុប្បន្នយើងខ្ញុំជានិស្សិតថ្នាក់នីតិសាស្ត្រ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច និង ជាបេក្ខភាពការពារសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំសិក្សា ២០១៩-២០២០។

យើងខ្ញុំសូមធ្វើការធានាអះអាងថា រាល់ខ្លឹមសារនៃសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ប្រធានបទ «**ក្របខណ្ឌគតិយុត្តសម្រាប់ការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក្នុងបរិបទជាតិ និង អន្តរជាតិ**» ចំពោះមុខនេះ ពិតប្រាកដបានកើតចេញពីលទ្ធផលការសិក្សាស្រាវជ្រាវ ដែលមានការចង្អុលបង្ហាញពីសាស្ត្រាចារ្យណែនាំ។ គ្មានផ្នែកណាមួយ នៃសារណានេះត្រូវបានដកស្រង់យកមកសរសេរ ដោយមិនបានផ្តល់ប្រភព និងឯកសារយោង នៃស្នាដៃរបស់ អ្នកនិពន្ធ ឬ អ្នករៀបរៀង រូបណាឡើយ។

យើងខ្ញុំសូមធ្វើការទទួលខុសត្រូវចំពោះមុខច្បាប់ស្តីពីសិទ្ធិ អ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ព្រមទាំងសុខចិត្តដោយឥតលក្ខខណ្ឌក្នុងការទទួលយកទណ្ឌកម្មវិន័យចំពោះមុខសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រសិនបើស្នាដៃនេះបានប៉ះពាល់ ដល់កម្មសិទ្ធិបញ្ញារបស់អ្នកដទៃ។

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **ទេព គួចហេង** និង**ម៉ិច តាតា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២០ ថ្នាក់ L4C3 ឆ្នាំសិក្សា ២០១៩-២០២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងនូវកតញ្ញូ ដឹងគុណជ្រាលជ្រៅ មិនអាចកាត់ថ្លៃបាន ដល់លោកអ្នកមានគុណទាំងពីរ គឺ**លោកឪពុកអ្នកម្តាយ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថ្នាក់ថ្នមថែរក្សា តែងតែផ្តល់នូវក្តីស្រឡាញ់ អប់រំទូន្មាន ប្រៀនប្រដៅប្រកបដោយទំនួលខុសត្រូវខ្ពស់ និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ស្មារតី និងថវិកាផ្គត់ផ្គង់ដល់ការសិក្សារបស់កូនៗ តាំងពីថ្នាក់មតេយ្យសិក្សា រហូតមកដល់ពេលនេះ ជាពិសេសតែងតែ ផ្តល់នូវកម្លាំងចិត្ត លើកទឹកចិត្ត និងផ្តល់ក្តីសង្ឃឹមដល់កូនៗជានិច្ច។ សេចក្តីដឹងគុណទាំងអស់ពុំអាចថ្លែងត្រឹមសំណេរមួយទំព័រនេះបានឡើយ។

ជាបន្ត យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ** និង**លោក/លោកស្រី សាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ ដែលលោកគ្រប់រូប បានផ្តល់ការអប់រំ ទាំងចំណេះដឹង និងសីលធម៌ ដល់យើងខ្ញុំក្នុងអំឡុងពេល ៤ឆ្នាំនេះ។

ជាបន្ទាប់មកទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រង ព្រមទាំងបុគ្គលិកនៃ**បណ្ណាល័យនីតិសាស្ត្រ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានរៀបចំ និងគ្រប់គ្រងសៀវភៅ ព្រមទាំងបង្កភាពងាយស្រួលដល់ការស្រាវជ្រាវរបស់និស្សិតនៃសាកលវិទ្យាល័យទាំងមូល។

ជាពិសេសជាងនេះទៅទៀត យើងខ្ញុំ សូមថ្លែងអំណរគុណ ដល់លោកសាស្ត្រាចារ្យ **យឹម ឧត្តម** ជាសាស្ត្រាចារ្យណែនាំការសរសេរសារណានេះ ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃ ផ្តល់ជាយោបល់កែសម្រួល និងត្រួសត្រាយផ្លូវដល់យើងខ្ញុំ រហូតដល់បានប្រសូតជាស្នាដៃចំពោះមុខនេះ។

ជាចុងក្រោយនេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់ លោកអ្នកមានគុណ **សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ** និង**សាស្ត្រាចារ្យទាំងអស់** សូមឱ្យជួបតែជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ដោយធ្លាប់បានសិក្សានៅថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ ឆមាសទី១ នូវមុខវិជ្ជានីតិកម្មសិទ្ធិបញ្ញា តាមកម្មវិធីសិក្សានៃសាកលវិទ្យាល័យ និងការស្រាវជ្រាវបន្ថែមពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា យើងខ្ញុំបានចាប់អារម្មណ៍ជាខ្លាំងចំពោះផ្នែកមួយនៃកម្មសិទ្ធិបញ្ញាគឺ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មានលក្ខណៈពេញនិយមយ៉ាងខ្លាំងនៅក្នុងពិភពលោក ក៏ប៉ុន្តែសម្រាប់ប្រទេសកម្ពុជា ភាគតិចណាស់ដែលមានប្រជាជនស្គាល់ ឬយល់ដឹង ហើយក៏មានតែបុគ្គលដែលពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាប៉ុណ្ណោះ ដែលអាចយល់ដឹងពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបានច្បាស់លាស់។ លើសពីនេះ យើងខ្ញុំយល់ថា ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនេះ គឺមានលក្ខណៈថ្មីសន្លាង ហើយពាណិជ្ជករ ឬអ្នកបង្កើតស្នាដៃ មួយចំនួនធំនៅក្នុងប្រទេសមិនទាន់យល់ច្បាស់ថា អ្វីទៅជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅឡើយផង។ ក៏ដោយសារតែការផ្សព្វផ្សាយនៅមានកម្រិត និងឯកសារសម្រាប់ការស្រាវជ្រាវជាភាសាខ្មែរនូវមានតិចតួច ហើយជាពិសេសអ្នកជំនាញសម្រាប់ការអនុវត្តម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនេះ នៅខ្វះខាតច្រើន។

ដើម្បីចូលរួមចំណែកក្នុងការផ្សព្វផ្សាយ និងក្នុងគោលបំណងសិក្សាបន្ថែមនៅក្នុងការអនុវត្តម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅកម្ពុជា និងបរទេស ឱ្យស្របទៅតាមបទដ្ឋានគតិយុត្តដែលនូវមានជាធរមាន គឺយើងខ្ញុំក៏សម្រេចចិត្តជ្រើសរើសយកប្រធានបទ «**ក្របខណ្ឌគតិយុត្តសម្រាប់ការពារម៉ាកសម្គាល់ ភូមិសាស្ត្រទំនិញក្នុងបរិបទជាតិ និង អន្តរជាតិ**» យកមកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ហើយនេះក៏ជាឱកាសដ៏វិសេសវិសាលមួយ ដែលយើងខ្ញុំអាចវាស់ស្ទង់ចំណេះដឹងតាមរយៈការសិក្សាអស់រយៈពេល ៤ឆ្នាំ និងការស្រាវជ្រាវបន្ថែម។

ជាអវសាន យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ស្នាដៃចំពោះមុខនេះ នឹងចូលរួមចំណែកដល់ការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយ ដែលអាចបម្រើដល់ការសិក្សារបស់ពួកគេ។ យើងខ្ញុំក៏សង្ឃឹមថា ខ្លឹមសារនៃសារណានេះ អាចត្រូវបានយកទៅសិក្សាបន្ថែម និងកែសម្រួលចំណុចខុសឆ្គង និងខ្វះខាតក្នុងពេលអនាគតជាក់ជាពុំខាន។ យើងខ្ញុំក៏សូមអភ័យទោសចំពោះកំហុសខុសឆ្គងនៅក្នុងអត្ថបទនេះ ទាក់ទងនឹងខ្លឹមសារ ការប្រើប្រាស់ អក្ខរាវិរុទ្ធ វេយ្យាករណ៍ និងបកប្រែពុំបានត្រឹមត្រូវ ហើយយើងខ្ញុំរីករាយនឹងទទួលយកការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត និងអ្នកស្រាវជ្រាវទាំងអស់ ដោយក្តីអនុគ្រោះ។

សូមអរគុណ។

# មាតិកា

ទំព័រ


**តារាងសម្គាល់អក្សរកាត់**..........v

**សេចក្តីផ្តើម**..........1

**ជំពូកទី១**

**ទិដ្ឋភាពទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ**..........5

**កថាខណ្ឌទី១៖ ប្រវត្តិនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ**..........5

ក. ប្រវត្តិនៃកកើតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ..........5

ខ. ផលប្រយោជន៍នៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ..........6

ខ.១. ផ្នែកសេដ្ឋកិច្ច..........6

ខ.២. ផ្នែកសង្គម..........8

ខ.៣. ផ្នែកបរិស្ថាន..........10

**កថាខណ្ឌទី២៖ សញ្ញាណទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ**..........11

ក. និយមន័យ និងប្រភេទនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ..........11

ក.១. និយមន័យ..........11

ក.២. ប្រភេទនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ..........12

ខ. លក្ខណៈខុសគ្នានឹងម៉ាកដទៃទៀត..........13

ខ.១. ពាណិជ្ជនាម..........13

ខ.២. ម៉ាកសមូហភាព..........14

ខ.៣. សញ្ញាសម្គាល់ប្រភពទំនិញ..........15

ខ.៤. ឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញ..........15

**ផ្នែកទី២៖ ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងបរិបទជាតិ និងអន្តរជាតិ**..........17

**កថាខណ្ឌទី១៖ បរិបទជាតិ**..........17

ក. ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ..........17

ខ. ប្រកាសស្តីពីនីតិវិធីចុះបញ្ជីនិងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ..........19

គ. ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់..........19

ឃ. បទដ្ឋានគតិយុត្តអន្តរជាតិផ្សេងៗដែលកម្ពុជាបានផ្តល់សច្ចាប័ន..........19

**កថាខណ្ឌទី២៖ បរិបទអន្តរជាតិ**...20
ក. សន្ធិសញ្ញាអន្តរជាតិដែលជាប់ទាក់ទងនឹងការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ...20
ក.១. អនុសញ្ញាទីក្រុងប៉ារីសឆ្នាំ១៨៨៣...20
ក.២. កិច្ចព្រមព្រៀមទីក្រុងម៉ាឌ្រីដឆ្នាំ១៨៩១...21
ក.៣. កិច្ចព្រមព្រៀងទីក្រុងលីសប៊នឆ្នាំ ១៩៥៨...22
ក.៤. កិច្ចព្រមព្រៀមទីក្រុងម៉ាឌ្រីដ ទាក់ទងនឹងការចុះបញ្ជីអន្តរជាតិនៃម៉ាក...23
ក.៥. កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា...24
ខ. ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅក្នុងកិច្ចព្រមព្រៀងពហុភាគី និងតំបន់...25
ខ.១. កិច្ចព្រមព្រៀងអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក...25
ខ.២. ពិធីសារទីក្រុងបង់ហ្ស៊ុលស្តីពីម៉ាក...25
គ.កិច្ចព្រមព្រៀងទ្វេភាគីសហគមន៍អឺរ៉ុបសម្រាប់ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ...26
គ.១. កិច្ចព្រមព្រៀងរវាងសហគមន៍អឺរ៉ុប និងប្រទេសអូស្ត្រាលី ...26
គ.២. កិច្ចព្រមព្រៀងរវាងសហគមន៍អឺរ៉ុប និងប្រទេសកាណាដា...27
គ.៣. កិច្ចព្រមព្រៀងសហគមន៍អឺរ៉ុប និងប្រទេសម៉ិកស៊ិក...27
គ.៤. កិច្ចព្រមព្រៀងសហគមន៍អឺរ៉ុប និងប្រទេសស៊ីលី...27
គ.៥. កិច្ចព្រមព្រៀងសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក ...28

## ជំពូកទី២

## នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

## ក្នុងក្របខណ្ឌភូមិយុត្តជាតិ និងអន្តរជាតិ

**ផ្នែកទី១៖ នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងក្របខណ្ឌភូមិយុត្តជាតិ**.30
**កថាខណ្ឌទី១៖ នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងស្រុក**...30
ក. លក្ខខណ្ឌដើម្បីទទួលបានការការពារ...30
ក.១. លក្ខណៈរបស់អ្នកដាក់ពាក្យស្នើសុំ...30
ក.១.១. ក្រុមផលិតករ ប្រតិបត្តិករ ស្ថាប័ន និង/ឬបុគ្គលពាក់ព័ន្ធ...31
ក.១.២. ផលិតករ ឬប្រតិបត្តិករតែមួយ...32
ក.២. សៀវភៅបន្ទុក ...32
ក.៣. ការត្រួតពិនិត្យអនុលោមភាព...33
ក.៤. ការកំណត់ព្រំដែន ...35

ក.៥. ឯកសារបញ្ជាក់ភស្តុតាង ........ 35
ខ. នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ........ 37
ខ.១. ការដាក់ពាក្យស្នើសុំចុះបញ្ជី ........ 37
ខ.២. ការដកពាក្យស្នើសុំចុះបញ្ជី ........ 40
ខ.៣. ការត្រួតពិនិត្យពាក្យស្នើសុំចុះបញ្ជី ........ 40
ខ.៤. ការត្រួតពិនិត្យខ្លឹមសារពាក្យស្នើសុំចុះបញ្ជី ........ 41
ខ.៥. ការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ........ 43
**កថាខណ្ឌទី២៖ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស** ........ 44
ក. លក្ខខណ្ឌនៃការចុះបញ្ជី ........ 44
ខ. នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស ........ 45
**កថាខណ្ឌទី៣៖ ការកែប្រែ និងបណ្តឹង** ........ 46
ក. ការកែសម្រួល មោឃភាព និងការលុបចោល ........ 46
ក.១. ការកែសម្រួល ........ 46
ក.២. មោឃភាព និងការលុបការចុះបញ្ជី ........ 46
ខ. បណ្តឹងពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ........ 48
ខ.១. បណ្តឹងជំទាស់ ........ 48
ខ.២. បណ្តឹងតវ៉ា ........ 49
**កថាខណ្ឌទី៤៖ ការប្រើប្រាស់រូបសញ្ញាជាតិ** ........ 50
ក. លក្ខខណ្ឌក្នុងការប្រើប្រាស់ ........ 50
ខ. អ្នកប្រើប្រាស់រូបសញ្ញាជាតិ ........ 50
**កថាខណ្ឌទី៥៖ អានុភាពនៃការចុះបញ្ជី** ........ 51
ក. សិទ្ធិដែលទទួលបានពីការចុះបញ្ជី ........ 51
ខ. រយៈពេលនៃកិច្ចការពារ និងកាតព្វកិច្ច ........ 52
គ. កិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ........ 52
គ.១. កិច្ចការពារចំពោះការរំលោភបំពាន ........ 53
គ.២. វិធានការនៃការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ........ 54
គ.២.១ វិធានការជូនដំណឹង ........ 54
គ.២.២. វិធានការបណ្តោះអាសន្ន ........ 54

គ.២.៣. វិធានការតាមមាត់ច្រកព្រំដែន ........ 55
គ.២.៤. ការឃាត់ទុក និងការរឹបអូស ........ 55
គ.២.៥. ទណ្ឌកម្ម ........ 56
**ផ្នែកទី២៖ នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញតាមបទដ្ឋានគតិយុត្តអន្តរជាតិ** ........ 57
**កថាខណ្ឌទី១៖ ការចុះបញ្ជីតាមកិច្ចព្រមព្រៀងពហុភាគី** ........ 58
ក. ប្រព័ន្ធទីក្រុងលីសប៊ន ........ 58
ក.១. ការដាក់ពាក្យសុំចុះបញ្ជី ........ 59
ក.២. ការត្រួតពិនិត្យពាក្យស្នើសុំ ........ 59
ក.៣. ការឆ្លើយតបរបស់ភាគីនៃកិច្ចព្រមព្រៀង ........ 59
ខ. ប្រព័ន្ធទីក្រុងម៉ាឌ្រីដ ........ 60
ខ.១. ដំណាក់កាលទី១ ........ 61
ខ.២. ដំណាក់កាលទី២ ........ 62
ខ.៣. ដំណាក់កាលទី៣ ........ 62
**កថាខណ្ឌទី២៖ ការចុះបញ្ជីតាមតំបន់ និងតាមកិច្ចព្រមព្រៀងទ្វេភាគី** ........ 63
ក. ការចុះបញ្ជីតាមតំបន់ (សហភាពអឺរ៉ុប) ........ 63
ខ. ការចុះបញ្ជីតាមកិច្ចព្រមព្រៀងទ្វេភាគី ........ 66
**សេចក្តីសន្និដ្ឋាន** ........ 71
**អនុសាសន** ........ 73
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# តារាងសម្គាល់អក្សរកាត់

| | |
|---|---|
| **AO** | ឈ្មោះសម្គាល់ទីតាំងប្រភពដើមនៃទំនិញ/ Appellation of Origin |
| **ARIPO** | អង្គការកម្មសិទ្ធិបញ្ញាក្នុងតំបន់អាហ្វ្រិក/ The African Regional Intellectual Property Organization |
| **AU** | សហភាពទ្វីបអាហ្វ្រិក/ The African Unions |
| **EC** | សហគមន៍អឺរ៉ុប/ European Community |
| **EU** | សហភាពអឺរ៉ុប/ European Unions |
| **GIO** | សមាគមសម្គាល់ភូមិសាស្ត្រទំនិញ/ Geographical Indication Organization |
| **GIs** | ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ/ Geographical Indications |
| **OAPI** | អង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក/ The African Intellectual Property Organization |
| **PDO** | ការការពារឈ្មោះនៃទីតាំងប្រភពដើម/ Protected Designation of Origin |
| **PGI** | ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ/ Protected Geographical Indication |
| **TSG** | ការធានាភាពពិសេសនៃប្រពៃណី/ Traditional Specialty Guaranteed |
| **UNECA** | គណៈកម្មការសេដ្ឋកិច្ចទ្វីបអាហ្វ្រិក/ United Nations Economic Commission for Africa |
| **WIPO** | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក/ World Intellectual Property Organization |
| **WTO** | អង្គការពាណិជ្ជកម្មពិភពលោក/ World Trade Organization |

# សេចក្តីផ្តើម

# សេចក្តីផ្តើម

វិស័យកម្មសិទ្ធិបញ្ញា បានក្លាយជាវិស័យដ៏សំខាន់មួយក្នុងចំណោមវិស័យផ្សេងៗទៀតក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ ដោយសារតែកម្មសិទ្ធិបញ្ញាបានជំរុញឱ្យផលិតករ អ្នកចែកចាយ និងពាណិជ្ជករ ព្យាយាមស្វះស្វែងរកនូវការបង្កើតថ្មី ដើម្បីបំពេញតម្រូវការរបស់មនុស្សជាតិ។ ការបង្កើតថ្មីនេះ អាចជារូបភាពនូវការបង្កើតនូវបច្ចេកវិទ្យាថ្មីៗ ស្នាដៃសិល្បៈ ឧស្សាហកម្ម និងផលិតផលប្រើប្រាស់ជាចម្បងក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សជាតិ ជាអាទិ៍។ លើសពីនេះ ដើម្បីជំរុញឱ្យអ្នកផលិត ឬពាណិជ្ជករ ធ្វើការផលិតកាន់តែខ្លាំង អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ដែលបានបង្កើតឡើងនាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧ ដោយអនុសញ្ញាស្តីពីការបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក [1] (WIPO Convention) បានតាក់តែងនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងការការពារកម្មសិទ្ធិបញ្ញាបន្ថែម និងធ្វើការវិសោធនកម្មនូវបទប្បញ្ញត្តិកម្មសិទ្ធិបញ្ញាចាស់ៗ ព្រមទាំងរៀបចំឱ្យមាននូវប្រព័ន្ធការពារទៅលើប្រភេទកម្មសិទ្ធិបញ្ញានីមួយៗ ក្នុងក្របខណ្ឌអន្តរជាតិទៀតផង។ ទន្ទឹមនឹងនេះ ដោយសារតែវិស័យកម្មសិទ្ធិបញ្ញាត្រូវបានរំលោភបំពានកាន់តែធ្ងន់ធ្ងរឡើងៗ អង្គការពាណិជ្ជកម្មពិភពលោក (WTO) បានបង្កើតនូវកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS Agreement) ឆ្នាំ១៩៩៤ ក្នុងគោលបំណងដើម្បីការពារដល់វិស័យកម្មសិទ្ធិបញ្ញាឱ្យកាន់តែមានប្រសិទ្ធភាពល្អប្រសើរ។

នៅក្នុងកិច្ចព្រមព្រៀងមួយនេះ បានរំលេចឱ្យឃើញនូវប្រភេទកម្មសិទ្ធិបញ្ញាមួយ ឱ្យមានសញ្ញាណកាន់តែច្បាស់លាស់ជាងពីមុន គឺម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (Geographical Indications “GIs”) ដែលជាប្រភេទកម្មសិទ្ធិបញ្ញាថ្មីមួយ ក្នុងចំណោមប្រភេទកម្មសិទ្ធិបញ្ញាទាំងអស់។ បើយោងតាមមាត្រា២២ កថាខណ្ឌទី១ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា "*ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជាការចង្អុលបង្ហាញដែលសម្គាល់ទំនិញមួយថា មានប្រភពក្នុងដែនដីនៃសមាជិកណាមួយ ឬតំបន់ ឬទីតាំងណាមួយនៃដែនដីនេះ ដែលមានគុណភាពជាក់លាក់ កិត្តិស័ព្ទ ឬចរិកលក្ខណៈផ្សេងទៀតនៃទំនិញ ដែលកើតចេញជាពិសេសពីប្រភពភូមិសាស្ត្រនោះ*"។ បានសេចក្តីថា ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺជាប្រភេទម៉ាកមួយ ដែលធ្វើការការពារទៅលើផលិតផលមួយដែលកើតចេញពីប្រភពភូមិសាស្ត្រមួយច្បាស់លាស់ និងជួយការពារទៅលើក្រុមផលិតករ ឬក្រុមពាណិជ្ជករដែលនៅក្នុងតំបន់នោះ។ ជាក់ស្តែង ប្រទេសកម្ពុជា ដែលជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (១៩៩៥)[2] និងសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (២០០៤)[3] ក៏បានតាក់តែងនូវបទប្បញ្ញត្តិសម្រាប់ការពារទៅលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញផងដែរ។ នាថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បាន

[1] “A Brief History of WIPO’, WIPO, https://bit.ly/2OpKXzc, ចូលមើលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

[2] “Cambodia Information in WIPO”, WIPO, https://bit.ly/30aZOD1, ចូលមើលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

[3] “Cambodia and the WTO”, WTO, https://bit.ly/2AUEOYG, ចូលមើលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

ប្រកាសឱ្យប្រើប្រាស់នូវច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក្នុងគោលបំណងការពារកម្មសិទ្ធិបញ្ញារបស់ផលិតករ ប្រតិបត្តិករ និងការពារអ្នកប្រើប្រាស់ផលិតផលដែលពាក់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ព្រមទាំងរក្សាអត្តសញ្ញាណជាតិ និងពង្រឹងចំណេះដឹង ចំណេះធ្វើតាមបែបប្រពៃណី និងរួមចំណែកកាត់បន្ថយភាពក្រីក្រ។

លើសពីនេះ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មានលក្ខណៈខុសប្លែកពីម៉ាកដទៃទៀត ដោយសារតែលក្ខខណ្ឌនៃការទទួលបាននូវការការពារ នីតិវិធីនៃការចុះបញ្ជី និងរយៈពេលនៃការការពារម៉ាកនេះ គឺពិបាកក្នុងការស្នើសុំ និងលម្អិតខ្លាំង ព្រមទាំងតែត្រូវធ្វើការសិក្សាត្រួតពិនិត្យចំណាយពេលយូរ ដើម្បីទទួលបាននូវការការពារ។ ក៏ប៉ុន្តែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនេះ បានផ្ដល់នូវអត្ថប្រយោជន៍យ៉ាងច្រើន ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ជាពិសេសកសិករ ឬផលិតករ ដែលរស់នៅក្នុងតំបន់ដែលផលិតផលទទួលបាននូវការការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ព្រោះតាមរយៈការការពារនេះ អាចជួយលើកស្ទួយជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងតំបន់ឱ្យកាន់តែល្អប្រសើរឡើង។ បច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជា មានផលិតផលមួយចំនួន ត្រូវបានចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ហើយក្នុងចំណោម នោះ មានផលិតផលចំនួន ២ មុខ គឺម្រេចកំពត (Kampot pepper) និងស្ករត្នោតកំពង់ស្ពឺ (Skor Thnot Kampong Speu) ត្រូវបានចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិនៅសហភាពអឺរ៉ុប (EU)។

ដូចបានលើកឡើងពីខាងលើនេះ ដើម្បីឱ្យផលិតផល ឬទំនិញណាមួយ ត្រូវទទួលបាននូវការការពារ ត្រូវតែធ្វើការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ ការចុះបញ្ជីនេះ អាចជាការចុះបញ្ជីតាមបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ ដែលអាស្រ័យទៅលើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ថាចង់បាននូវការការពារក្នុងកម្រិតបែបណា។ ការចុះបញ្ជីតាមបទដ្ឋានគតិយុត្តជាតិ គឺអាស្រ័យទៅលើប្រព័ន្ធចុះបញ្ជីរបស់ប្រទេសនីមួយៗ ដែលបានរៀបចំនូវប្រព័ន្ធការពារលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជាក់ស្ដែងនៅព្រះរាជាណាចក្រកម្ពុជា គឺការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ធ្វើតាម បទប្បញ្ញត្តិពិសេស (Sui generis) តាមរយៈច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ ២០១៤។ រីឯការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅសហរដ្ឋអាមេរិក គឺធ្វើឡើងតាមការចុះបញ្ជីជាម៉ាកសមូហភាព (Collective Mark) និងវិញ្ញាតកម្ម (Certification Marks)។ ចំណែកការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងក្របខណ្ឌអន្តរជាតិ អាចធ្វើឡើងតាមកិច្ចព្រមព្រៀងពហុភាគី (Multilateral Agreement) កិច្ចព្រមព្រៀងទ្វេភាគី (Bilateral Agreement) និងកិច្ចព្រមព្រៀងតំបន់ (Regions Agreement)។

ដោយសារតែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺជាសញ្ញាណថ្មីមួយក្នុងវិស័យកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា និងមានលក្ខណៈពិសេស ព្រមទាំងស្មុគស្មាញក្នុងការយល់ ដូច្នេះទើប បញ្ហាគតិយុត្តសំខាន់ៗមួយចំនួនត្រូវបានលើកឡើង សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ ជាអាទិ៍ តើមាននូវក្របខណ្ឌគតិយុត្តអ្វីខ្លះ សម្រាប់ធ្វើការ

ការពារលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ? ហើយដើម្បីទទួលបាននូវការពារក្នុងបរិបទជាតិ និងអន្តរជាតិ តើការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបំពេញនូវនីតិវិធីបែបណាខ្លះ?

គោលបំណងនៃការស្រាវជ្រាវនូវប្រធានបទស្តីពី **"ក្របខណ្ឌគតិយុត្តសម្រាប់ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងបរិបទជាតិ និងអន្តរជាតិ"** គឺដើម្បីពង្រីកការយល់ដឹងពីកម្មសិទ្ធិបញ្ញានៅក្នុងបរិបទកម្ពុជា និងអន្តរជាតិ ជាពិសេសផលប្រយោជន៍នៃការលើកស្ទួយវិស័យកម្មសិទ្ធិបញ្ញា ព្រមទាំងជួយកាត់បន្ថយនូវការរំលោភបំពានទៅលើសិទ្ធិរបស់ម្ចាស់ម៉ាក និងលើកទឹកចិត្តឱ្យផលិតករ កសិករ ឬពាណិជ្ជករ ធ្វើការចុះបញ្ជីនូវទំនិញ ឬផលិតផល ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឱ្យកាន់តែច្រើនឡើងៗ។ ជាពិសេស ស្នាដៃស្រាវជ្រាវមួយនេះ គឺចង់ឱ្យរដ្ឋបន្តនូវការផ្សព្វផ្សាយ និងព្យាយាមដាក់បញ្ចូលនូវផលិតផលប្រពៃណីជាច្រើនរបស់កម្ពុជា ទៅជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដើម្បីជួយថែរក្សា អភិរក្សនូវប្រពៃណីរបស់ខ្មែរ និងសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាជន។ ប្រធានបទស្រាវជ្រាវមួយនេះ នឹងធ្វើការសិក្សាផ្តោតសំខាន់ទៅលើបទដ្ឋានគតិយុត្ត ដែលយកមកការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងបរិបទជាតិ និងអន្តរជាតិ ព្រមទាំងនីតិវិធីក្នុងការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដើម្បីទទួលបាននូវការការពារក្នុងកម្រិតជាតិ និងអន្តរជាតិ។

វិសាលភាពនៃការស្រាវជ្រាវក្នុងសារណានេះ កម្រិតត្រឹមការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងបរិបទជាតិ និងអន្តរជាតិតែប៉ុណ្ណោះ។ បរិបទអន្តរជាតិក្នុងន័យនេះ គឺត្រឹមកម្រិតការការពារ ដែលមានកំណត់ដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក កម្រិតតំបន់មួយចំនួន (សហភាពអឺរ៉ុប) និងកម្រិតទ្វេភាគីសំខាន់ៗមួយចំនួន (សហរដ្ឋអាមេរិក និងចិន)។ ដើម្បីសម្រេចបាននូវស្នាដៃចំពោះមុខនេះ គឺជៀសមិនផុតពីការសិក្សាស្រាវជ្រាវលើឯកសារ និងប្រភពព័ត៌មានផ្សេងទៀត ដែលមានបង្កប់នូវខ្លឹមសារពាក់ព័ន្ធ ដើម្បីជាបង្អែកសម្រាប់ការបកស្រាយទៅលើចំណោទបញ្ហាខាងលើនេះ។ អាស្រ័យហេតុនេះ យើងខ្ញុំបានប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវចំបងមួយចំនួន៖ ទី១ ប្រភពចម្បង៖ ការស្រាវជ្រាវតាមរយៈអានសៀវភៅដែលបោះពុម្ពផ្សាយ ជាភាសាខ្មែរ និងអង់គ្លេស និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ សៀវភៅជាភាសាខ្មែរ ភាគច្រើនបោះពុម្ពដោយក្រសួងពាណិជ្ជកម្ម (សៀវភៅណែនាំ និងព្រឹត្តិបត្រព័ត៌មាន) ចំណែកឯសៀវភៅជាភាសាបរទេស គឺយកចេញពីការបោះពុម្ពផ្សាយដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងស្ថាប័នដែលជាប់ពាក់ព័ន្ធដទៃទៀត។ ទី២ ប្រភពបន្ទាប់បន្សំ៖ ឯកសារដែលបានផ្សាយលើអ៊ីនធឺណេត ជាសៀវភៅបែបស្រាវជ្រាវ ព្រមទាំងជើណាល (Journal) ដែលភាគច្រើនអ្នកនិពន្ធសរសេរទាក់ទងនឹងអត្ថប្រយោជន៍របស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងការការពារទៅលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក្នុងប្រទេស ឬតំបន់ណាមួយ ព្រមទាំងអត្ថបទកាសែតដែលបានចុះផ្សាយនៅលើគេហទំព័រព័ត៌មាន។

ដើម្បីងាយស្រួលក្នុងការបកស្រាយនូវប្រធានបទស្តីពី ក្របខណ្ឌគតិយុត្តសម្រាប់ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងបរិបទជាតិ និងអន្តរជាតិ ឱ្យបានស៊ីជម្រៅ និងគ្រប់គ្រងជ្រុងជ្រោយ ជាពិសេសឆ្លើយ

តបទៅនឹងបញ្ហាគតិយុត្ត ដូចបានលើកឡើងពីខាងលើនេះ គឺត្រូវធ្វើការបែងចែកនូវការស្រាវជ្រាវសារណានេះ ជាពីរជំពូកធំៗ គឺ៖ ទិដ្ឋភាពទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (ជំពូកទី១) និងនីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងបរិបទជាតិ និងអន្តរជាតិ (ជំពូកទី២)។

# ជំពូកទី១

# ទិដ្ឋភាពទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

# ជំពូកទី១

# ទិដ្ឋភាពទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺជាផ្នែកមួយនៃកម្មសិទ្ធិបញ្ញា។ នៅក្នុងវិស័យកម្មសិទ្ធិបញ្ញា ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបានចាត់ទុកថា ជាផ្នែកមួយដ៏សំខាន់ក្នុងការជំរុញឱ្យមានការបង្កើតថ្មីនៅក្នុងវិស័យកសិកម្ម។ ប៉ុន្តែនៅព្រះរាជាណាចក្រកម្ពុជា ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនេះ គឺមានលក្ខណៈថ្មីសន្លាងសម្រាប់ប្រជាជន ឬពាណិជ្ជករ ទោះបីជាកម្ពុជាបានបង្កើតច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញតាំងពីឆ្នាំ២០១៤ហើយក៏ដោយ។ ទាក់ទងនឹងទិដ្ឋភាពទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ អាចរំលេចឱ្យឃើញនូវផ្នែកសំខាន់ៗពីរគឺៈ សញ្ញាណទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រ (ផ្នែកទី១) និងការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងបរិបទជាតិ និងអន្តរជាតិ (ផ្នែកទី២)។

## ផ្នែកទី១៖ សញ្ញាណទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ដើម្បីយល់ឱ្យកាន់តែច្បាស់អំពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ យើងគប្បីសិក្សាទៅលើប្រវត្តិនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញជាមុនសិន បន្ទាប់មកនឹងសិក្សាលម្អិតអំពីសញ្ញាណទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។

### កថាខណ្ឌទី១៖ ប្រវត្តិនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

#### ក. ប្រវត្តិនៃកកើតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ពីដំបូងឡើយ ការការពារក្នុងវិស័យកម្មសិទ្ធិបញ្ញាធ្វើឡើងតែចំពោះតែម៉ាក គំនូរឧស្សាហកម្ម ប្រកាសនីយបត្រតក្កកម្ម សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលប៉ុណ្ណោះ។ ជាក់ស្តែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីសឆ្នាំ១៨៨៣ ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម គឺមិនឃើញមានការលើកឡើងពីការការពារទៅលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឡើយ ប៉ុន្តែមានការលើកឡើងពីការការពារទៅលើសញ្ញាសម្គាល់ប្រភពទំនិញ (Indication of Source) និងឈ្មោះសម្គាល់ទីតាំងប្រភពដើមនៃទំនិញ (Appellation of Origin) ។ ក្រោយមក ដោយសារតែសង្គមមានការជឿនលឿន ហើយច្បាប់ក៏មានការវិវត្តឥតឈប់ឈរ រហូតមកដល់ចុងសតវត្សទី១៩ ឃើញមាននូវសញ្ញាណមួយចំនួនពាក់ព័ន្ធនឹងការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញខ្លះដែរ ដូចជាការបង្កើតនូវកិច្ចព្រមព្រៀងម៉ាឌ្រីដឆ្នាំ១៨៩១ (The Madrid Agreement) ស្តីពីការបង្ក្រាបនៃការក្លែងបន្លំ ឬការបោកបញ្ឆោតនៃសញ្ញាសម្គាល់ប្រភពទំនិញ។

ដោយសារតែមាននូវការរំលោភបំពានច្រើនទៅលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ រហូតនៅឆ្នាំ១៩១៩ ប្រទេសបារាំងបានបង្កើតច្បាប់ពិសេសមួយ ដើម្បីការពារទៅលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺទាក់ទងនឹងការការពារឈ្មោះសម្គាល់ទីតាំងប្រភពដើមនៃទំនិញ (Appellations of Origin) ដោយផ្តោតសំខាន់ទៅលើការការពារ

លើស្រាទំពាំងបាយជូ និងស្រា (Wines and Spirits)[4]។ រហូតមកដល់ចុងសតវត្សទី២០ ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ រឹតតែត្រូវបានគេការពារខ្លាំងជាមុន ជាពិសេសនៅសហភាពអឺរ៉ុប ជាកន្លែងសម្បូរទៅដោយទំនិញដែលផ្សាភ្ជាប់ជាមួយប្រពៃណី ដោយបានតាក់តែងនូវបទប្បញ្ញត្តិច្បាប់ បង្កើតនូវប្រព័ន្ធការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ រួមមាន ការការពារឈ្មោះនៃទីតាំងប្រភពដើម (Protected Designation of Origin "PDO") ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ(Protected Geographical Indication "PGI") ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញលើប្រភេទស្រា (Geographical Indication of Spirit drinks and aromatized wines "GI") និងការធានាភាពពិសេសនៃប្រពៃណី (Traditional Specialty Guaranteed "TSG")[5]។

បន្ទាប់ពីសហភាពអឺរ៉ុបបានបង្កើតនូវប្រព័ន្ធការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅឆ្នាំ១៩៩៤ អង្គការពាណិជ្ជកម្មពិភពលោក (WTO) បានតាក់តែងនូវកិច្ចព្រមព្រៀងស្ដីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS Agreement) ដែលបានលើកឡើងពីការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញយ៉ាងច្បាស់ លាស់[6] ជាងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត។

### ខ. ផលប្រយោជន៍នៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺជាប្រភេទម៉ាកមួយ ដែលផ្ដល់នូវផលប្រយោជន៍យ៉ាងច្រើន សម្រាប់ផលិតករ ប្រតិបត្តិករ ឬប្រជាជនដែលរស់នៅក្នុងតំបន់ ដែលត្រូវបានចាត់ទុកថាជាតំបន់នៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ហើយផលប្រយោជន៍ដែលកើតចេញពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអាចជាផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គម និងផ្នែកបរិស្ថាន។

#### ខ.១. ផ្នែកសេដ្ឋកិច្ច

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ បានជួយដល់ផលិតករឱ្យទទួលបានតម្លៃល្អប្រសើរ សម្រាប់ផលិតផលរបស់ពួកគេ ព្រមទាំងមានការធានានូវសុវត្ថិភាព និងគុណភាពជូនអតិថិជន។ ជាក់ស្ដែងដូចមាន់បារាំង (Bresse Poultry[7]) ត្រូវបានការចុះបញ្ជីការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅក្នុងឆ្នាំ១៩៧៥ ហើយ មាន់បារាំង (Bresse Poultry) បានទទួលនូវការកើនតម្លៃបួនដង បើប្រៀបនឹងតម្លៃសាច់មាន់នេះ ពេលមិនទាន់ចុះបញ្ជីការពារ។ នេះជាឧទាហរណ៍មួយដែលបញ្ជាក់ថា ទំនិញដែលមានប្រភពត្រឹមត្រូវ ឬទំនិញដែលបានចុះបញ្ជីជាម៉ាកសម្គាល់

---

[4] Lori E. Simon, *"Appellations of Origin: The Continuing Controversy"*, Northwestern Journal of International Law & Business, 1983, p137-138, ចូលមើលថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០

[5] "Green Paper on the Protection of Geographical Indications for non-agricultural products", European Commission, July 2014, https://bit.ly/2AKHnfs

[6] ជំពូកទី២ ផ្នែកទី៣ នៃកិច្ចព្រមព្រៀងស្ដីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS Agreement)

[7] *"Bresse Poultry: The queen of poultry and the poultry of kings"*, Poulet de bresse, https://bit.ly/387kYpp, ចូលមើលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០

ភូមិសាស្ត្រទំនិញ គឺអាចធ្វើឱ្យការលក់ទំនិញនោះ បានតម្លៃថ្លៃខុសពីធម្មតា។ លើសពីនេះ ឱកាសកើនឡើងនូវប្រាក់ចំណូលបន្ថែម ចំពោះផលិតផលដែលត្រូវបានការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រដោយសារតែអាចលើកលែងពន្ធនាំចេញនាំចូល ព្រោះផលិតផលការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រ គឺមានលក្ខណៈជាផលិតផលដែលពុំមានការប្រកួតប្រជែងគ្រប់ដណ្ដប់លើទីផ្សារពិសេសមួយផ្នែក ដែលជាហេតុនាំឱ្យអាចមានឱកាសក្នុងការនាំចូលទំនិញដោយលើកលែងពន្ធ។ ឧទាហរណ៍៖ ផលិតផលកសិកម្មរបស់ទ្វីបអាហ្វ្រិកដែលបានចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺអាចនឹងត្រូវបានកាត់បន្ថយ ឬលើកលែងនូវពន្ធនាំចូលទំនិញទៅកាន់សហភាពទ្វីបអឺរ៉ុបដោយសារតែកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហភាពទ្វីបអឺរ៉ុប និងទ្វីបអាហ្វ្រិក[៨]។

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ បាននាំមកនូវការបន្ថែមតម្លៃសម្រាប់តំបន់នៃប្រភពដើម ដោយប្រយោលតាមរយៈទេសចរណ៍។ ទេសចរណ៍ អាចបន្ថែមនូវគុណតម្លៃទៅដល់តំបន់ជនបទតាមរយៈសេវាកម្មដែលជាប់ទាក់ទង់ជាមួយផ្នែកទេសចរណ៍ និងការលក់នូវម្ហូបអាហារនៅតាមភោជនីយដ្ឋាន និងហាងផ្សេងៗ។ ទេសចរណ៍ គឺជាសេវាដែលមិនមែនជាផ្នែកនៃកសិកម្ម និងសាកវប្បកម្ម ប៉ុន្តែវាមានទំនាក់នងទៅនឹងផលិតផលកសិ-ឧស្សាហកម្មជាពិសេស ដោយសារតែកេរ្តិ៍ឈ្មោះរបស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលអាចទាក់ទាញទេសចរណ៍នៅក្នុងតំបន់ណាមួយ។ ទោះជាយ៉ាងណា ការអភិវឌ្ឍផ្នែកទេសចរណ៍ដែលជាប់ទាក់ទងនឹងអាហារតាមតំបន់ ក៏មាននូវការបារម្ភអំពីការចម្លងតាមផងដែរ។ គណៈកម្មាធិការជំនាញវិជ្ជាជីវៈរបស់ស្រាសំប៉ាញ (The Comité Interprofessionnel du Vin de Champagne) បានប្រកាសនូវសំណើ ដើម្បីដាក់បញ្ចូលនូវទេសភាពនៅតំបន់ផលិតស្រាសំប៉ាញ ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក[៩]។ គោលបំណងនេះគឺដើម្បីការពារទីតាំងនានាក្នុងតំបន់ផលិតស្រាសំប៉ាញ ដែលបញ្ចូលទាំងចំការទំពាំងបាយជូរ និងបន្ទប់ក្រោមដីសម្រាប់ផ្ទុកស្រាឆ្លាក់ព័ទ្ធជុំវិញដោយដីស បូករួមទាំងទេសភាពតំបន់ផលិតស្រាសំប៉ាញ។ ទេសភាពនេះ គឺមានប្រភពដែលមានតម្លៃសម្រាប់ទេសចរណ៍។ ដូច្នេះ ស្រាសំប៉ាញដែលមានការការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ បានជួយបង្កើនតម្លៃមួយកម្រិតដល់តំបន់នោះ ដោយប្រយោល។

ការការពារនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក៏ជំរុញឱ្យមានការបង្កើតថ្មី និងសហគ្រិនភាព នៅក្នុងតំបន់ជនបទ។ បើសិនជាសិទ្ធិការពារទៅលើផលិផលកសិកម្ម នៅតំបន់នានាមានលក្ខណៈតឹងរឹងនោះនឹងមានការជំរុញដ៏ល្អប្រសើរឱ្យប្រជាកសិករ ធ្វើការអភិវឌ្ឍនូវការដាំដុះផលិតផលកសិកម្មរបស់ខ្លួនកាន់តែច្រើនឡើង និងចេះជ្រើសរើសដំណាំណាដែលមានសក្ដានុពលថែមទៀតផង។

---

8 "EU trade policy and Africa's exports", Trade European Commission, 2017, https://bit.ly/2EAjsRN, ចូលមើលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០

9 "Champagne Hillsides, House and Cellars", UNESO, https://bit.ly/3g8WizL, ចូលមើលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជាឧបករណ៍ទីផ្សារដ៏មានតម្លៃសម្រាប់ផលិតករ។ ការយល់ដឹងរបស់ផលិតករអំពីសក្តានុពល ដើម្បីការពារផលិតផលដែលមានគុណតម្លៃក្នុងតំបន់ទៅជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ បានបង្កើតឱ្យមាននូវអត្ថប្រយោជន៍នៃការប្រកួតប្រជែងក្នុងទីផ្សាររយៈពេលវែង សម្រាប់ក្រុមហ៊ុនកសិកម្ម។ នេះបានសបញ្ជាក់ អំពីឱកាសដែលក្រុមហ៊ុនកសិកម្មអាចនឹងមានលទ្ធភាពប្រកួតប្រជែងខ្លាំងជាងមុន ប្រសិនបើពួកគេបានយល់ដឹងអំពីថា ផលិតផលរបស់ពួកគេអាចនឹងការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយសារតែចរិតលក្ខណៈរបស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដូចជាការបន្ថែមគុណតម្លៃទៅលើទីកន្លែងដែលជាតំណាង ដែលជាឧបករណ៍ទាក់ទាញទីផ្សារដ៏មានតម្លៃ។ វាអាចឆ្លុះបង្ហាញឱ្យឃើញតាមរយៈកំណើននៃចំនួនអតិថិជន ដែលមានចំណាប់អារម្មណ៍ក្នុងការគាំទ្រទៅលើផលិតផលដែលបានបន្ថែមគុណតម្លៃ។ ការប្រើប្រាស់នូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជាឧបករណ៍ទាក់ទាញទីផ្សារមានផលវិជ្ជមានជាច្រើនដើម្បីជួយលើកកម្ពស់ការអភិវឌ្ឍតំបន់ជនបទដោយចីរភាព តាមរយៈការបង្កើនតម្លៃផលិតផល ការវាយលុកចូលទៅក្នុងទីផ្សារថ្មី និរន្តរភាពទីផ្សារ ការអប់រំអតិថិជន ជាដើម។

### ខ.២. ផ្នែកសង្គម

ភាពត្រឹមត្រូវយុត្តិធម៌នៅក្នុងបរិបទនេះ សំដៅទៅលើការការពារការប្រកួតប្រជែងមិនស្មោះត្រង់។ នេះគឺជាគោលបំណងដ៏សំខាន់នៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលការពារផលិតករនៅក្នុងតំបន់មួយដែលមានបច្ចេកទេសបង្កើតនូវផលិតផលមួយប្រភេទ ពីការដណ្តើមដោយខុសច្បាប់ពីផលិតករខាងក្រៅពីតំបន់នោះ ចៀសពីការប្រកួតប្រជែងមិនស្មោះត្រង់។ **ឧទាហរណ៍** ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់នៅក្នុងទីក្រុង Antigua ប្រទេសក្វាតេម៉ាឡា។ ជាក់ស្តែងនៅឆ្នាំ២០០៣[10] កាហ្វេ Antigua ប្រមាណត្រឹមតែ ៦,០០០ លានតោនប៉ុណ្ណោះ ដែលផលិតចេញពីទីក្រុង Antigua នៃប្រទេសក្វាតេម៉ាឡា ប៉ុន្តែកាហ្វេ ៥០,០០០លានតោន ត្រូវបានដាក់លក់ក្រោមឈ្មោះកាហ្វេ Antigua នៅជុំវិញពិភពលោក។ ប្រសិនបើការការពាររបស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ អាចបំផុសឱ្យឃើញនូវភាពត្រឹមត្រូវយុត្តិធម៌ ក្នុងចំណោមផលិតករ នោះវានឹងធានាឱ្យមាននូវនិរន្តភាពនៃទីផ្សារ ពីព្រោះផលិតករទទួលបាននូវការតបស្នងចំពោះការខំប្រឹងរបស់ពួកគេ។ ប្រសិនបើពុំមានវត្តមាននូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (បង្កើតឱ្យមាននូការប្រកួតប្រជែងមិនស្មោះត្រង់) នោះមិនអាចបង្កើតទីផ្សារបានទេ។ ដូច្នេះនឹងមិនមាននូវការជំរុញលើកទឹកចិត្តសម្រាប់ផលិតករ គិតគូរពីគុណតម្លៃបរិស្ថាន និងសង្គម សម្រាប់ផលិតផលរបស់ពួក ដែលធ្វើឱ្យកាត់បន្ថយភាពគង់វង្ស។

[10] "Why do Geographical Indications matter to us?", European Commission, 2003, https://bit.ly/3eGD3gk, ចូលមើលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០

បំណងដែលសំខាន់មួយទៀតនៃការការពាររបស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺដើម្បីធានានូវតម្លាភាពសម្រាប់អ្នកប្រើប្រាស់។ **ឧទាហរណ៍** នៅពេលអតិថិជនបានទទួលទាននូវស្រាសំប៉ាញ ដែលបានចំណាយប្រាក់ច្រើនទៅលើផលិតផលនេះ យើងអាចធានាថាស្រានេះ ជាស្រាសំប៉ាញពិតប្រាកដ និងមិនមែនជាស្រាធម្មតាដែលយកពីកន្លែងផ្សេងៗ។ ធម្មតាដែលផលិតផលម្ហូបអាហារផលិតឡើងក្នុងប្រទេសមួយ ឆ្លងកាត់ដំណើរកែច្នៃនៅប្រទេសមួយទៀត និងវិចខ្ចប់នៅប្រទេសផ្សេងមួយទៀត។ កង្វះខាតនៃតម្លាភាពនេះហើយ គឺជួយដល់ការបង្កើតឱ្យមានជំនឿទុកចិត្តដល់អ្នកផលិតករគិតគូរឡើងវិញអំពីការផ្តល់នូវតម្លាភាព តាមរយៈការបន្ថែមគុណតម្លៃលើផលិតផលកសិកម្មរបស់ខ្លួន។ កាលដែលអាចកំណត់បាននូវប្រភពដើម និងតម្លាភាពគឺជាលក្ខខណ្ឌដ៏ចម្បងសម្រាប់ផលិតផលការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ អាចបង្កើនផលិតកម្ម និងជួយបង្កើតការងារដល់ប្រជាជនក្នុងតំបន់។ កំណើនផលិតកម្ម និងការបង្កើតការងារដល់ប្រជាជនក្នុងតំបន់ ពឹងផ្អែកលើស្តង់ដានៃការគ្រប់គ្រងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ នៅក្នុងសហភាពអឺរ៉ុបម៉ាកសម្គាល់ភូមិសាស្ត្រ ត្រូវបានបែងចែកជាបួនផ្នែក គឺការការពារឈ្មោះនៃទីតាំងប្រភពដើម (Protected Designation of Origin “PDO”) ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (Protected Geographical Indication “PGI”) ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញលើប្រភេទស្រា (Geographical Indication of Spirit drinks and aromatized wines “GI”) និងការធានាភាពពិសេសនៃប្រពៃណី (Traditional Specialty Guaranteed “TSG”)។ ការការពារឈ្មោះនៃទីតាំងប្រភពដើម គឺទាមទារឱ្យដំណើរការផលិតកម្ម និងកែច្នៃទាំងអស់ត្រូវតែកើតឡើងនៅតំបន់ដែលបានទទួលបានការការពារ ចំណែកឯការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺទាមទារឱ្យមានតែដំណាក់ការនៃខ្សែចង្វាក់ផលិតកម្មមានតែមួយគត់ដែលកើតឡើងនៅក្នុងតំបន់ដែលជាប់ទាក់ទងនោះ។ ដូច្នេះ ការការពារឈ្មោះនៃទីតាំងប្រភពដើមនឹងអាចបង្កើតការងារដល់ប្រជាជនក្នុងតំបន់ នៅក្នុងវិស័យណាមួយច្រើនជាងការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ កំណើនផលិតកម្ម និងការបង្កើតការងារ ក៏ត្រូវពឹងផ្អែកលើប្រភេទនៃផលិតផល ដែលផលិតផលនោះតម្រូវឱ្យមានកម្លាំងពលកម្មច្រើន នឹងបង្កើតការងារដល់ប្រជាជនច្រើនដូចគ្នា។

លើសពីនេះ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញជាប់ពាក់ព័ន្ធខ្លាំងជាមួយនឹងការការពារចំណេះដឹងប្រពៃណី។ ចំណេះដឹងប្រពៃណី ជាផ្នែកសង្គមមួយដែលមានសារៈសំខាន់នៃការអភិវឌ្ឍតំបន់ជនបទដោយចីរភាព។ **ឧទាហរណ៍** កសិករជាច្រើនបង្កើតការដាំដុះដំឡូង Jersey Royal[11] ដែលមានការការពារ ដោយឈ្មោះសម្គាល់ការការពារឈ្មោះនៃទីតាំងប្រភពដើម(PDO) ប្រើប្រាស់សារាយសមុទ្រប្រមូលចេញពីតំបន់ឆ្នេរ Jersey ប្រទេស

[11] ព័ត៌មានបន្ថែមទាក់ទងនឹងផលិតផលដំឡូង Jersey Royal នៅក្នុងគេហទំព័រ៖ https://bit.ly/2ZhXSsh, ចូលមើលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០

អង់គ្លេសមកធ្វើជាជី។ ការអនុវត្តជាទម្លាប់នេះគឺមានតាំងពីសតវត្សទី១២។ ការងារភាគច្រើន គឺធ្វើឡើងដោយដៃ ដោយសារភាពចោតនៃចម្រាលភ្នំ។ ដូច្នេះដំឡូង Jersey Royal ដែលមានការការពារ ដោយឈ្មោះសម្គាល់ការ ការពារឈ្មោះនៃទីតាំងប្រភពដើម(PDO) បានចូលរួមដល់ការរក្សាបានការអភិវឌ្ឍតំបន់ជនបទដោយចីរភាព តាមរយៈ ការរក្សាឱ្យបាននូវចំណេះដឹងប្រពៃណី និងការអនុវត្តនៃការដាំដុះឱ្យនៅគង់វង្ស(ការប្រើប្រាស់ជីធម្មជាតិ)។

### ខ.៣. ផ្នែកបរិស្ថាន

និរន្តភាពនៃតំបន់ជនបទអាចសម្រេចបានតាមរយៈការរក្សានូវប្រព័ន្ធជីវចម្រុះ ទេសភាព និងចំណេះដឹង ប្រពៃណីដែលអាចផ្សព្វផ្សាយបានតាមរយៈការការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ពាក្យថា"ជីវចម្រុះ" សំដៅ លើបរិមាណ និងភាពចម្រុះគ្នានៃភាវរស់នានា ដែលត្រូវបានរកឃើញក្នុងតំបន់ជាក់លាក់មួយ ឬជុំវិញពិភពលោក និងរវាងពពួកសត្វ និងប្រព័ន្ធអេកូឡូស៊ី។ ការការពារនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺត្រូវបានចាត់ទុកថាដើម្បីធ្វើ ការផ្សព្វផ្សាយអំពីការអភិវឌ្ឍនៃការទទួលស្គាល់នូវផលិតផលកសិកម្ម។ ការធ្វើពិពិធកម្មនៃផលិតផលកសិកម្ម អាចធ្វើមានតុល្យភាពរវាងការផ្គត់ផ្គង់ និងតម្រូវការដែលមានន័យថា គឺមានផលិតផលប្រហាក់ប្រហែល និងមាន ផលិតផលកាន់តែខុសគ្នាក្នុងទីផ្សារ។ បើសិនជាផលិតផលមួយមានភាពខុសគ្នាខ្លាំង នោះនឹងមានការប្រកួត ប្រជែងតិចព្រោះដោយសារមានផលិតផលតិចតួចដែលអាចយកមកជំនួសបាន។ ការធ្វើពិពិធកម្មផលិតផល ត្រូវ បានមើលឃើញថាមានអត្ថប្រយោជន៍ទៅដល់ប្រព័ន្ធអេកូឡូស៊ី និងសេដ្ឋកិច្ច។

ទន្ទឹមនឹងនេះ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអាចដើរតួនាទីជាឧបករណ៍សម្រាប់ជំរុញឱ្យមានការធ្វើ កសិកម្មប្រកបដោយចីរភាព តាមរយៈការកំណត់នូវបរិមាណ និងទំហំនៃផលិតកម្ម និងវិធីសាស្ត្រផលិតកម្ម។ ទោះជាយ៉ាងណាក៏ដោយ ករណីដែលអាចកើតឡើង ឬមិនកើតឡើង គឺអាស្រ័យលើស្តង់ដារបស់ម៉ាកសម្គាល់ ភូមិសាស្ត្រទំនិញ ដែលអនុវត្តដោយប្រទេសនីមួយៗ។ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មានគោលបំណងធានានូវ ការប្រកួតប្រជែងទីផ្សារ ដោយត្រឹមត្រូវសម្រាប់ផលិតកម្មនៃទំនិញមានគុណភាពប្រៀបជាមួយទីផ្សារ សម្រាប់តែ ទំនិញបរិមាណ។ ប្រសិនបើម៉ាកសម្គាល់ភូមិសាស្ត្រ និងស្លាកសញ្ញាសម្គាល់ផ្សេងទៀត មិនត្រូវបានការពារ នោះ នឹងគ្មានការជំរុញលើកទឹកចិត្តដល់ផលិតករឡើយ។ នេះត្រូវបានគេមើលឃើញនៅក្នុងឧស្សាហកម្មកាហ្វេដែលជា ឧទាហរណ៍។ ការផលិតកាហ្វេដ៏ច្រើនលើសលប់នាំឱ្យមានការធ្លាក់តម្លៃជាសកល ហើយមានតែកាហ្វេដែលមាន គុណភាពខ្ពស់ និងមានទីតាំងប្រភពច្បាស់លាស់អាចទទួលបាននូវតម្លៃខ្ពស់។ នេះសបញ្ជាក់ឱ្យឃើញអំពីស្លាក សញ្ញាបង្ហាញពីគុណតម្លៃ សម្រាប់សម្គាល់ទីតាំងភូមិសាស្ត្រនៃប្រភព ដែលជំរុញឱ្យមាននូវគុណភាពច្រើនជាង បរិមាណ។ ការផ្តោតសំខាន់លើគុណភាពច្រើនជាងបរិមាណ មានអត្ថប្រយោជន៍ដល់បរិស្ថានដូចជាផ្តោតសំខាន់ លើការផលិតដែលមានគុណភាព (ផលិតនិងកែច្នៃសមស្របទៅនឹងបរិស្ថាន)។ អ្នកប្រើប្រាស់នឹងរីករាយសាទរ ជាមួយនឹងការបន្ថែមគុណតម្លៃ ហើយឱ្យតម្លៃកាន់តែខ្ពស់។

## កថាខណ្ឌទី២៖ សញ្ញាណទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ដើម្បីឱ្យ ការសិក្សាទៅលើ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកាន់តែច្បាស់លាស់ និងស៊ីជម្រៅ យើងត្រូវយល់អំពីការផ្តល់និយមន័យផ្សេងៗគ្នា ហើយប្រភេទនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងលក្ខណៈខុសគ្នានឹងម៉ាកដទៃទៀត ក៏ជាចំណុចសំខាន់ដែលយើងត្រូវសិក្សាឱ្យច្បាស់ផងដែរ។

### ក. និយមន័យ និងប្រភេទនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

#### ក.១. និយមន័យ

យោងទៅតាមកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា(TRIPS Agreement) ឆ្នាំ ១៩៩៤ បានកំណត់នូវនិយមន័យ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញថា "ជាការចង្អុលបង្ហាញដែលសម្គាល់ទំនិញមួយថា មានប្រភពក្នុងដែនដីនៃសមាជិកណាមួយ ឬតំបន់ ឬទីតាំងណាមួយនៃដែនដីនេះ ដែលមានគុណភាពជាក់លាក់ កិត្តិស័ព្ទ ឬចរិកលក្ខណៈផ្សេងទៀតនៃទំនិញ ដែលកើតចេញជាពិសេសពីប្រភពភូមិសាស្ត្រនោះ"[12]។

ចំណែកឯ ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ចេញដោយក្រសួងពាណិជ្ជកម្ម ក៏បានកំណត់នូវនិយមន័យ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "សំដៅដល់ឈ្មោះ សញ្ញាសម្គាល់ និង/ឬ រូបភាពផ្សេងៗទៀត ដែលមានលក្ខណៈញែកដាច់ដែលជាឈ្មោះ ឬតំណាងឱ្យប្រភពដើមនៃតំបន់ភូមិសាស្ត្រមួយ ហើយឈ្មោះសញ្ញាសម្គាល់ និង/ឬ រូបភាពនោះសម្រាប់កំណត់អត្តសញ្ញាណទំនិញ មានប្រភពក្នុងភូមិសាស្ត្រនោះ ដែលបានផ្តល់ជាមូលដ្ឋានគ្រឹះដល់គុណភាព កិត្តិនាម ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញដែលកើតចេញពីតំបន់ភូមិសាស្ត្រនោះ"[13]។

ផ្អែកតាមនិយមន័យខាងលើនេះ យើងអាចសង្កេតឃើញថា ជាទូទៅផលិតផលមួយត្រូវចាត់ទុកជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបាន លុះត្រា តែផលិតផលនោះត្រូវបានផលិតនៅក្នុងតំបន់នោះ ហើយគុណភាព និងកេរ្តិ៍ឈ្មោះរបស់ផលិតផលត្រូវតែផ្សាភ្ជាប់ជាចាំបាច់ទៅនឹងតំបន់ដោយគេអាចដឹងអំពីទីកន្លែងផលិតនៃផលិតផលណាមួយ ដោយគ្រាន់តែឮអំពីឈ្មោះរបស់ផលិតផលនោះ។ **ឧទាហរណ៍៖** ម្រេចកំពត (Kampot Pepper) ស្ករត្នោតកំពង់ស្ពឺ (Kampong Speu Palm Sugar) ស្រាទំពាំងបាយជូរ Bordeaux ជាអាទិ៍។

ដើម្បីទទួលស្គាល់ថាផលិតផល ឬទំនិញណាមួយ ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺចាំបាច់ត្រូវតែបំពេញនូវលក្ខខណ្ឌចំបងៗចំនួនបី៖ ទី១-ទាក់ទងទៅនឹងផលិតផល ទី២-ផលិតផលត្រូវតែផលិតចេញពីតំបន់កំណត់នោះ និងទី៣-ផលិតផលត្រូវតែមានគុណភាព កិត្តិនាម និងចរិតលក្ខណៈផ្សេងទៀត ដែលមានទំនាក់ទំនងយ៉ាងច្បាស់ទៅនឹងប្រភពភូមិសាស្ត្រនៃផលិតផល ឬទំនិញ។

[12] មាត្រា២២ ចំណុចទី១ នៃកិច្ចព្រៀមស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS Agreement)

[13] មាត្រា៤ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ២០១៤

សរុបជារួមមក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺសំដៅការពារដល់ផលិតផលទាំងឡាយណាដែលបានផលិតនៅក្នុងតំបន់មួយដែលអំណោយផលដល់ផលិតផល រួមទាំងបច្ចេកទេសពិសេសរបស់ផលិតករនៅក្នុងតំបន់នោះក្នុងការផលិតចេញនូវផលិតផលមួយ ដែលមានគុណភាពពិសេសជាងផលិតផលដូចគ្នាដែលនាំមកពីតំបន់ដទៃ ហើយត្រូវបានអចិតិជនភាគច្រើនទទួលស្គាល់លើគុណភាពនោះនៅលើទីផ្សារ។

## ក.២. ប្រភេទនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ជាធម្មតា ផលិតផលកសិកម្មច្រើនតែបានផ្សាភ្ជាប់ជាពិសេសទៅនឹងតំបន់ដែលបានផលិតចេញ ដោយសារតែកត្តាអាកាសធាតុ កត្តាទឹក និងដី ក៏ដូចជាបច្ចេកទេសនៃការដាំដុះ និងការផលិតរបស់ផលិតករជាដើម។ ដូច្នេះហើយទើបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញភាគច្រើន គឺត្រូវបានការពារទៅលើផលិតផលកសិកម្ម ក៏ដូចជាផលិតផលកសិផល ចំណីអាហារ ស្រា និងភេសជ្ជៈ ជាដើម។

ទោះបីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញច្រើនតែការពារលើផលិតផលកសិកម្ម ផលិតកម្មចំណីអាហារ ស្រា និងភេសជ្ជៈ ក៏ដោយ ក៏ព្រំដែននៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មិនមែនកំណត់ត្រឹមផលិតផលកសិកម្មនោះឡើយ។ តាមរយៈគោលការណ៍របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក៏ត្រូវបានការពារទៅលើគុណភាពនៃផលិតផល តាមរយៈកត្តាមនុស្សនៅក្នុងតំបន់ផងដែរ ដូចជាការផលិតតាមរយៈការប្រើប្រាស់បច្ចេកទេស និងចំណេះធ្វើតាមបែបប្រពៃណីជាដើម។ នៅក្នុងនេះ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺត្រូវបានការពារទៅលើផលិតផលជាច្រើនផ្សេងទៀតដូចជា ផលិតផលសិប្បកម្ម និងផលិតផលហត្ថកម្មដែលបានផលិតចេញពីវត្ថុធាតុដើមដែលនៅក្នុងតំបន់ និងដែលត្រូវបានឆ្លុះបញ្ចាំងអំពីចំណេះធ្វើតាមបែបប្រពៃណីរបស់ប្រជាជននៅក្នុងតំបន់នោះផងដែរ[14]។ **ឧទាហរណ៍៖** ផលិតផលគ្រីស្តាល់ Bohemia (សាធារណៈរដ្ឋឆែក) ផលិតផលកាំបិត Solingen (ប្រទេសអាឡឺម៉ង់) នាឡិកាដៃស្វីស (ប្រទេសស្វីស) ជាដើម។

ជាពិសេស បើផ្អែកតាមច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៃព្រះរាជាណាចក្រកម្ពុជា ប្រភេទទំនិញដែលអាចត្រូវបានការពារដោយច្បាប់នេះ គឺទំនិញកសិផល ទំនិញកសិចំណីអាហារ ទំនិញសិប្បកម្ម ឬទំនិញផ្សេងៗទៀតដែលផលិតក្នុងតំបន់ភូមិសាស្ត្រ ឬកែច្នៃស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ[15]។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាមាននូវផលិតផលក្នុងស្រុកដែលត្រូវបានការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរួមមាន៖ អំបិលធម្មជាតិកំពត ធូរេនកំពត អង្ករថ្មគោល ក្រូចពោធិ៍សាត់បាត់ដំបង ពងទាកូនស្រែននោងតាកែវ ស្ករត្នោតកំពង់ស្ពឺ ស្បូត្រង្គំស្រុកបន្ទាយមានជ័យ[16] និងផលិតផលមួយចំនួនទៀត។ ចំណែកនូវផលិតផលរបស់កម្ពុជា ដែលបានចុះបញ្ជីការពារដោយម៉ាកសម្គាល់

[14] *"World Intellectual Property Indicators 2017"*, WIPO, 2017, p.202-203, ចូលមើល ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០

[15] មាត្រា៣ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ២០១៤

[16] ញ៉ុង ហេង, *"ផលិតផល ៦មុខទៀត គ្រោងចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅEU"*, គេហទំព័រថ្មីៗ (ThmeyThmey), ចុះផ្សាយឆ្នាំ២០១៦, https://bit.ly/2zyqRPJ, ចូលមើល, ថ្ងៃទី២៩ ខែមិថុនា ២០២០

ភូមិសាស្ត្រទំនិញលក្ខណៈអន្តរជាតិមានដូចជា ម្រេចកំពត ស្ករត្នោតកំពង់ស្ពឺ និងក្រូចថ្លុងកោះទ្រង់[17] ដែលបានចុះបញ្ជីការពារនៅសហភាពអឺរ៉ុប និងប្រទេសបារាំង។

### ខ. លក្ខណៈខុសគ្នានឹងម៉ាកដទៃទៀត

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ពាណិជ្ជនាម ម៉ាកសមូហភាព និងម៉ាកផ្សេងៗទៀត គឺសុទ្ធសឹងតែជាឈ្មោះ ឬសញ្ញាសម្គាល់សម្រាប់កំណត់សម្គាល់លើទំនិញដែលបានផលិត ហើយការដាក់ឈ្មោះ ឬសញ្ញាសម្គាល់ឱ្យផលិតផលណាមួយ គឺក្នុងគោលបំណងចង់ផ្តល់នូវភាពងាយស្រួលដល់អ្នកប្រើប្រាស់ ក្នុងការញែកឱ្យដាច់ចំពោះផលិតផលរបស់សហគ្រាសណាមួយ។ ជាពិសេស ម៉ាកទាំងអស់នេះ សុទ្ធតែស្ថិតនៅក្រោមការគ្រប់គ្រងដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម និងត្រូវទទួលបាននូវការការពារដោយបទប្បញ្ញត្តិជាតិ និងអន្តរជាតិដូចគ្នាទៀតផង។ ប៉ុន្តែ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងប្រភេទម៉ាកដទៃទៀត ក៏មាននូវលក្ខណៈខុសគ្នាមួយចំនួនផងដែរ។

#### ខ.១. ពាណិជ្ជនាម

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងពាណិជ្ជនាម គឺជាសញ្ញាខុសគ្នា ដែលសម្រាប់សម្គាល់នូវទំនិញ ឬសេវានៅក្នុងទីផ្សារ។ ម៉ាកទាំងពីរនេះ បង្ហាញឱ្យឃើញនូវព័ត៌មានអំពីប្រភពនៃទំនិញ ឬសេវា និងអាចជួយឱ្យអ្នកប្រើប្រាស់យល់ដឹងបន្ថែមពីគុណភាពជាក់លាក់ដែលភ្ជាប់ជាមួយនឹងទំនិញ ឬសេវា។

ពាណិជ្ជនាម (Trademark) គឺជាឈ្មោះ ឬសញ្ញាសម្គាល់ ឬជាឈ្មោះ និងសញ្ញាសម្គាល់ សម្រាប់បញ្ជាក់និងសម្គាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ[18]។ ផ្អែកតាមនិយមន័យនេះ ពាណិជ្ជនាម គឺផ្តល់នូវព័ត៌មានដល់អ្នកប្រើប្រាស់អំពីប្រភពនៃទំនិញ ឬសេវា ហើយក៏បានកំណត់អត្តសញ្ញាណនូវទំនិញ ឬសេវា ដោយមានបញ្ជាក់យ៉ាងច្បាស់នូវសហគ្រាសផលិត។ ជាក់ស្តែង ពាណិជ្ជនាម គឺជាកម្មសិទ្ធិឯកជនរបស់ម្ចាស់ម៉ាក ដែលមានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់[19] ព្រមទាំងអាចផ្ទេរបន្តនូវកម្មសិទ្ធិ[20] ហើយម្ចាស់ម៉ាក គឺមានគោលដៅស្វែងរកប្រាក់ចំណេញ។ លើសពីនេះ ពាណិជ្ជនាមនេះ គឺមានរយៈពេលនៃការការពារ ចំនួន១០ឆ្នាំ និងអាចពន្យារបាន សម្រាប់រយៈពេល ១០ឆ្នាំជាបន្តបន្ទាប់ ក្នុងលក្ខខណ្ឌដែលម្ចាស់ដើមបង់អាករចុះបញ្ជីជាថ្មីតាមការកំណត់ [21] ក៏ប៉ុន្តែ

---

[17] វណ្ណ សុគន្ធា, *"កម្ពុជាជំរុញឱ្យពាណិជ្ជករបរទេសចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដើម្បីទទួលការគាំពារតាមផ្លូវច្បាប់"*, គេហទំព័រ RFI, ចុះផ្សាយនាខែមេសា ឆ្នាំ២០១៩, https://bit.ly/3gDScke, ចូលមើលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០

[18] មាត្រា២ ចំណុច គ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[19] មាត្រា៣ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[20] មាត្រា៤៨ ដល់ មាត្រា ៥២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[21] មាត្រា១២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

ប្រសិនបើម៉ាកនេះ មិនបានប្រើប្រាស់សោះក្នុងរយៈពេល ៥ឆ្នាំ នោះពាណិជ្ជនាមដែលបានចុះបញ្ជី ត្រូវបានលុបចេញពីបញ្ជី[22]។

ផ្ទុយទៅវិញ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺសំដៅដល់ឈ្មោះ សញ្ញាសម្គាល់ និង/ឬរូបភាពផ្សេងៗទៀតដែលមានលក្ខណៈញែកដាច់ដែលជាឈ្មោះ ឬតំណាងឱ្យប្រភពដើមនៃតំបន់ភូមិសាស្ត្រមួយ ហើយឈ្មោះសញ្ញាសម្គាល់ និង/ឬ រូបភាពនោះសម្រាប់កំណត់អត្តសញ្ញាណទំនិញ មានប្រភពក្នុងភូមិសាស្ត្រនោះ ដែលបានផ្តល់ជាមូលដ្ឋានគ្រឹះដល់គុណភាព កិត្តិនាម ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញដែលកើតចេញពីតំបន់ភូមិសាស្ត្រនោះ។ បានសេចក្តីថា ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺផ្តោតសំខាន់ទៅលើប្រភពភូមិសាស្ត្រនៃការ ផលិតទំនិញដែលមានលក្ខណៈខុសប្លែកពីពាណិជ្ជនាម ដោយផ្តោតសំខាន់ទៅលើសហគ្រាសដែលផលិតទំនិញ ឬសេវា។ លើសពីនេះ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺជាកម្មសិទ្ធិសមូហភាពមានដែនកំណត់ (លើតំបន់ណាមួយ) ជាសិទ្ធិរបស់សមាគមក្នុងតំបន់ណាមួយជាក់លាក់ ដោយមាននូវគោលបំណងមិនធ្វើពាណិជ្ជកម្ម[23] (មិនស្វែងរកប្រាក់ចំណេញ) ហើយសិទ្ធិប្រើប្រាស់នៃម៉ាកនេះ មិនអាចផ្ទេរបន្តបានឡើយ[24]។ ជាពិសេស ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺមានរយៈពេលនៃការការពារ មិនកំណត់រយៈពេលឡើយ[25] ហើយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មិនអាចផ្តល់អាជ្ញាបណ្ណដល់បុគ្គលណាម្នាក់ ដែលនៅខាងក្រៅពីកន្លែង ឬមិនស្ថិតនៅក្រោមកម្មសិទ្ធិរបស់សមាគមនៃតំបន់ណាមួយដែលទទួលបានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច[26] ដែលខុសពីពាណិជ្ជនាម គឺអាចផ្តល់អាជ្ញាបណ្ណទៅឱ្យបុគ្គលដទៃទៀតបាន។

សរុបជារួមមក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងពាណិជ្ជនាម គឺមានលក្ខណៈខុសគ្នាមួយចំនួន ដូចជា ទី១-ផ្តោតសំខាន់ទៅលើប្រភពភូមិសាស្ត្រទំនិញ/សហគ្រាសផលិត ទី២-សិទ្ធិក្នុងការប្រើប្រាស់ ទី៣-រយៈពេលនៃការការពារ និង ទី៤-ការផ្តល់អាជ្ញាបណ្ណចំពោះម៉ាក។

### ខ.២. ម៉ាកសមូហភាព

ម៉ាកសមូហភាព (Collective marks) គឺជាសញ្ញាដែលមើលឃើញ សំដៅប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជី ហើយអាចសម្គាល់នូវប្រភពដើមនៃទំនិញ ឬសេវា ឬសំគាល់នូវចរិតលក្ខណៈរួមដទៃទៀត គិតទាំងគុណភាពនៃ

---

[22] មាត្រា១៥ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[23] មាត្រា៧ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឆ្នាំ២០១៤

[24] មាត្រា២២ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឆ្នាំ២០១៤

[25] មាត្រា២៤ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឆ្នាំ២០១៤

[26] “What is the difference between a geographical indication and a trademark?”, WIPO, https://bit.ly/2Mt90MB,ចូលមើលថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០

ទំនិញ ឬសេវា របស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះ ក្រោមការគ្រប់គ្រងរបស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី[27]។

ផ្អែកតាមនិយមន័យនេះ ម៉ាកសមូហភាព និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺសុទ្ធតែមានលក្ខណៈដូចគ្នាច្រើន ប៉ុន្តែក៏មាននូវលក្ខណៈខុសគ្នាមួយចំនួនផងដែរ។ ជាក់ស្តែងម៉ាកសមូហភាព គឺស្ថិតនៅក្រោមកម្មសិទ្ធិសមូហភាព បានន័យថា ម្ចាស់កម្មសិទ្ធិលើម៉ាកមានចំនួនច្រើននាក់ ព្រមទាំងអាចផ្ទេរនូវសិទ្ធិកម្មសិទ្ធិបាន និងមានសិទ្ធិក្នុងការប្រើប្រាស់ផ្តាច់មុខ ហើយម្ចាស់ម៉ាកនេះ គឺមានគោលដៅស្វែងរកប្រាក់ចំណេញ ដោយខុសពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺមានសិទ្ធិប្រើប្រាស់ក្នុងទំហំដែលបានកំណត់ (ក្នុងតំបន់ណាមួយជាក់លាក់) ស្ថិតនៅក្នុងកម្មសិទ្ធិសមូហភាព (សមាគម) ប៉ុន្តែមិនស្វែងរកប្រាក់ចំណេញឡើយ។ ចំណែករយៈពេលនៃការការពារ គឺដូចគ្នាទៅនឹងចំណុចខុសគ្នារវាង ពាណិជ្ជនាម ជាមួយនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែរ។

### ខ.៣. សញ្ញាសម្គាល់ប្រភពទំនិញ

សញ្ញាសម្គាល់ប្រភពទំនិញ (Indication of Source) សំដៅដល់ពាក្យ ឬសញ្ញា ដែលប្រើដើម្បីបង្ហាញថាទំនិញ ឬសេវានោះមានប្រភពនៅក្នុងប្រទេស តំបន់ និងកន្លែងជាក់លាក់ណាមួយ ដែលបានផលិតទំនិញនោះ[28]។ ផ្អែកតាមនិយមន័យនេះ សញ្ញាសម្គាល់ប្រភពទំនិញ គឺមានលក្ខណៈខុសគ្នាពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយសារការបង្ហាញប្រភពទំនិញ គឺមិនបានបង្ហាញពីវត្តមាននូវគុណភាព កិត្តនាម ឬចរិតលក្ខណៈផ្សេងៗទៀតនៃផលិតផលឡើយ ហើយដែលជាចំណុចសំខាន់ៗទាំងនេះ គឺប្រើសម្រាប់ក្នុងការបញ្ជាក់លើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។[29] សញ្ញាសម្គាល់ប្រភពទំនិញ តែងតែធ្វើនិទ្ទេសនៅលើផលិតផល ដូចជាការដាក់ពាក្យថាផលិតនៅ (Made in…) ផលិតផលរបស់ (Product of…) ជាដើម។ ជាក់ស្តែងផលិតផលរបស់ប្រទេសកម្ពុជា គឺតែងតែដាក់ពាក្យថាផលិតផលរបស់កម្ពុជា ឬផលិតនៅកម្ពុជា (Product of Cambodia or Made in Cambodia)។

### ខ.៤. ឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញ

ឈ្មោះសម្គាល់ទីតាំងនៃប្រភពដើមទំនិញ (Appellation of Origin) គឺជាប្រភេទពិសេសមួយនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ ពាក្យនេះ ត្រូវបានប្រើនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស (Paris Convention) ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម និងត្រូវបានកំណត់និយមន័យនៅក្នុងកិច្ចព្រមព្រៀងទីក្រុងលីសប៊ន (Lisbon

[27] មាត្រា២ ចំណុចខ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[28] មាត្រា១០ នៃអនុសញ្ញាទីក្រុងប៉ារីស (Paris Convention) ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មឆ្នាំ១៨៨៣ និងមាត្រា១ នៃកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ(Madrid Agreement) ស្តីពីការបង្ក្រាបនៃការក្លែងបន្លំ ឬការបោកបញ្ឆោតនៃសញ្ញាសម្គាល់ប្រភពទំនិញឆ្នាំ១៨៩១

[29] *"What is the difference between a geographical indication and an indication of source?"*, WIPO, https://bit.ly/2Mt90MB, ចូលមើលថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០

Agreement) ស្តីពីការការពារឈ្មោះសម្គាល់ទីតាំងនៃប្រភពដើមទំនិញ និងការចុះបញ្ជីជាលក្ខណៈអន្តរជាតិ។ ឈ្មោះសម្គាល់ទីតាំងនៃប្រភពដើមទំនិញ "សំដៅដល់ភូមិសាស្ត្រនៃប្រទេសមួយ ឬតំបន់ណាមួយ ឬទីតាំងណាមួយ ដែលបានធ្វើឱ្យផលិតផលមួយ បានកើតឡើងនៅទីនោះ ទាំងគុណភាព ឬចរិតលក្ខណៈពិសេសផ្សេងទៀត ដែលអាស្រ័យទៅលើលក្ខណៈពិសេសនៃបរិស្ថានភូមិសាស្ត្រ ដែលរួមបញ្ចូលទាំងកត្តាធម្មជាតិ និងកត្តាមនុស្សផងដែរ"[30]។

ផ្អែកតាមនិយមន័យខាងលើនេះ ឈ្មោះសម្គាល់ទីតាំងនៃប្រភពដើមទំនិញ និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ទាមទារឱ្យមានទំនាក់ទំនងរវាងគុណភាពនៃផលិតផលដែលផលិត និងទីតាំងភូមិសាស្ត្រដើមនៃផលិតផល។ បន្ថែមទៀត ទាំងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងឈ្មោះសម្គាល់ទីតាំងនៃប្រភពដើមទំនិញ បានផ្តល់នូវព័ត៌មានសំខាន់ៗជូនអ្នកប្រើប្រាស់ អំពីប្រភពភូមិសាស្ត្រដើមនៃផលិតផល ឬគុណភាព ឬកិត្តនាម ឬចរិតលក្ខណៈផ្សេងទៀតនៃផលិតផល ដែលភ្ជាប់ទៅនឹងទីកន្លែងដើមរបស់ផលិតផល។ ប៉ុន្តែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងឈ្មោះសម្គាល់ទីតាំងនៃប្រភពដើមទំនិញ គឺលក្ខណៈខុសគ្នាជាមូលដ្ឋានចំនួនពីរចំណុចគឺ ទី១-ទីតាំងភូមិសាស្ត្រនៃផលិតផល និងទី២-គុណភាព ឬចរិតលក្ខណៈផ្សេងៗនៃផលិតផល។ ទាក់ទងនឹងទីតាំងភូមិសាស្ត្រនៃផលិតផល គឺឈ្មោះសម្គាល់ទីតាំងនៃប្រភពដើមទំនិញ(AO) ត្រូវតែលម្អិតជាងក្នុងករណីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ហើយទាក់ទងនឹងគុណភាព ឬចរិតលក្ខណៈនៃទំនិញដែលការពារដោយឈ្មោះសម្គាល់ទីតាំងនៃប្រភពដើមទំនិញ ត្រូវតែមានលក្ខណៈទាំងស្រុង ឬចាំបាច់ចេញពីភូមិសាស្ត្រដើម[31]។

បានសេចក្តីថា គ្រប់វត្ថុធាតុដើមទាំងអស់ដែលយកមកផលិត ចេញជាផលិតផល ត្រូវតែមានប្រភពចេញពីក្នុងតំបន់នោះ ហើយដំណើរការនៃការផលិត ត្រូវតែកើតឡើងនៅក្នុងតំបន់នោះ ព្រមទាំងត្រូវភ្ជាប់នូវលក្ខណៈពិសេសនៃបរិស្ថានភូមិសាស្ត្រក្នុងតំបន់ ដូចជា កត្តាធម្មជាតិ និងកត្តាមនុស្សផងដែរ។ ផ្ទុយទៅវិញ ក្នុងករណីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ លក្ខណៈវិនិច្ឆ័យតែមួយដែលបង្កើតឱ្យមានប្រភពភូមិសាស្ត្រអាចជាគុណភាព ឬកិត្តិនាម ឬចរិតលក្ខណៈផ្សេងៗទៀតនៃទំនិញ គឺគ្រប់គ្រាន់ហើយ[32]។ **ឧទាហរណ៍៖** ពាក់ព័ន្ធនឹងឈ្មោះសម្គាល់ទីតាំងនៃប្រភពដើមទំនិញ(Appellation of origin) មានដូចជា ផលិតផល COMTÉ CHEESE[33] (ប្រទេសបារាំង), ផលិតផលកាហ្វេកូឡុំប៊ី ឬCafé de Colombia[34] (ប្រទេសកូឡុំប៊ី) ជាដើម។

---

[30] មាត្រា២ នៃកិច្ចព្រមព្រៀងទីក្រុងលីសបិន (Lisbon Agreement) ស្តីពីការការពារឈ្មោះសម្គាល់ទីតាំងនៃប្រភពដើម និងការចុះបញ្ជីលក្ខណៈអន្តរជាតិឆ្នាំ១៩៥៨

[31] *"What is the difference between a geographical indication and an appellation of origin?"*, WIPO, https://bit.ly/2Mt90MB, ចូលមើលថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០

[32] "Geographical Indications: An Indications", WIPO, 2017, p14-15, ចូលមើលថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០

[33] Myrabella, "COMTE", Cheese.com, https://bit.ly/3dHCcvt, ចូលមើលថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០

[34] "Colombian Coffee", Buencafe.com, 2018, https://bit.ly/3h2BoDF, ចូលមើលថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២០

## ផ្នែកទី២៖ ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងបរិបទជាតិ និងអន្តរជាតិ

ក្រោយពីបានសិក្សា ពាក់ព័ន្ធនឹងសញ្ញាណទូទៅនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរួចមក ចំណុចសំខាន់ដែលត្រូវធ្វើការសិក្សាបន្តទៀត គឺទាក់ទងនឹងការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញទាំងក្នុងបរិបទជាតិ និងអន្តរជាតិ។

### កថាខណ្ឌទី១៖ បរិបទជាតិ

ក្នុងបរិបទនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ បទដ្ឋានគតិយុត្តដែលសម្រាប់ការការពារលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ អាចមាននូវបទដ្ឋានគតិយុត្តសំខាន់ៗ ដូចជា៖ ច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ប្រកាសស្ដីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទដ្ឋានគតិយុត្តអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័ន។

#### ក. ច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ប្រកាសស្ដីពីនីតិវិធីណែនាំការចុះបញ្ជី និងការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបានប្រកាសឱ្យប្រើដោយក្រសួងពាណិជ្ជកម្ម។ មូលហេតុនៃការបង្កើតប្រកាសមួយនេះ គឺ ទី១-ច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ បានចំណាយរយៈពេលយូរក្នុងនីតិវិធីនៃការឆ្លងច្បាប់ និងទី២-តម្រូវការចាំបាច់ក្នុងការការពារដល់ទំនិញជាតិដែលមានសក្តានុពលក្នុងការនាំចេញទៅក្រៅប្រទេស និងទំនិញទាំងនោះកំពុងប្រឈមនឹងការក្លែងបន្លំ ដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍ដល់ផលិតករ និងរដ្ឋយ៉ាងខ្លាំង ទើបក្រសួងពាណិជ្ជកម្ម សម្រេចតាក់តែងនូវប្រកាសមួយនេះ ក្នុងគោលបំណងការពារដល់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជាបណ្ដោះអាសន្ន ដើម្បីរង់ចាំនូវការអនុម័តច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រ ដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

ប្រកាសនេះរួមមាន ១៥ប្រការ ដែលបានចែងពីចំណុចសំខាន់ៗ ដើម្បីគ្រប់គ្រង និងការពារទៅលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅកម្ពុជាដូចជា សិទ្ធិដែលទទួលបានពីការចុះបញ្ជី ភារកិច្ចរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា និងលក្ខខណ្ឌនៃការស្នើសុំចុះបញ្ជី ជាអាទិ៍។ លើសពីនេះប្រកាសនេះ ក៏បានចែងទាក់ទងនឹងនីតិវិធីប្តឹងតវ៉ា នីតិវិធីនៃបណ្ដឹងជំទាស់ វិធានការបណ្ដោះអាសន្នតាមច្រកព្រំដែន ទោសបញ្ញត្តិ ជាដើម គឺត្រូវអនុវត្តតាមច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់[35]។ ក៏ប៉ុន្តែប្រកាសនេះ ត្រូវបាននិរាករណ៍សឹងតែទាំងស្រុង[36] ដោយសារតែនៅ ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបានអនុម័តប្រកាសឱ្យប្រើជាផ្លូវការ បន្ទាប់ពីការផ្ដួចផ្ដើមតាក់តែងឡើងដោយក្រសួងពាណិជ្ជកម្មតាំងពីឆ្នាំ២០០៩ មកម្ល៉េះ។ ច្បាប់នេះមានគោលបំណងការពារកម្មសិទ្ធិបញ្ញារបស់ផលិតករ ប្រតិបត្តិករ និងការពារអ្នកប្រើប្រាស់ផលិតផលដែលពាក់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ព្រមទាំងរក្សាអត្តសញ្ញាណជាតិ និងពង្រឹងចំណេះដឹង ចំណេះធ្វើតាមបែប

[35] ប្រការ១៤ នៃប្រកាសស្ដីពីនីតិវិធីណែនាំការចុះបញ្ជី និងការការពារម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ

[36] មាត្រា៤១ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ២០១៤

ប្រពៃណី និងរួមចំណែកកាត់បន្ថយភាពក្រីក្រ[37]។ ជាពិសេស ច្បាប់នេះមានគោលដៅកំណត់អំពីការគ្រប់គ្រង ការចុះបញ្ជី ការទទួលស្គាល់ និងការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា[38] ហើយច្បាប់នេះមានវិសាលភាពអនុវត្តលើការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះទំនិញកសិផល ទំនិញកសិចំណីអាហារ ទំនិញសិប្បកម្ម ឬទំនិញផ្សេងៗទៀតដែលផលិតក្នុងតំបន់ភូមិសាស្ត្រ ឬកែច្នៃស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ[39]។

លើសពីនេះ ច្បាប់នេះក៏បានកំណត់យ៉ាងច្បាស់ពីស្ថាប័នក្នុងការគ្រប់គ្រង កាន់កាប់ និងចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្រគល់សមត្ថកិច្ចជូនក្រសួងពាណិជ្ជកម្ម[40] ហើយច្បាប់នេះ ក៏រៀបចំឱ្យមានក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដើម្បីសិក្សា និងជំរុញមុខទំនិញដែលមានសក្តានុពល អាចចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដោះស្រាយបណ្តឹងតវ៉ាពីការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ[41]។

ទន្ទឹមនឹងនេះ ច្បាប់នេះបានកំណត់អំពីនីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយតម្រូវឱ្យបុគ្គលដោយមានបំណងក្នុងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដើម្បីទទួលបានការការពារតាមផ្លូវច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ នីតិវិធីនៃការចុះបញ្ជីម៉ាកនេះ អាចមានពីរប្រភេទគឺៈ នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងស្រុក និងបរទេស។ បុគ្គលដែលមានបំណងចង់ធ្វើការចុះបញ្ជីការពារ គឺត្រូវតែអនុលោមទៅតាមខ្លឹមសារនៃបទប្បញ្ញត្តិនៃច្បាប់នេះ។ ជាពិសេស ច្បាប់នេះក៏បានបញ្ញត្តិឡើងនូវចំណុចសំខាន់ៗផ្សេងទៀតដូចជា សិទ្ធិដែលទទួលបានពីការចុះបញ្ជី កិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា និងបរទេស និងវិធានការនៃការពារនៃម៉ាក ក្នុងករណីមានការរំលោភបំពានណាមួយទៅលើម្ចាស់កម្មសិទ្ធិនៃម៉ាក ជាដើម។

សរុបជារួមមក ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺបង្កើតឡើង ដើម្បីគ្រប់គ្រងទំនិញសម្គាល់ភូមិសាស្ត្រ មិនឱ្យជនណាម្នាក់រំលោភបំពាន ឬយកឈ្មោះនោះទៅប្រើប្រាស់ទាញយកផលប្រយោជន៍ណាមួយដែលគ្មានការយល់ព្រមពីផលិតករបានឡើយ។ ជាពិសេសច្បាប់នេះ ក៏បានចូលរួមចំណែកថែរក្សា ការពារនូវប្រពៃណីបុរាណរបស់ខ្មែរ ក្នុងការផលិតនូវផលិតផលណាមួយដែលមានប្រវត្តិតាំងពីបុរាណកាលមកម្ល៉េះ។

---

37 មាត្រា១ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ២០១៤

38 មាត្រា២ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ២០១៤

39 មាត្រា៣ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ២០១៤

40 មាត្រា៥ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ២០១៤

41 មាត្រា៦ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ២០១៤

### ខ. ប្រកាសស្តីពីនីតិវិធីចុះបញ្ជីនិងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

បន្ទាប់ពីច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៤ រួចមក ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា បានតាក់តែងនូវប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលប្រកាសឱ្យប្រើក្នុងឆ្នាំ២០១៦ ក្នុងគោលបំណងអនុវត្តកិច្ចការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឱ្យកាន់តែមានប្រសិទ្ធភាពជាមុនបន្ថែមទៀត។

ប្រកាសនេះ មានគោលដៅកំណត់វិធាន និងនីតិវិធីស្តីពីការគ្រប់គ្រង ការចុះបញ្ជី ការទទួលស្គាល់ និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ហើយការពារកម្មសិទ្ធិបញ្ញារបស់ផលិតករ ប្រតិបត្តិករ និងអ្នកប្រើប្រាស់ផលិតផលសម្គាល់ភូមិសាស្ត្រ ព្រមទាំងអភិរក្ស និងពង្រឹងចំណេះដឹង ចំណេះធ្វើតាមបែបប្រពៃណី និងអត្តសញ្ញាណជាតិ ជាពិសេសជួយបង្កើតការងារនៅជនបទ អភិវឌ្ឍន៍សហគមន៍ក្នុងស្រុក កាត់បន្ថយភាពក្រីក្រ និងទាក់ទាញភ្ញៀវទេសចរណ៍[42]។

### គ. ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

ក្រៅពីច្បាប់ និងប្រកាសខាងលើនេះ ច្បាប់ស្តីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលបានអនុម័តប្រកាសឱ្យប្រើជាធរមាននៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ក៏ជាបទដ្ឋានគតិយុត្តសំខាន់មួយសម្រាប់ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាក់ស្តែងត្រង់បទប្បញ្ញត្តិទាំងឡាយណាស្តីពីវិធានការបណ្តោះអាសន្ន និងវិធានការតាមមាត់ច្រកព្រំដែនដែលមានចែងក្នុងច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ[43]។ ទន្ទឹមនឹងនេះ ច្បាប់នេះ គឺមានតួនាទីការពារដល់ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញពីការរំលោភបំពានណាមួយ និងបានជួយការពារដល់ម្ចាស់ម៉ាកនេះ មុនពេលដែលមិនទាន់មាននូវការប្រកាសឱ្យប្រើជាធរមាននូវច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។

### ឃ. បទដ្ឋានគតិយុត្តអន្តរជាតិផ្សេងៗដែលកម្ពុជាបានផ្តល់សច្ចាប័ន

ដើម្បីការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងក្របខណ្ឌអន្តរជាតិ ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិមួយចំនួនផងដែរ។ ជាក់ស្តែង កម្ពុជាបានចូលជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥[44] ហើយ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំដដែល កម្ពុជាក៏ក្លាយជាសមាជិកនៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ដែលជាអនុសញ្ញាដំបូងបង្អស់ក្នុងការការពារ

---

[42] ប្រការ២ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ២០១៦

[43] មាត្រា៣២ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ២០១៤

[44] "Cambodia Contracting Information" WIPO, https://bit.ly/2Qly0aK, ចូលមើលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងក្របខណ្ឌអន្តរជាតិ។ រហូតមកដល់ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ ប្រទេសកម្ពុជា[45] បានដាក់តម្កល់លិខិតុបករណ៍នៃការចូលជាសមាជិកច្បាប់ទីក្រុងហ្សឺណែវ ស្តីពីកិច្ចព្រមព្រៀងទីក្រុងលីសបិន អំពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញ ហើយបានក្លាយជាសមាជិកពេញសិទ្ធិនាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០។ កិច្ចព្រមព្រៀងនេះ បានបង្កើតនូវប្រព័ន្ធចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិសម្រាប់ការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ហើយផលិតផលរបស់កម្ពុជា ចំនួនពីរមុខ គឺម្រេចកំពត និងស្ករត្នោតកំពង់ស្ពឺ ក៏ត្រូវបានស្ថិតនៅក្រោមការការពារនូវប្រព័ន្ធចុះបញ្ជីទីក្រុងលីសបិននេះផងដែរ។

### កថាខណ្ឌទី២៖ បរិបទអន្តរជាតិ

កាលដើមឡើយ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវបានគេការពារដោយផ្អែកតាមច្បាប់ជាតិតែមួយប៉ុណ្ណោះ ដែលអាចត្រឹមតែអនុវត្តនៅក្នុងប្រទេសណាមួយនោះ។ ម៉ាកសម្គាល់ភូមិសាស្ត្រ ចាប់ផ្តើមកាន់តែមើលឃើញ នៅពេលមួយដែលជំនួញពាណិជ្ជកម្មត្រូវបានពង្រីកនៅសតវត្សទី១៩ ដែលការការពារនៅតាមថ្នាក់ជាតិមិនមានភាពគ្រប់គ្រាន់ឡើយ ដោយសារតែផលិតផលជារឿយៗ ត្រូវបានដាក់កំណត់នូវចំនួនចេញពីប្រទេសដែលជាប្រភពដើមនៃការផលិត។ ដូច្នេះ សហប្រតិបត្តិការអន្តរជាតិ តែងតែទាមទារឱ្យមានការធានាថាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវបានទទួលការការពារជាលក្ខណៈអន្តរជាតិ និងបង្កើតឱ្យមាននូវទំនាក់ទំនងទៅវិញទៅមកទៅលើកម្រិតនៃការការពាររវាងរដ្ឋ និងរដ្ឋ។

#### ក. សន្ធិសញ្ញាអន្តរជាតិដែលជាប់ទាក់ទងនឹងការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ការរំលោភបំពានទៅលើកម្មសិទ្ធិបញ្ញា កាន់តែកើនឡើងឥតឈប់ឈរ រហូតមកដល់ឆ្នាំ១៨៨៣ ក៏មានលេចឡើងនូវឧបករណ៍អន្តរជាតិមួយ សម្រាប់ប្រើប្រាស់ជាមធ្យោបាយ ក្នុងការការពារដល់កម្មសិទ្ធិបញ្ញា គឺអនុសញ្ញាទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិបញ្ញា ហើយអនុសញ្ញានេះ មិនត្រឹមតែចែងអំពីបទប្បញ្ញត្តិការពារលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញទេ គឺបានបញ្ញត្តិឡើងនូវគ្រប់ផ្នែកទាំងអស់នៃកម្មសិទ្ធិបញ្ញា។

#### ក.១. អនុសញ្ញាទីក្រុងប៉ារីសឆ្នាំ១៨៨៣

អនុសញ្ញាទីក្រុងប៉ារីស (Paris Agreement) គឺជាកិច្ចព្រមព្រៀមពហុភាគីដំបូង ដែលរួមបញ្ចូលនូវ "សញ្ញាសម្គាល់ប្រភពទំនិញ ឬឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញ" ដែលជាគោលបំណងនៃការការពារ។ បើយោងតាមមាត្រា១ កថាខណ្ឌទី២ នៃអនុសញ្ញាទីក្រុងប៉ារីសបានចែងថា៖

"ការការពារកម្មសិទ្ធិឧស្សាហកម្មមានគោលបំណងការពារ ប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ គំនូសឧស្សាហកម្ម ពាណិជ្ជសញ្ញា សេវាសញ្ញា ពាណិជ្ជនាម សញ្ញាសម្គាល់នៃប្រភពទំនិញ ឬឈ្មោះសម្គាល់នៃទីតាំងប្រភពទំនិញ និងការទប់ទល់នឹងការប្រកួតប្រជែងមិនស្មោះត្រង់" ។

---

[45] *"Cambodia first to join the Geneva Act of WIPO"s Lisbon Agreement"*, WIPO, March 2018, https://bit.ly/3dMgiX0, ចូលមើលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

លើសពីនេះ អនុសញ្ញាទីក្រុងប៉ារីសបានកំណត់ថា ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជាកម្មសិទ្ធិបញ្ញាមួយដែលដាច់ដោយឡែក ប៉ុន្តែមិនបានចែងច្បាស់លាស់អំពីចំណុចនេះទេ។ បើផ្អែកតាមមាត្រា ១០ កថាខណ្ឌទី១ នៃអនុសញ្ញាទីក្រុងប៉ារីស បានផ្តល់នូវមធ្យោបាយដោះស្រាយមួយចំនួន ដែលជាប់ទាក់ទងនឹងការប្រើប្រាស់នូវសញ្ញាសម្គាល់នៃប្រភពទំនិញដោយខុសច្បាប់។ បានសេចក្តីថាគ្មាននូវសញ្ញាសម្គាល់នៃប្រភពទំនិញ ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញនូវទីតាំងភូមិសាស្ត្រថាតើផលិតផលនោះមាន ឬមិនមានប្រភពចេញពីទីតាំងនោះឡើយ។ បន្ថែមទៀតបើយោងតាមមាត្រា១០ នៃអនុសញ្ញាទីក្រុងប៉ារីស ក៏បានរាប់បញ្ចូលឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញយ៉ាងច្បាស់លាស់។ ទោះបីយ៉ាងណាក៏ដោយ ឈ្មោះសម្គាល់នៃទីតាំងប្រភពទំនិញត្រូវបានជំនួសដោយសញ្ញាសម្គាល់នៃប្រភពទំនិញ ពោលឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញទាំងអស់ ត្រូវបានចាត់ទុកជាសញ្ញាសម្គាល់នៃប្រភពទំនិញ។

ទន្ទឹមនឹងនេះ យោងតាមមាត្រា១១ស្ទួន នៃអនុសញ្ញានេះ ផ្តល់នូវមូលដ្ឋានសម្រាប់ការការពារសញ្ញាសម្គាល់នៃប្រភពទំនិញដែលនាំឱ្យយល់ច្រលំ ដោយរួមបញ្ចូលទាំងឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញ។ អនុសញ្ញានេះ ក៏បង្គាប់ឱ្យសមាជិកធ្វើការការពារពីការប្រកួតប្រជែងមិនស្មោះត្រង់ និងអំពើមួយចំនួនដែលស្ថិតក្នុងបញ្ជីហាមឃាត់ក្នុងការប្រព្រឹត្ត។ អនុសញ្ញាទីក្រុងប៉ារីសមិនបានចែងនូវដំណោះស្រាយផ្លូវច្បាប់ពិសេសណាមួយសម្រាប់ទប់ទល់នឹងការរំលោភបំពាននៃបទប្បញ្ញត្តិនេះឡើយ។ លើសពីនេះទៅទៀត មាត្រា១៩នៃអនុសញ្ញាទីក្រុងប៉ារីសបានអនុញ្ញាតឱ្យភាគី "បង្កើតនូវកិច្ចព្រមព្រៀងរវាងភាគីសម្រាប់ការការពារកម្មសិទ្ធិឧស្សាហកម្ម"។ ជាក់ស្តែងកិច្ចព្រមពៀងពីរដែលជាប់ទាក់ទងនឹងកំណត់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ រួមមានកិច្ចព្រមព្រៀមទីក្រុងម៉ាឌ្រីដឆ្នាំ១៨៩១ (Madrid Agreement) និងកិច្ចព្រមព្រៀមទីក្រុងលីសប៊ន ឆ្នាំ១៩៥៨ (Lisbon Agreement)។

### ក.២. កិច្ចព្រមព្រៀមទីក្រុងម៉ាឌ្រីដឆ្នាំ១៨៩១

កិច្ចព្រមព្រៀមទីក្រុងម៉ាឌ្រីដ (Madrid Agreement) ស្តីពីការបង្ក្រាបការក្លែងបន្លំ ឬការបោកបញ្ឆោតនៃប្រភពទំនិញ ដែលចែងលម្អិតលើសញ្ញាសម្គាល់នៃប្រភពទំនិញ។ យោងទៅតាមមាត្រា១ កថាខណ្ឌទី១ នៃកិច្ចព្រមព្រៀមទីក្រុងម៉ាឌ្រីដបានចែងថា៖

"ទំនិញមួយឬច្រើន ដែលមាននូវការក្លែងឬបន្លំនូវសញ្ញា ដោយភាគីនៃរដ្ឋមួយនៃរដ្ឋដទៃទៀតដែលស្ថិតក្នុងកិច្ចព្រមព្រៀង កន្លែងដែលស្ថិតនៅ ដោយផ្ទាល់ឬប្រយោល ដែលក្នុងនាមជារដ្ឋ ឬជាទីតាំងនៃប្រភពដើមទំនិញ ត្រូវបានរឹបអូសលើការនាំចូលទៅក្នុងប្រទេសដែលមានចែងក្នុងកិច្ចព្រមព្រៀង" ។

កិច្ចព្រមព្រៀមទីក្រុងម៉ាឌ្រីដ ជាកិច្ចព្រមព្រៀងពហុភាគីដំបូងដែលចែងអំពីវិធានជាក់លាក់សម្រាប់ការទប់ទល់ប្រឆាំងនឹងការក្លែងបន្លំ ឬការបោកបញ្ឆោតនៃសញ្ញាសម្គាល់នៃប្រភពទំនិញ។ កិច្ចព្រមព្រៀមនេះ គឺមិនបានបន្ថែមច្រើននូវការការពារពីលើអនុសញ្ញាទីក្រុងប៉ារីសទេ ប៉ុន្តែកិច្ចព្រមព្រៀងនេះ បានបន្ថែមការការពារចំពោះសញ្ញា

សម្គាល់នៃប្រភពដើមទំនិញ ដែលមានការក្លែងបន្លំពីលើសញ្ញាសម្គាល់ពិត។ ឧទាហរណ៍៖ សញ្ញាសម្គាល់នៃប្រភពដើមទំនិញ ដែលមានការក្លែងបន្លំ អាចជាឈ្មោះនៃទីកន្លែង ដែលជាប្រភពដើមនៃទំនិញ ហើយធ្វើឱ្យអ្នកប្រើប្រាស់មានការភាន់ច្រលំ ដោយផ្អែកលើភាពប្រាកដប្រជានៃទីតាំងប្រភពទំនិញ និងគុណភាពនៃទំនិញ។ ប៉ុន្តែតាមពិត ទំនិញនេះមិនមែនចេញពីប្រភពកំណើតដែលផលិតទំនិញនេះទេ គឺគ្រាន់តែដាក់ឈ្មោះបន្លំទៅនឹងទំនិញ ដែលត្រូវបានចាត់ទុកជាសញ្ញាសម្គាល់នៃប្រភពដើមទំនិញ ក្នុងគោលបំណងចង់ទទួលបាននូវផលប្រយោជន៍ និងធ្វើឱ្យខាតបង់ទៅលើម្ចាស់ទំនិញដែលទទួលបាននូវការការពារ។

## ក.៣. កិច្ចព្រមព្រៀងទីក្រុងលីសប៊ីនឆ្នាំ ១៩៥៨

គោលបំណងរបស់កិច្ចព្រមព្រៀងទីក្រុងលីសប៊ីន (Lisbon Agreement) ស្តីពីការការពារនូវឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញ គឺបានផ្តល់នូវការការពារទៅលើឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញថា "ជាឈ្មោះទីតាំងភូមិសាស្ត្រនៃប្រទេសមួយ ឬតំបន់ណាមួយ ឬទីតាំងណាមួយ ដែលបានធ្វើឱ្យផលិតផលមួយ បានកើតឡើងនៅទីនោះ ទាំងគុណភាព ឬចរិតលក្ខណៈពិសេសផ្សេងទៀត ដែលអាស្រ័យទៅលើលក្ខណៈពិសេសនៃបរិស្ថានភូមិសាស្ត្រ ដែលរួមបញ្ចូលទាំងកត្តាធម្មជាតិ និងកត្តាមនុស្សផងដែរ[46]"។ យោងតាមកិច្ចព្រមព្រៀងនេះ ដើម្បីទទួលបានការការពារលើឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញ ត្រូវតែបំពេញនូវលក្ខខណ្ឌចម្បងពីរ៖ **(ក)** ទទួលបានការការពារក្នុងប្រទេសដែលជាប្រភពដើម និង**(ខ)** ទទួលបានការចុះបញ្ជីជាអន្តរជាតិរបស់ WIPO។

លើសពីនេះ កិច្ចព្រមព្រៀងនេះ ក៏បានអនុញ្ញាតឱ្យប្រទេសជាសមាជិក អាចប្រើប្រាស់នូវប្រព័ន្ធរបស់ខ្លួនក្នុងការកំណត់ឈ្មោះទីតាំងដោយសេរីតាមរយៈសេចក្តីសម្រេចយុត្តាធិការ ឬតាមការសម្រេចបែបរដ្ឋបាល ឬ អាចធ្វើបានទាំងពីរវិធី។ នៅពេលចុះឈ្មោះរួចរាល់ ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រនឹងទទួលបានការការពារពីរដ្ឋដទៃដែលជាសមាជិក។ ភាគីដែលពាក់ព័ន្ធត្រូវតែការពារនូវឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញ ដែលតម្រូវតាមបទដ្ឋានអន្តរជាតិ លើកលែងតែក្នុងករណីភាគីសមាជិកណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ បានប្រកាសក្នុងរយៈពេលកំណត់មួយឆ្នាំ ថាមិនអាចធានាសម្រាប់ការការពារទៅលើប្រទេសណាមួយ។ ជាពិសេស គ្មាននូវមូលហេតុជាក់លាក់នៅក្នុងកិច្ចព្រមព្រៀង សម្រាប់ការបដិសេធនូវការដាក់ឈ្មោះ។

រយៈពេលនៃការការពារតាមរយៈការចុះបញ្ជីអន្តរជាតិ មានភាពស្រដៀងទៅនឹងការការពារឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញនៅក្នុងរដ្ឋដែលជាប្រភពដើម។ ដូច្នេះហើយ គ្មាននូវលក្ខខណ្ឌទាមទារសម្រាប់ការបន្តទទួលបានការការពារជាអន្តរជាតិឡើយ។ នាពេលបច្ចុប្បន្ន កិច្ចព្រមព្រៀងទីក្រុងលីសប៊ីន មានរដ្ឋជាហត្ថលេខីចំនួន៣០[47] ដែលរួមមាន រដ្ឋដែលជាសមាជិកសហភាពអឺរ៉ុបដូចជា ប្រទេសបារាំង និងព័រទុយហ្កាល់

[46] មាត្រា២ នៃកិច្ចព្រមព្រៀងទីក្រុងលីសប៊ីនឆ្នាំ១៩៥៨

[47] "Lisbon Agreement: Contracting Parties", WIPO, 2020, https://bit.ly/31dfCHA, ចូលមើលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

(ចាប់ពីថ្ងៃ២៥ ខែសីហា ឆ្នាំ១៩៦៦) ប្រទេសហុងគ្រី (ចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៦៧) អ៊ីតាលី (ចាប់ពីថ្ងៃទី២៩ ខែធ្នូ ១៩៦៨) ប្រទេសឆេកូស្លូវ៉ាគី សាធារណរដ្ឋឆេក(ថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៣) និងប្រទេសផ្សេងៗទៀត។ បានសេចក្តីថា ឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញដែលមកពីប្រទេសជាសហគមន៍អឺរ៉ុបដែលចុះបញ្ជីជាអន្តរជាតិនៅ WIPO គឺត្រូវទទួលបានការការពារគ្រប់ប្រទេសទាំងអស់ដែលជា ភាគីនៃកិច្ចព្រមព្រៀង។

### ក.៤. កិច្ចព្រមព្រៀមទីក្រុងម៉ាឌ្រីដ ទាក់ទងនឹងការចុះបញ្ជីអន្តរជាតិនៃម៉ាក

នៅប្រទេសមួយចំនួន ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រឹមតែបានការពារជាម៉ាកធម្មតាតែប៉ុណ្ណោះ។ ដូច្នេះ ប្រព័ន្ធម៉ាឌ្រីដសម្រាប់ការចុះបញ្ជីជាអន្តរជាតិនេះ ជាម៉ាកសមូហភាព (Collective marks) ម៉ាកវិញ្ញាតកម្ម (Certification marks) ឬម៉ាកដែលមានការធានា (Guarantee Marks) គឺសុទ្ធតែទាក់ទងនឹងការការពារនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ នេះមានន័យថាការចុះបញ្ជីជាអន្តរជាតិសម្រាប់ម៉ាកពាណិជ្ជកម្ម បង្កើតឡើងដោយអនុសញ្ញាទីក្រុងម៉ាឌ្រីដឆ្នាំ១៨៩១ និងពិធីសារដែលជាប់ទាក់ទងកិច្ចព្រមព្រៀមទីក្រុងម៉ាឌ្រីដស្តីអំពីការចុះបញ្ជីអន្តរជាតិនៃម៉ាកនៅឆ្នាំ១៩៨៩ ក៏បានដើរតួនាទីជាវិធីសាស្ត្រក្នុងការការពារកិច្ចព្រមព្រៀមទីក្រុងម៉ាឌ្រីដជាអន្តរជាតិ។ ទោះយ៉ាងណាក៏ដោយ ប្រព័ន្ធនេះអាចប្រើបានត្រឹមតែប្រទេសដែលការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ តាមរយៈម៉ាកវិញ្ញតកម្ម ពាណិជ្ជនាម និងមាននូវវិធានជាក់លាក់ (Sui generis) ទៅលើការទទួលបានការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។

ប្រព័ន្ធទីក្រុងម៉ាឌ្រីដមាននូវសន្ធិសញ្ញាចំនួនពីរគឺ កិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកជាអន្តរជាតិ ដែលបង្កើតឡើងឆ្នាំ១៨៩១ និងពិធីសារដែលជាប់ទាក់នឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដនៅឆ្នាំ១៩៨៩។ ប្រព័ន្ធចុះបញ្ជីអន្តរជាតិទីក្រុងម៉ាឌ្រីដ អាចប្រើប្រាស់បានក្នុងចំណោមប្រទេសដែលជាភាគីនៃកិច្ចព្រមព្រៀង ឬពិធីសារទីក្រុងម៉ាឌ្រីដ។ ប្រព័ន្ធនេះបានផ្តល់ឱ្យនូវម្ចាស់នៃ ពាណិជ្ជនាម ទទួលបានការការពារម៉ាករបស់ខ្លួននៅក្នុងប្រទេសមួយចំនួន ដោយគ្រាន់តែដាក់ពាក្យសុំមួយទៅកាន់ការិយាល័យចុះបញ្ជី ពាណិជ្ជនាម ហើយប្រើប្រាស់ភាសាតែមួយ និងកំណត់ថ្លៃសេវាជារូបិយប័ណ្ណមួយប្រភេទ។

យោងតាមពិធីសារនេះ ការចុះបញ្ជីលក្ខណៈអន្តរជាតិបង្កើតឱ្យមាននូវអានុភាពដូចទៅនឹងការដាក់ពាក្យសុំចុះបញ្ជីម៉ាកដែលកំណត់ នៅតាមប្រទេសនីមួយៗនៃប្រទេសម្ចាស់ពាក្យសុំបានកំណត់។ ប្រសិនការស្នើនូវការការពារមិនត្រូវបានបដិសេធដោយការិយាល័យចុះបញ្ជីពាណិជ្ជនាម នៅក្នុងប្រទេសដែលបានកំណត់ក្នុងរយៈពេលជាក់លាក់ (ពី១២ខែ ដល់ ១៨ខែ) ការការពារនៃម៉ាកនោះ នឹងមានប្រសិទ្ធភាពដូចដែលចុះបញ្ជីនៅការិយាល័យប្រទេសនោះ។ ប្រព័ន្ធទីក្រុងម៉ាឌ្រីដ បានធ្វើឱ្យការគ្រប់គ្រង់ម៉ាកកាន់តែល្អប្រសើរជាបន្តបន្ទាប់ ដោយសារតែងាយស្រួលក្នុងការធ្វើកំណត់ត្រាផ្លាស់ប្តូរជាបន្តបន្ទាប់ (ដូចជាការផ្លាស់ប្តូរម្ចាស់ ឬការប្តូរផ្លាស់ឈ្មោះឬអាសយដ្ឋានរបស់អ្នកកាន់កាប់) ឬ បន្តនូវការចុះបញ្ជីតាមរយៈនីតិវិធីសាមញ្ញៗ ជាមួយនឹងការិយាល័យអន្តរជាតិ WIPO។

## ក.៥. កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា

ផ្នែកមួយនៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS Agreement) ឆ្នាំ១៩៩៤ គឺការចែងពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ កិច្ចព្រមព្រៀងនេះជាសន្ធិសញ្ញាពហុភាគីដំបូងគេ ដែលមានជាប់ពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ ផ្អែកតាមមាត្រា២២ នៃកិច្ចព្រមព្រៀងនេះ បានផ្តល់នូវនិយមន័យ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញថា៖

"ជាការចង្អុលបង្ហាញដែលសម្គាល់ទំនិញមួយថា មានប្រភពក្នុងដែនដីនៃសមាជិកណាមួយ ឬតំបន់ ឬទីតាំងណាមួយនៃដែនដីនេះ ដែលមានគុណភាពជាក់លាក់ កិត្តិនាម ឬចរិកលក្ខណៈផ្សេងទៀតនៃទំនិញដែលកើតចេញជាពិសេសពីប្រភពភូមិសាស្ត្រនោះ" ។

និយមន័យនេះ គឺចង់ពង្រីកនូវអត្ថន័យនៃឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញមាននៅក្នុងមាត្រា២ នៃកិច្ចព្រមព្រៀងទីក្រុងលីសបិន ហើយមានគោលបំណងការពារនូវទំនិញដែលកើតចេញពីកេរ្តិ៍ឈ្មោះ ឬកិត្តិនាម មកពីទីតាំងប្រភពដើម ដោយពុំចាំបាច់មាននូវគុណភាព ឬលក្ខណៈផ្សេងៗដែលកើតចេញពីទីកន្លែងនោះ។ តាមរយៈនិយមន័យនេះ ដើម្បីទទួលបានការការពារ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវតែជា "សញ្ញាសម្គាល់មួយប្រាកដ" ប៉ុន្តែមិនចាំបាច់ជាឈ្មោះនៃទីកន្លែងភូមិសាស្ត្រនោះទេ។ លើសពីនេះ កិច្ចព្រមព្រៀងនេះ បានបែងចែកនូវកម្រិតទទួលបានការការពារជាបីកម្រិតខុសៗគ្នា៖ ទី១-ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញទាក់ទងនឹងផលិតផលទាំងអស់ទី២-ស្រាទំពាំងបាយជូរ និង ស្រាដប (ពពួកជាតិអាកុលខ្លាំង) និងទី៣- ទំពាំងបាយជូរតែមួយគត់។

ស្តង់ដារអប្បបរមានៃការពារសម្រាប់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញទាំងអស់ មិនថាប្រភេទទំនិញអ្វីក៏ដោយ គឺស្ថិតក្រោមមាត្រា២២ នៃកិច្ចព្រមព្រៀងនេះ។ វិសាលភាពនៃការការពារ គឺកម្រិតត្រឹមការហាមឃាត់នូវការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយផលិតករដែលមិនស្ថិតនៅក្នុងតំបន់ដែល ជាកន្លែងពិសេសរបស់ម៉ាកសម្គាល់ភូមិសាស្ត្រ។ ការការពារបន្ថែមសម្រាប់ពពួកស្រាទំពាំងបាយជូរ និងស្រាដប (ពពួកជាតិអាកុលខ្លាំងរួមបញ្ចូលនូវចំណុចសំខាន់បី៖ (ទី១) មធ្យោបាយគតិយុត្ត សម្រាប់ភាគីដែលពាក់ព័ន្ធក្នុងការបង្ការនូវការប្រើប្រាស់នូវម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រកំណត់នូវស្រាទំពាំងបាយជូរ និងស្រាដប(ពពួកជាតិអាកុលខ្លាំង) ដែលមិនមែនមានប្រភពចេញពីទីកន្លែងដែលកំណត់ដោយ ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ (ទី២) លទ្ធភាពដែលអាចធ្វើការបដិសេធ ឬចាត់ទុកថាមោឃៈរាល់ការចុះបញ្ជីពាណិជ្ជនាម លើស្រាទំពាំងបាយជូរ និង ស្រាដប(ពពួកជាតិអាកុលខ្លាំង)ដែលមាន ឬជាប់ទាក់ទងនឹងម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ កំណត់នូវស្រាទំពាំងបាយជូរ និងស្រាដប(ពពួកជាតិអាកុលខ្លាំង) ដោយសំណើរបស់ភាគីពាក់ព័ន្ធ និង (ទី៣) ការកោះហៅសម្រាប់ការជជែកពិភាក្សាវែកញែក ក្នុងគោលបំណងបង្កើននូវការការពារសម្រាប់ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រផ្សេង សម្រាប់ស្រាទំពាំងបាយជូរ និងស្រាដប (ពពួកជាតិអាកុលខ្លាំង)។

"ការបន្ថែមការការពារ" ដោយកិច្ចព្រមព្រៀងនេះ សម្រាប់ស្រាទំពាំងបាយជូរប៉ុណ្ណោះ ដោយសង្កត់ធ្ងន់តែទៅលើតម្រូវការក្នុងការផ្តល់ នូវការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ សម្រាប់ស្រាទំពាំងបាយជូរ ក្នុងករណីមានសញ្ញាស្រដៀងគ្នា និងការបង្កើតនូវប្រព័ន្ធពហុភាគីនៃការផ្តល់ដំណឹង និងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញសម្រាប់ស្រាទំពាំងបាយជូរទាំងឡាយ ដែលមានសិទ្ធិទទួលបាននូវការការពារ នៅក្នុងដែនសមត្ថកិច្ចនៃសមាជិករបស់អង្គការពាណិជ្ជកម្មអន្តរជាតិ ដែលបានចូលរួមនៅក្នុងប្រព័ន្ធនេះ។

### ខ. ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅក្នុងកិច្ចព្រមព្រៀងពហុភាគី និងតំបន់

#### ខ.១. កិច្ចព្រមព្រៀងអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក

កិច្ចព្រមព្រៀងអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក (The African Intellectual Property Organization "OAPI" Agreement) ត្រូវបានចុះហត្ថលេខានៅទីក្រុងBangui នាថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៧៧ ជំនួសនូវកិច្ចព្រមព្រៀងដំបូងដែលចុះហត្ថលេខានៅទីក្រុងLibreville នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៦២ ដែលបង្កើតបាននូវអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក។ កិច្ចព្រមព្រៀងអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក(OAPI) ឬ Bangui ត្រូវបានធ្វើកំណែទម្រង់នៅឆ្នាំ១៩៩៩ និងចូលជាធរមាននៅខែកុម្ភៈ ឆ្នាំ២០០២។

ប្រទេសកាមេរូន បេណាំង បួគីណាហ្វាសូ អាហ្វ្រិកកណ្តាល ឆាដ កុងហ្គោ ហ្គាបុង ហ្គីណេ និងប្រទេសក្នុងតំបន់អាហ្វ្រិកផ្សេងៗទៀត គឺជាភាគីនៃកិច្ចព្រមព្រៀងអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក[48] បានបញ្ចូលកិច្ចព្រមព្រៀងនេះទៅក្នុងច្បាប់ជាតិរបស់ខ្លួន នាំឱ្យកិច្ចព្រមព្រៀងនេះ មានអានុភាពអនុវត្តនៅគ្រប់បណ្តារដ្ឋជាសមាជិក។ គ្រប់រដ្ឋជាសមាជិកអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក គឺជាភាគីនៃអនុសញ្ញាទីក្រុងប៉ារីស និងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា។ ប្រទេសបួគីណាហ្វាសូ កុងហ្គោ ហ្គាបុង និងតូហ្គោ ក៏ជាភាគីនៃកិច្ចព្រមព្រៀងទីក្រុង Lisbon ផងដែរ។

#### ខ.២. ពិធីសារទីក្រុងបង់ហ្ស៊ុលស្តីពីម៉ាក

អង្គការកម្មសិទ្ធិបញ្ញាក្នុងតំបន់អាហ្វ្រិក ត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងទីក្រុងLusaka ហើយត្រូវបានអនុម័តនៅទីក្រុងLusaka ប្រទេសសំប៊ី ក្នុងឆ្នាំ១៩៧៦។ គោលបំណងនៃអង្គការកម្មសិទ្ធិបញ្ញាក្នុងតំបន់អាហ្វ្រិក (ARIPO) គឺដើម្បីពង្រឹងធនធានរបស់រដ្ឋដែលជាសមាជិក (ប្រទេសក្នុងទ្វីបអាហ្វ្រិកដែលនិយាយភាសាអង់គ្លេស) នៅក្នុងវិស័យកម្មសិទ្ធឧស្សាហកម្ម ដើម្បីជៀសវាងនូវការងារច្រំដែល។

ពិធីសារទីក្រុងបង់ហ្ស៊ុលស្តីពីម៉ាក [49] ដែលអនុម័តដោយក្រុមប្រឹក្សារដ្ឋបាលនៅឆ្នាំ១៩៩៣ គឺបង្កើតនូវប្រព័ន្ធចុះបញ្ជីពាណិជ្ជនាម។ ក្រោមពិធីសារទីក្រុងបង់ហ្ស៊ុល អ្នកដាក់ពាក្យអាចដាក់ពាក្យសុំមួយច្បាប់នៅរដ្ឋដែល

[48] "African Intellectual Property Organization (OAPI)", WIPO Lex, https://bit.ly/2YxkbLd, ចូលមើលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

[49] *"BANJUL PROTOCOL ON MARKS"*, ARIPO Office, 2019, https://bit.ly/38bSQlb, ចូលមើលថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ២០២០

ជាភាគី ឬដោយផ្ទាល់ជាមួយនឹងការិយាល័យអង្គការកម្មសិទ្ធិបញ្ញាក្នុងតំបន់នៅអាហ្វ្រិក ព្រមទាំងធ្វើការកំណត់នូវរដ្ឋដែលខ្លួនចង់បានការការពារលើម៉ាក។ ពិធីសារនេះ បានចូលជាធរមាននៅថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៩៧ សម្រាប់ប្រទេសម៉ាឡាវី ស្វាស៊ីឡង់ និងស៊ីមបាវ៉េ។ ប្រទេសឡេសូតូ និង តង់សានី បានចូលរួមក្នុងពិធីសារ នៅឆ្នាំ១៩៩៩។ សព្វថ្ងៃនេះ អង្គការកម្មសិទ្ធិបញ្ញាក្នុងតំបន់អាហ្វ្រិក មានសមាជិកសរុបចំនួន ១៩ប្រទេស[50] ដែលជាប្រទេសសុទ្ធតែមាននូវវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម ក្នុងកម្រិតខ្ពស់ ហើយនាពេលបច្ចុប្បន្ននេះ សមាជិកភាពនៃ ARIPO បានបើកចំហឱ្យរដ្ឋជាសមាជិកនៃគណៈកម្មការសេដ្ឋកិច្ចទ្វីបអាហ្វ្រិក (UNECA) ឬសហភាពទ្វីបអាហ្វ្រិក (AU)។ តាំងពីឆ្នាំ ១៩៩៧ ពិធីសារនេះ ត្រូវបានកែសម្រួលយ៉ាងទូលំទូលាយ ដើម្បីធ្វើឱ្យត្រូវគ្នាជាមួយកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងសន្ធិសញ្ញានៃច្បាប់ពាណិជ្ជនាម ក៏ដូចជាធ្វើឱ្យកាន់តែងាយស្រួលអនុវត្ត។

### គ.កិច្ចព្រមព្រៀងទ្វេភាគីសហគមន៍អឺរ៉ុបសម្រាប់ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

សហគមន៍អឺរ៉ុប (European Community/EC) បានធ្វើកិច្ចព្រមព្រៀងទ្វេភាគីជាច្រើន ជាមួយនឹងបណ្តាប្រទេសដែលជាសមាជិកនៃអអង្គការពាណិជ្ជកម្មអន្តរជាតិ ហើយកិច្ចព្រមព្រៀងទាំងនោះ រួមមាន៖

#### គ.១. កិច្ចព្រមព្រៀងរវាងសហគមន៍អឺរ៉ុប និងប្រទេសអូស្ត្រាលី

កិច្ចព្រមព្រៀងសហគមន៍អឺរ៉ុប និងប្រទេសអូស្ត្រាលី លើការជួញដូរស្រាទំពាំងបាយជូរ គឺជាឧទាហរណ៍ដំបូងមួយនៃកិច្ចព្រមព្រៀងទ្វេភាគី ដែលសម្រេចរវាងសហគមន៍អឺរ៉ុប និងប្រទេសដទៃទៀតសម្រាប់ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាដោយឡែកពីគ្នា នៅទីក្រុង Brussel នៅថ្ងៃទី២៥ និងទីក្រុង Canberra នៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៤។

កិច្ចព្រមព្រៀងសហគមន៍អឺរ៉ុប និងប្រទេសអូស្ត្រាលី ផ្តល់នូវនិយមន័យសម្រាប់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងវិសាលភាពនៃការការពារឈ្មោះ ដែលរាប់នៅឧបសម្ព័ន្ធទី២[51] នៃកិច្ចព្រមព្រៀងនេះ។ លក្ខខណ្ឌសំខាន់សម្រាប់ការការពារក្រោមកិច្ចព្រមព្រៀងនេះគឺ ការទទួលស្គាល់នូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក្រោមច្បាប់របស់ប្រទេសដែលជាភាគីនៃកិច្ចព្រមព្រៀង។ បន្ថែមពីនេះ កិច្ចព្រមព្រៀងនេះ បានបញ្ញត្តិឡើងនូវច្បាប់ដែលជាប់ពាក់ព័ន្ធនឹងការទទួលស្គាល់គ្នាទៅវិញទៅមកនូវរបៀបរបបប្រពៃណី[52]។

[50] *"Member States"*, ARIPO, https://bit.ly/2Zdq5QG, ចូលមើលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

[51] Annex II of Agreement between the European Community and Australia on trade in wine, Official Journal of the European Communities, 1994, https://bit.ly/31ggNGl, ចូលមើលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

[52] **របៀបរបបប្រពៃណីសំដៅលើ** ប្រពៃណីក្នុងការបង្កើត និងរៀបចំគុណភាពស្រា និងការផលិតឬ វិធីសាស្ត្រក្នុងការបម្រែបម្រួល អាយុ គុណភាព និងពណ៌ស្រា។

### គ.២. កិច្ចព្រមព្រៀងរវាងសហគមន៍អឺរ៉ុប និងប្រទេសកាណាដា

កិច្ចព្រមព្រៀងរវាងសហគមន៍អឺរ៉ុប និងប្រទេសកាណាដា លើការជួញដូរស្រាទំពាំងបាយជូរ និងស្រាដប (កម្រិតជាតិអាកុលខ្ពស់) ត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៣[53]។ រចនាសម្ព័ន្ធនៃកិច្ចព្រមព្រៀងសហគមន៍អឺរ៉ុប និងប្រទេសកាណាដា គឺស្រដៀងគ្នានឹងកិច្ចព្រមព្រៀងអូស្ត្រាលី។ កិច្ចព្រមព្រៀងនេះ ត្រូវបានយល់ព្រមលើការបញ្ចប់លើប្រភេទស្រាទំពាំងបាយជូរអឺរ៉ុបដែលគ្មានឈ្មោះ ឬគុណភាពច្បាស់លាស់ ជាបីដំណាក់កាល គឺនៅថ្ងៃទី៣១ ខែធ្នូ ២០១៣ សម្រាប់ស្រាChablis Champagne, Port/Porto និង Sherry ចាប់ពីថ្ងៃទី ៣១ ខែធ្នូ ២០០៨ សម្រាប់ស្រា Bourgogne/Burgundy, Rhin/Rhine, Sauterne/Sauternes និងត្រូវអនុវត្តភ្លាមៗ សម្រាប់ស្រា Bordeaux, Chianti, Claret, Madeira, Malaga, Marsala, Medoc/Médoc, និង Mosel/Moselle។ សម្រាប់ស្រាដែលមានជាតិអាកុលខ្ពស់ ត្រូវបានបញ្ចប់ពីប្រភេទស្រាអឺរ៉ុបរួមមាន Grappa, Ouzo, Jägertee/Jagertee/ Jagatee, Korn/Kornbrand និង Pacharan ត្រូវបានបញ្ឈប់ការផលិតក្នុងរយៈពេល ២ឆ្នាំ ចាប់ពីពេលដែលកិច្ចព្រមព្រៀងមានអានុភាពអនុវត្ត។ ដោយជាការតបស្នងសហគមន៍អឺរ៉ុប នឹងការពាររាល់គ្រប់ឈ្មោះផលិតផលស្រាវីស្គីធ្វើពីស្រូវសាលីរបស់កាណាដា “Canadian Rye Whiskey” ជាផលិតផលដាច់ដោយរបស់ប្រទេសកាណាដា។

### គ.៣. កិច្ចព្រមព្រៀងសហគមន៍អឺរ៉ុប និងប្រទេសម៉ិកស៊ិក

នៅឆ្នាំ១៩៩៨ ប្រទេសម៉ិកស៊ិក និងសហភាពអឺរ៉ុប បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងលើការជ្រើសរើសនូវប្រភេទស្រាដែលមានកម្រិតអាកុលខ្ពស់ ដែលភាគីទាំងពីរបានយល់ព្រមឱ្យមានការការពារទៅលើការដាក់ឈ្មោះប្រភពដើមនៃប្រភេទស្រាដូចជា Tequila និង Mezcal, Whisky, Grappa និងCognac។ ឈ្មោះដែលទទួលបានការការពារនឹងបញ្ជាក់បន្ថែមនៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀង[54]។

### គ.៤. កិច្ចព្រមព្រៀងសហគមន៍អឺរ៉ុប និងប្រទេសស៊ីលី

ផ្នែកទី៦នៃកិច្ចព្រមព្រៀងឆ្នាំ២០០២ បង្កើតនូវចំណងរវាងសហគមន៍អឺរ៉ុប និងប្រទេសស៊ីលី ដែលមាននៅក្នុងឧបសម្ព័ន្ធទី៥ និង ៦ ភ្ជាប់ជាមួយនឹងកិច្ចព្រមព្រៀង។ ឧបសម្ព័ន្ធនេះ គឺជាកិច្ចព្រមព្រៀងលើការជួញដូរស្រាទំពាំងបាយជូរ និងកិច្ចព្រមព្រៀងលើការជួញដូរលើស្រាដែលមានកម្រិតអាកុលខ្ពស់ និងស្រាសម្រាប់គ្រេបយកក្លិន។

---

[53] Agreement between the European Community and Canada on trade in wines and spirit drinks, https://bit.ly/2Nt9GSR, ចូលមើលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

[54] Agreement between the European Community and the United Mexican States on the mutual recognition and protection of designations for spirit drinks, https://bit.ly/2CAyqGw

កិច្ចព្រមព្រៀងទាំងពីរនេះបានប្បញ្ញត្តិនូវច្បាប់មួយចំនួន ដែលជាប់ទាក់ទងនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងបញ្ជាក់ពីឈ្មោះស្រាដែលទទួលបានការការពារនៅក្នុងឧបសម្ព័ន្ធ[55]។

## គ.៥. កិច្ចព្រមព្រៀងសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ កិច្ចព្រមព្រៀងរវាងសហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប លើការជំនួញស្រាទំពាំងបាយជូរ ត្រូវបានចុះហត្ថលេខា។ ចាប់តាំងពីឆ្នាំ១៩៨៣ សហភាពអឺរ៉ុប បានធ្វើបដិប្បញ្ញត្តិរយៈពេលខ្លីមួយ ដែលអនុញ្ញាតឱ្យមានការនាំចូលស្រាទំពាំងបាយជូរអាមេរិក ដែលធ្វើឡើងតាមវិធីសាស្ត្រដែលទទួលស្គាល់ដោយសហភាពអឺរ៉ុប។ រយៈពេលបណ្ដោះអាសន្ននៃការធ្វើបដិប្បញត្តិ នេះបង្កើតឱ្យមានភាពមិនប្រាកដប្រជាដល់អ្នកនាំចេញស្រាទំពាំងបាយជូរសហរដ្ឋអាមេរិក។ កិច្ចព្រមព្រៀងបានផ្ដល់នូវ៖ (ទី១) ការទទួលស្គាល់នូវវិធីសាស្ត្របច្ចុប្បន្ន ក្នុងការផលិតស្រាទំពាំងបាយជូររបស់គ្នាទៅវិញទៅមក (ទី២) ដំណើរការពិភាក្សាសម្រាប់ការទទួលស្គាល់នូវវិធីសាស្ត្រ ក្នុងការបង្កើតស្រាទំពាំងបាយជូរថ្មី (ទី៣) សហរដ្ឋអាមេរិកបានកំណត់នូវការប្រើប្រាស់ឈ្មោះប្រទេសរបស់ខ្លួន ទៅលើផលិតផលដែលមិនមានដើមកំណើត ក្នុងសហរដ្ឋអាមេរិកតែលើផលិតផលមួយចំនួនក្នុងទីផ្សារសហរដ្ឋអាមេរិក (ទី៤) សហភាពអឺរ៉ុបអនុញ្ញាតឱ្យប្រើប្រាស់នូវលក្ខខណ្ឌដាក់កំហិតមួយចំនួនសម្រាប់ស្រាទំពាំងបាយជូររបស់សហរដ្ឋអាមេរិកនាំចេញទៅសភាពអឺរ៉ុប (ទី៥) ទទួលស្គាល់ឈ្មោះប្រភពដើមមួយចំនួនក្នុងទីផ្សាររបស់គ្នាទៅវិញទៅមក និង(ទី៦) បន្ធូរបន្ថយនូវលក្ខខណ្ឌទទួលស្គាល់ សម្រាប់ស្រាទំពាំងបាយជូរដែលនាំចេញពីសហរដ្ឋ ទៅសហភាពអឺរ៉ុប។

កិច្ចព្រមព្រៀងនេះបានចែងថា សហរដ្ឋអាមេរិកនឹងស្វែងរកការផ្លាស់ប្ដូរផ្នែកផ្លូវច្បាប់សម្រាប់ការកំណត់នូវការប្រើប្រាស់ផលិតផលដែលមានឈ្មោះប្រទេសរបស់ខ្លួន តែមិនមែនជាទីតាំងប្រភពដើមពីសហរដ្ឋអាមេរិកចំនួន ១៦ (ឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀងមានស្រា Burgundy, Chablis, Champagne, Chianti, Claret, Haut Sauterne, Hock, Madeira, Malaga, Marsala, Moselle, Port, Retsina, Rhine, Sauterne, Sherry និង Tokay)។ ការផ្លាស់ប្ដូរនេះនឹងលើកលែងដល់ការដែលធ្លាប់បានប្រើប្រាស់នូវផលិតផលស្រា ដែលមិនមែនជារបស់ផលិតផលអឺរ៉ុប ដែលមានឈ្មោះប្រទេសរបស់ខ្លួនតែមិនមែនជាទីតាំងប្រភពដើមពីសហរដ្ឋអាមេរិក ប៉ុន្តែហាមឃាត់ផលិតផលថ្មីទៀតពីការប្រើប្រាស់ឈ្មោះទាំងនេះលើស្រាទំពាំងបាយជូរអឺរ៉ុប។ សហរដ្ឋអាមេរិកនឹងក្រើនរំលឹកដល់សហគមន៍អឺរ៉ុប នូវកាលបរិច្ឆេទ នៅពេលដែលការផ្លាស់ប្ដូរផ្នែកផ្លូវច្បាប់នេះចូលមកជាធរមាន។ កិច្ចព្រមព្រៀងនេះបានប្បញ្ញត្តិនូវឈ្មោះស្រាទំពាំងបាយជូរដែលមានគុណភាពផលិតក្នុងតំបន់ជាក់លាក់ពីសហគមន៍អឺរ៉ុប និងសហរដ្ឋ

[55] Agreement establishing an association between the European Community and its Member States, of the one part, and the Republic of Chile, of the other part, https://bit.ly/2Z7quEh

អាមេរិក (ឧបសម្ព័ន្ធទី៦ និង ៥) ដែលអាចនឹងត្រូវបានប្រើប្រាស់ឈ្មោះនៃទីតាំងប្រភពដើម ដែលកំណត់ដោយឈ្មោះដែលបានរៀបរាប់ (មាត្រា ៧ នៃកិច្ចព្រមព្រៀង[56])។

[56] Agreement between the European Community and the United States of America on trade in wine, https://bit.ly/2Z6IRte

# ជំពូកទី២

# នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ទំនិញក្នុងក្របខណ្ឌគតិយុត្តជាតិ និងអន្តរជាតិ

# ជំពូកទី២
# នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក្នុងក្របខណ្ឌគតិយុត្តជាតិ និងអន្តរជាតិ

ដើម្បីឱ្យផលិតផលមួយអាចទទួលបានការការពារថា ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញម្ចាស់ផលិតផល ត្រូវតែយកផលិតផលរបស់ខ្លួនទៅចុះបញ្ជីឱ្យបានត្រឹមត្រូវ ទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់។ ជាក់ស្តែង នីតិវិធីចុះបញ្ជីនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ អាចធ្វើការចុះបញ្ជីតាមបទដ្ឋានគតិយុត្តជាតិ និងបទដ្ឋានគតិយុត្តអន្តរជាតិ ។

## ផ្នែកទី១៖ នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងក្របខណ្ឌគតិយុត្តជាតិ

យោងទៅតាមច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលបានការការពារដោយស្របច្បាប់ គឺតម្រូវឱ្យម្ចាស់ផលិតផល ត្រូវធ្វើការស្នើសុំចុះបញ្ជីទៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដោយត្រូវបំពេញនូវលក្ខខណ្ឌ និងអនុវត្តតាមនីតិវិធីដែលកំណត់ក្នុងបទប្បញ្ញត្តិនានាដែលជាប់ពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ នីតិវិធីនៃការចុះបញ្ជីនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញតាមបរិបទគតិយុត្តជាតិ ត្រូវបានបែងចែកជាពីរគឺ៖ ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងស្រុក និងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស ។

### កថាខណ្ឌទី១៖ នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងស្រុក

ចំពោះទំនិញដែលបានផលិតក្នុងព្រះរាជាណាចក្រកម្ពុជា មានបំណងចង់ចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺចាំបាច់បំផុតត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួន ដែលតម្រូវដោយបទប្បញ្ញត្តិនានារបស់ព្រះរាជាណាចក្រកម្ពុជា។

#### ក. លក្ខខណ្ឌដើម្បីទទួលបានការការពារ

ដើម្បីទទួលបាននូវការការពារភាគីដែលជាប់ព័ន្ធពាក់ ត្រូវតែបំពេញនូវលក្ខខណ្ឌចំបងមួយចំនួនសិន មុននឹងទៅស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ពីនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។

#### ក.១. លក្ខណៈរបស់អ្នកដាក់ពាក្យស្នើសុំ

សមាគមសម្គាល់ភូមិសាស្ត្រ ឬក្រុមតំណាងផលិតករ ឬអង្គភាពតំណាងផលិតផល និង/ឬប្រតិបត្តិករដែលអាចទទួលបានផលប្រយោជន៍ពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះមាន សិទ្ធិដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ យោងតាមមាត្រា៧ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ សមាគមសម្គាល់ភូមិសាស្ត្រ[57] សំដៅដល់ ក្រុមតំណាងផលិតករ អង្គភាពផលិតករ និង/ឬប្រតិបត្តិករ ដែលទទួលផលប្រយោជន៍ពី

[57] ប្រការ៣ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដូចមានចែងក្នុងមាត្រា៧ នៃច្បាប់ និងត្រូវបានទទួលស្គាល់ជាម្ចាស់នៃម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួច។ ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា ត្រូវធ្វើតាមរយៈសមាគមសម្គាល់ភូមិសាស្ត្រទំនិញ (Geographical Indication Organization/GIO)។ អ្នកដាក់ពាក្យស្នើសុំ គឺជាម្ចាស់សិទ្ធិលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្រោយការចុះបញ្ជី។ ដូច្នេះហើយ អ្នកដាក់ពាក្យស្នើសុំត្រូវផ្តល់ភស្តុតាងបញ្ជាក់ពីលទ្ធភាពរបស់ខ្លួន ដើម្បីការពារ និងគ្រប់គ្រងម៉ាកសម្គាល់ភូមិសាស្ត្រ[58]។

### ក.១.១. ក្រុមផលិតករ ប្រតិបត្តិករ ស្ថាប័ន និង/ឬបុគ្គលពាក់ព័ន្ធ

ក្រុមផលិតករ ប្រតិបត្តិករ ស្ថាប័ន និង/ឬបុគ្គលពាក់ព័ន្ធ ដែលមានបំណងចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា ត្រូវរៀបចំបង្កើតជាសមាគមសម្គាល់ភូមិសាស្ត្រទំនិញ ដោយផ្អែកលើតំបន់ភូមិសាស្ត្រ និងមុខទំនិញមួយ ហើយត្រូវមានលក្ខន្តិកៈដើម្បីគ្រប់គ្រង និងចាត់ចែងការងាររបស់ខ្លួនក្នុងគោលដៅមិនរកប្រាក់ចំណេញ។ សមាជិកភាពរបស់សមាគមត្រូវមានលក្ខណៈបើកចំហ។ សមាគមសម្គាល់ភូមិសាស្ត្រទំនិញត្រូវមានការទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច។ លក្ខន្តិកៈរបស់សមាគមត្រូវយកមកតម្កល់នៅក្រសួងពាណិជ្ជកម្ម។ សមាគមត្រូវធានាឱ្យសមាជិករបស់ខ្លួនអនុវត្តតាមសៀវភៅបន្ទុក និងកាតព្វកិច្ចផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន[59]។

សមាគមសម្គាល់ភូមិសាស្ត្រ ដែលជាអ្នកមានសិទ្ធិក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនទៀត ក្នុងគោលបំណងឱ្យស្ថាប័នដែលមានសមត្ថកិច្ចក្នុងការទទួលពាក្យស្នើសុំនេះ (នាយកដ្ឋានកម្មសិទ្ធិបញ្ញា) ។ លក្ខខណ្ឌដែលត្រូវបំពេញ[60]មានដូចជា៖ **(ក)** ព្រាងសៀវភៅបន្ទុកចូលរួមចំណែកដល់ការអនុវត្តតាមសៀវភៅបន្ទុកពីបណ្តាផលិតករ សមាជិក និងប្រតិបត្តិ ព្រមទាំងចូលរួមក្នុងការអនុវត្តផែនការត្រួតពិនិត្យជាពិសេសការត្រួតពិនិត្យផ្ទៃក្នុង **(ខ)** តម្កល់ទុកបញ្ជីផលិតករ និង/ឬប្រតិបត្តិករនៃម៉ាកសម្គាល់ភូមិសាស្ត្រ ហើយត្រូវបញ្ជូនបញ្ជីនោះទៅអង្គភាពត្រួតពិនិត្យ និងនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម និង **(គ)** ចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រ ជាពិសេសឈ្មោះ និងដែនដី ការវាយតម្លៃអំពីផលិតផល ព្រមទាំងចំណេះដឹងផ្នែកស្ថិតិនៃចង្វាក់តម្លៃ។

ទន្ទឹមនឹង អ្នកដាក់ពាក្យស្នើសុំ ត្រូវតែផ្តល់នូវឯកសារមួយចំនួនបន្ថែមទៀត នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីមកកាន់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដើម្បីឱ្យនាយកដ្ឋានកាន់តែជឿជាក់ ថាអ្នកដាក់ពាក្យស្នើសុំ ពិតជាសមាគមសម្គាល់ភូមិសាស្ត្រស្របច្បាប់។ ឯកសារបន្ថែម[61] ទាំងនោះរួមមាន៖ **(ក)** វិធាន និងបទបញ្ជាគ្រប់គ្រងផ្ទៃក្នុងរបស់

---

[58] ប្រការ៥ ចំណុចទី១ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[59] មាត្រា៧ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[60] ប្រការ៥ ចំណុចទី១ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[61] ប្រការ៥ ចំណុចទី២ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

អង្គភាព ឬសមាគម ប្រសិនបើមានព័ត៌មានដែលប្រើប្រាស់សម្រាប់វាយតម្លៃលើភាពជាអ្នកតំណាងនៃផលិតករ និង/ឬប្រតិបត្តិករ ហើយទ្រង់ទ្រាយតំណាងឱ្យប្រភេទផ្សេងៗគ្នានៃប្រតិបត្តិករសម្រាប់ផលិតផល ដែលកំពុងស្នើសុំ ត្រូវឱ្យមានតុល្យភាពនឹងគ្នា (ខ) ព័ត៌មានស្តីពីអង្គភាព និងធនធាន ដែលបានលះបង់ចំពោះកិច្ចការដូចបានកំណត់ ក្នុងកថាខណ្ឌ១ នៃប្រកាសនេះ និង (គ) អនុវត្តតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ។

លើសពីនេះ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម អាចតម្រូវឱ្យអ្នកស្នើសុំផ្តល់ព័ត៌មានបន្ថែមទៀត[62] ដើម្បីពិចារណាអំពីការទទួលស្គាល់សមាគម ហើយប្រតិបត្តិករទាំងនោះ ត្រូវមានឆន្ទៈអនុវត្តតាមវិធាននៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយមិនត្រូវបង្កឧបសគ្គដល់ការចូលរួម ដែលនាំឱ្យមានការរើសអើង ឬលើកលែងតែមានគោលដៅផ្ទុយពីនេះ។

### ក.១.២. ផលិតករ ឬប្រតិបត្តិករតែមួយ

ប្រតិបត្តិករ សំដៅដល់បុគ្គលដែលពាក់ព័ន្ធនៅក្នុងដំណើរការប្រមូលទិញកែច្នៃធ្វើពាណិជ្ជកម្ម ឬចែកចាយទំនិញសម្គាល់ភូមិសាស្ត្រ។ ក្នុងករណីដែលរូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ អាចត្រូវបានចាត់ទុកជាសមាគមសម្គាល់ភូមិសាស្ត្រ ឬក្រុមបាន លុះត្រាតែសមាគមនោះបានបំពេញលក្ខខណ្ឌទាំងពីរ[63]ដូចជា៖ (ក) បុគ្គលពាក់ព័ន្ធជាផលិតករតែម្នាក់គត់ ដែលមានឆន្ទៈក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជី និង (ខ) ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រ តំបន់ភូមិសាស្ត្រដែលបានកំណត់ត្រូវមានចរិតលក្ខណៈដែលធ្វើឱ្យខុសគ្នាដាច់ពីបណ្តាតំបន់ភូមិសាស្ត្រជិតខាង ឬចរិតលក្ខណៈនៃផលិតផល ត្រូវមានលក្ខណៈខុសពីផលិតផលក្នុងបណ្តាតំបន់ជិតខាងនោះ។ លើសពីនេះ សមាគមសម្គាល់ភូមិសាស្ត្រ ឬក្រុម ដែលស្ថិតក្រោមស្ថានភាពបែបនេះនៅតែចំហរចំពោះផលិតករ ឬប្រតិបត្តិករថ្មី ដែលមានឆន្ទៈអនុវត្តតាមវិធាននៃម៉ាកសម្គាល់ភូមិសាស្ត្រ។

### ក.២. សៀវភៅបន្ទុក

សៀវភៅបន្ទុក (Book of Specification) សំដៅដល់ឯកសារកំណត់យ៉ាងច្បាស់លាស់នូវចំណុចសំខាន់ៗ អំពីតំបន់ភូមិសាស្ត្រនៃការផលិត លក្ខខណ្ឌនៃការផលិត និងដំណើរការត្រួតពិនិត្យគុណភាព ទំនិញសម្គាល់ភូមិសាស្ត្រជាដើម ដែលចងក្រងឡើងដោយអ្នកដាក់ពាក្យស្នើសុំ[64]។ សៀវភៅបន្ទុកនេះ នឹងត្រូវបានធ្វើការត្រួតពិនិត្យនៅក្នុងនីតិវិធីត្រួតពិនិត្យពាក្យសុំចុះបញ្ជី និងនីតិវិធីត្រួតពិនិត្យខ្លឹមសារនៃពាក្យសុំចុះបញ្ជី ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញា

[62] ប្រការ៥ ចំណុចទី៣ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[63] ប្រការ៦ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[64] ប្រការ៤ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

នៃក្រសួងពាណិជ្ជកម្ម[65] ។ ម៉ាកសម្គាល់ភូមិសាស្ត្រ ត្រូវអនុវត្តឱ្យស្របតាមខ្លឹមសារនៃសៀវភៅបន្ទុក[66] ដែលមានចំណុចសំខាន់ៗដូចជា៖ (១) ឈ្មោះដែលត្រូវការពារម៉ាកសម្គាល់ភូមិសាស្ត្រ នៅពេលដែលឈ្មោះនោះត្រូវបានប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម ឬជាភាសាទូទៅ (២) សេចក្តីពិពណ៌នាអំពីផលិតផលសម្រាប់ម៉ាកសម្គាល់ភូមិសាស្ត្រ ដែលត្រូវស្នើសុំចុះបញ្ជីរួមមាន៖ វត្ថុធាតុដើម ចរិតលក្ខណៈសំខាន់ៗផ្នែករូបរាង គីមី អតិសុខុមជីវសាស្ត្រ ឬសរីរៈវិញ្ញាណនៃផលិតផល ប្រសិនបើសមស្រប (៣) ការកំណត់តំបន់ភូមិសាស្ត្រ ត្រូវកំណត់ព្រំដែនដោយផ្អែកទៅលើចំណុចទាក់ទង ដូចមានចែងក្នុងចំណុច៦ នៃកថាខណ្ឌនេះ (៤) ភស្តុតាងដែលបញ្ជាក់ថា ផលិតផលនោះមានប្រភពក្នុងតំបន់ភូមិសាស្ត្រដែលបានកំណត់ (៥) សេចក្តីពិពណ៌នាអំពីវិធីសាស្ត្រក្នុងការទទួលបានផលិតផល (៦) សេចក្តីពិពណ៌នាលម្អិតដែលបង្កើតចំណងទាក់ទងរវាង គុណភាពដែលទទួលបានកិត្តិសព្ទ ឬចរិតលក្ខណៈផ្សេងទៀតនៃផលិតផល និងប្រភពភូមិសាស្ត្រដើម (៧) ឈ្មោះ និងអាសយដ្ឋានរបស់អង្គភាព ដែលពិនិត្យផ្ទៀងផ្ទាត់ភាពអនុលោមទៅនឹងបទប្បញ្ញត្តិនានានៃសៀវភៅបន្ទុកផលិតផល (៨) វិធីសាស្ត្រដែលប្រើប្រាស់ ដើម្បីត្រួតពិនិត្យផលិតផល ដោយផ្អែកទៅតាមដំណើរការនៃផលិតកម្ម និងអនុលោមតាមវិធានទូទៅដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម (៩) វិធានស្តីពីការដាក់ស្លាកសញ្ញាជាក់លាក់ណាមួយ លើផលិតផលសម្គាល់ភូមិសាស្ត្រ និង (១០) ព័ត៌មានផ្សេងៗទៀត ប្រសិនបើចាំបាច់។

### ក.៣. ការត្រួតពិនិត្យអនុលោមភាព

ការត្រួតពិនិត្យអនុលោមភាព (Control and Traceability) សំដៅដល់ការផ្ទៀងផ្ទាត់អនុលោមភាពរបស់ផលិតផលជាមួយនឹងសៀវភៅបន្ទុក ដោយសមាគមសម្គាល់ភូមិសាស្ត្រទំនិញ និងអង្គភាពចេញវិញ្ញាបនបត្រ ឬអាជ្ញាធរដែលត្រូវបានចាត់តាំង[67] ។ ការត្រួតពិនិត្យអនុលោមភាព ធ្វើឡើងក្នុងគោលបំណងដើម្បីធានាឱ្យបានថារាល់ទំនិញទាំងអស់ដែលបានដាក់លក់នៅទីផ្សារក្នុងនាមជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបានផលិតនៅក្នុងតំបន់ដែលត្រូវបានកំណត់ ព្រមទាំងបានគោរពទៅតាមសៀវភៅបន្ទុកបានយ៉ាងត្រឹមត្រូវ[68]។

នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ជាអាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរទទួលបន្ទុកត្រួតពិនិត្យជាផ្លូវការ ដើម្បីផ្ទៀងផ្ទាត់ដោយអនុលោម តាមលក្ខខណ្ឌតម្រូវស្របច្បាប់ ដែលទាក់ទងនឹងគម្រោងផែនការម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ អាជ្ញាធរដែលមានសមត្ថកិច្ច ត្រូវផ្តល់កិច្ចធានាឱ្យបានគ្រប់គ្រាន់នូវភាពត្រឹមត្រូវ និងមិនលំអៀង ហើយត្រូវមានមន្ត្រីជំនាញដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងធនធានចាំបាច់ដើម្បីអនុវត្ត

[65] ពាក់ព័ន្ធនឹងចំណុចនេះ សូមមើលបន្ថែមនៅក្នុងចំណុច ខ.៣ និងខ.៤ នៃនីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅផ្នែកខាងក្រោម

[66] ប្រការ១០ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[67] ប្រការ៤ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[68] Jean-Marie Brun, *"The five pillars of a Protected Geographical Indication"*, GRET Cambodia, 2019, និង *"Protected Geographical Indication in Cambodia"*, Ministry of Commerce and Ministry of Agriculture, Forestry and Fishery, page 2, May 2010, ចូលមើលថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០

តួនាទីរបស់ខ្លួន[69]។ ការត្រួតពិនិត្យ ត្រូវផ្ទៀងផ្ទាត់ថាផលិតផលនោះបានផលិតដោយអនុលោមតាមសៀវភៅបន្ទុក និងត្រូវពិនិត្យតាមដានអំពីការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានចុះបញ្ជីរួច ដើម្បីពិពណ៌នាផលិតផលដែលបានដាក់លក់លើទីផ្សារ[70]។

លើសពីនេះ អ្នកដាក់ពាក្យស្នើសុំ អាចជ្រើសរើសអង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យដែលមានចុះបញ្ជីស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា និងមានការទទួលស្គាល់ពីក្រសួងពាណិជ្ជកម្ម។ អង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យ ជាអាជ្ញាធរសាធារណៈមានសមត្ថកិច្ច ឬអង្គភាពឯកជនដែលទទួលស្គាល់ជាផ្លូវការដោយអង្គការស្តង់ដារអន្តរជាតិ ឬស្ថាប័នណាមួយដែលមានប្រព័ន្ធត្រួតពិនិត្យអាចជឿជាក់[71]។ ការទទួលស្គាល់ត្រូវធ្វើឡើងដោយ អង្គភាពទទួលស្គាល់ថ្នាក់ជាតិ និងអង្គភាពទទួលស្គាល់ក្រៅពីព្រះរាជាណាចក្រកម្ពុជា ដែលជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងទទួលស្គាល់ជាពហុភាគី ក្រោមវេទិកាទទួលស្គាល់ជាអន្តរជាតិ[72]។ អង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យត្រូវផ្ញើរបាយការណ៍ប្រចាំឆ្នាំ ជូនក្រសួងពាណិជ្ជកម្ម ជារៀងរាល់ឆ្នាំដោយរាប់បញ្ចូលនូវបញ្ជីឈ្មោះផលិតករ ប្រតិបត្តិករផលិតផលបរិមាណដែលខ្លួនបានបញ្ជាក់ទទួលស្គាល់ និងវិធានការដែលបានដាក់ ចេញប្រសិនបើមាន។ ក្រសួងពាណិជ្ជកម្ម ជាអ្នកកំណត់កាលបរិច្ឆេទនៃការផ្តល់របាយការណ៍ ដោយផ្អែកតាមរដូវប្រមូលផល ឬចុងការិយបរិច្ឆេទ។ ចំពោះឯកសារ ក្រៅពីភាសាខ្មែរត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាខ្មែរដោយមានការបញ្ជាក់ពីភាពត្រឹមត្រូវ[73]។

ប្រសិនបើមានភាពមិនច្បាស់លាស់ត្រង់ចំណុចណាមួយ ក្រសួងពាណិជ្ជកម្មអាចអញ្ជើញម្ចាស់សិទ្ធិ ឬបុគ្គលដែលមានការពាក់ព័ន្ធមកផ្តល់ការពន្យល់ ឬផ្តល់ភស្តុតាងបន្ថែម។ ក្នុងករណីចាំបាច់ក្រសួងពាណិជ្ជកម្ម អាចស្នើសុំមតិពីអ្នកជំនាញក្នុងវិស័យពាក់ព័ន្ធ ដើម្បីធ្វើការពិនិត្យពិចារណា និងសម្រេច។ ជាពិសេស ក្នុងករណីដែលផលិតករ ឬប្រតិបត្តិករណាមួយ ឬច្រើន មិនបានបំពេញតាមលក្ខខណ្ឌនៅក្នុងសៀវភៅបន្ទុក អង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យត្រូវរាយការណ៍ជូនក្រសួងពាណិជ្ជកម្ម ដើម្បីដាក់ចេញនូវវិធានការសមស្របដូចជា៖ (១) ធ្វើការកត់សម្គាល់កំហុស និងណែនាំ (២) ព្រមាន (៣) បដិសេធទទួលស្គាល់ឡូត៍ណាមួយនៃផលិតផល (៤) មិនទទួលស្គាល់សិទ្ធិនៃការប្រើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជាបណ្តោះអាសន្ន និង (៥) ហាមឃាត់ជាស្ថាពរការប្រើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ[74]។

69 ប្រការ៣៥ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

70 ប្រការ៣៦នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

71 មាត្រា២៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

72 ប្រការ៣៧ ចំណុចទី៣ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

73 មាត្រា២៦ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

74 មាត្រា២៦ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យមើលពីប្រសិទ្ធភាពរបស់អង្គភាពដែលចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យ។ ក្នុងករណីគ្មានប្រសិទ្ធភាព ក្រសួងពាណិជ្ជកម្ម មានអំណាចបដិសេធជាលាយលក្ខណ៍អក្សរ ដោយមានសំអាងហេតុចំពោះអង្គភាពដែលចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យ និងអាចឱ្យអ្នកដាក់ពាក្យស្នើសុំជ្រើសរើសអង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យថ្មី[75]។ មូលហេតុដែលក្រសួងពាណិជ្ជកម្ម អាចបដិសេធទៅលើអង្គភាពទាំងនេះ គឺដោយសារតែអង្គភាពត្រួតពិនិត្យ និងចេញវិញ្ញាបនបត្រ ត្រូវទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម ដែលជាស្ថាប័នមានសមត្ថកិច្ច[76]។

### ក.៤. ការកំណត់ព្រំដែន

លក្ខណៈពិសេសរបស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺផ្តោតសំខាន់ទៅលើភូមិសាស្ត្រដែលវត្ថុធាតុដើមនោះស្ថិតនៅជាកត្តាសំខាន់ ដែលនាំឱ្យជះឥទ្ធិពលទៅលើគុណភាពរបស់ផលិតផល។ ការកំណត់ព្រំដែន (Delimitation) នៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺមានសារៈសំខាន់ ដែលអាចឱ្យយើងកំណត់យកតំបន់ណាមួយជាក់លាក់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចធ្វើឱ្យដំណាំ ឬវត្ថុធាតុដើមទទួលបាននូវគុណភាពខ្ពស់តាមលក្ខខណ្ឌកំណត់។ ដើម្បីធ្វើការកំណត់ព្រំដែន ត្រូវពិចារណាទៅលើលក្ខខណ្ឌមួយចំនួនដូចជា ដី អាកាសធាតុ ការផ្គត់ផ្គង់ទឹក ការប៉ះពន្លឺ លក្ខណៈដាំដុះ ពូជ ការប្រមូលផល ការកែច្នៃ ប្រវត្តិ និងកេរ្តិ៍ឈ្មោះជាដើម។

លើសពីនេះ ការដាក់ឈ្មោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺប្រើប្រាស់បានតែផលិតករ ឬប្រតិបត្តិករនៅក្នុងតំបន់ដែលត្រូវកំណត់ព្រំដែនតែប៉ុណ្ណោះ។ **ឧទាហរណ៍៖** ការដាក់ឈ្មោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញលើ "ក្រូចថ្លុងកោះទ្រង់" គឺប្រើប្រាស់បានតែសមាគមអ្នកដាំក្រូចថ្លុងកោះទ្រង់ក្រចេះ តែប៉ុណ្ណោះ ដែលមានសមាជិកជាផលិតករ និងអាជីវករសរុបចំនួន១៥៥គ្រួសារ មកពីសង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ[77]។

### ក.៥. ឯកសារបញ្ជាក់ភស្តុតាង

ដើម្បីឱ្យទទួលបាននូវការទទួលស្គាល់នោះ គឺទាមទារនូវភស្តុតាងជាចាំបាច់ សម្រាប់ធ្វើជាអំណះអំណាង។ ជាក់ស្តែង ប្រសិនបើចុះបញ្ជីផលិតផលណាមួយទៅក្នុងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះ ត្រូវបង្ហាញនូវឯកសារបញ្ជាក់ពីភស្តុតាង (A Proven Link Document) ដើម្បីឱ្យដឹងច្បាស់ថា ទំនិញនោះពិតជាមានលក្ខណៈគ្រប់គ្រាន់អាចក្លាយជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ ឯកសារដែលត្រូវធ្វើការបញ្ជាក់ភស្តុតាងអាចយោងទៅតាមប្រវត្តិសាស្ត្រ កេរ្តិ៍ឈ្មោះ កត្តាធម្មជាតិ កត្តាភូមិសាស្ត្រ ឬកត្តាមនុស្សសាស្ត្រជាដើម។ កេរ្តិ៍ឈ្មោះ អាចសំដៅដល់ភាពល្បីល្បាញ ដែលទទួលបានពីទំនិញសម្គាល់ភូមិសាស្ត្រនៅក្នុងទីផ្សារ និងនៅក្នុងសង្គម ដោយចេញពីអ្នកប្រើប្រាស់

---

[75] មាត្រា២៧ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[76] ប្រការ៣៩ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[77] *"ក្រូចថ្លុងកោះទ្រង់ក្លាយជាផលិតផលសម្គាល់ភូមិសាស្ត្រ"*, កោះសន្តិភាព, មិថុនា ២០១៨, https://bit.ly/2YiUVrT, ចូលមើលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០

ទំនិញ ផ្អែកលើប្រវត្តិ និងប្រពៃណីនៃការប្រើប្រាស់។ **ឧទាហរណ៍៖** ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញស្ករត្នោតកំពង់ស្ពឺ ឈ្មោះ "កំពង់ស្ពឺ" មានជាប់ទាក់ទងនឹងផលិតកម្មស្ករ ដែលគេស្គាល់ថាជាផលិតផលប្រពៃណីនៃតំបន់នេ[78]។ ប្រវត្តិរបស់ផលិតផល គឺជាផ្នែកមានសារៈសំខាន់សម្រាប់ការពិចារណាដើម្បីកំណត់តំបន់ផលិតកម្ម មានប្រវត្តិជាប់ទាក់ទងនឹងផលិតផល ហើយប្រវត្តិក៏រួមចំណែកដល់ការពង្រឹងកម្មសិទ្ធិផលិតផលរបស់ដែនដីមួយផងដែរ ហេតុនេះ អត្តសញ្ញាណតំបន់នឹងផ្តល់នូវហេតុផលស្របសម សម្រាប់ការទទួលស្គាល់ពីខាងក្រៅផ្តល់នូវភស្តុតាងបញ្ជាក់ពីចំណងតភ្ជាប់រវាងផលិតផលជាមួយនឹងដែនដី។ **ឧទាហរណ៍៖** ផលិតកម្មម្រេចនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានពិពណ៌នានៅក្នុងឯកសារចំណាស់មួយរបស់ជនជាតិចិន គឺលោក Tchéou Ta Kouan នៅសតវត្សទី១៣។ ម្រេចបាននាំចូលមកក្នុងប្រទេសកម្ពុជា និងរីកដុះដាល នៅក្នុងខេត្តកំពតចាប់ផ្តើមពីសតវត្សទី១៩ និងរីកដុះដាលខ្លាំងនៅពាក់កណ្តាលសតវត្សទី២០[79]។

លើសពីនេះ កត្តាមនុស្ស គឺសំដៅលើជំនាញ និងទេពកោសល្យរបស់ផលិតករក្នុងការផលិតដែលទាក់ទងទៅនឹងចំណេះដឹង ចំណេះធ្វើ ភាពប៉ិនប្រសប់ និងការច្នៃប្រឌិតរបស់ផលិតករ ដែលបន្សល់ទុកតាំងពីជំនាន់មុនមកម្ល៉េះ។ **ឧទាហរណ៍៖** ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញលើសូត្រថៃ (Thai Silk)[80] ជាផលិតផលដែលត្រូវបានផលិតចេញពីដៃរបស់សិប្បករ និងប្រើប្រាស់នូវបច្ចេកទេសផលិតបែបលក្ខណៈប្រពៃណី ដែលមានតាំងពីរាប់រយឆ្នាំមកម្ល៉េះ។ ចំពោះលក្ខខណ្ឌធម្មជាតិ និងកត្តាភូមិសាស្ត្រវិញ គឺក៏ជាចំណុចសំខាន់មួយដែលធ្វើឱ្យគុណភាពរបស់ផលិតផលនៃតំបន់មួយខុសពីតំបន់មួយទៀត។ **ឧទាហរណ៍៖** កំពង់ស្ពឺជាតំបន់ខ្ពង់រាប មិនលិចទឹកនៅរដូវវស្សា ហើយជាតំបន់ដែលសម្បូរទៅដោយដីខ្សាច់មានស្រទាប់ជ្រៅ។ តាមការសិក្សា និងវិភាគទៅលើទឹកត្នោតនៅក្នុងតំបន់ដទៃទៀតដែលមាននៅក្នុងប្រទេសកម្ពុជា គឺមានតែស្រុកចំនួន ០៣ប៉ុណ្ណោះ (ស្រុកឧដុង្គ និងស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងស្រុកអង្គស្នួល ខេត្តកណ្តាល) ដែលមានទឹកត្នោតមានកម្រិតស្ករខ្ពស់ជាងគេ។ ម្យ៉ាងទៀត នៅតំបន់នេះ ទឹកភ្លៀងមានកម្រិតទាបដែលជាមធ្យម ១,២០០ មម/ឆ្នាំ ហើយចំនួនថ្ងៃដែលមានភ្លៀងជាមធ្យម ១០៥ថ្ងៃក្នុង១ឆ្នាំ ហើយតំបន់នេះ គឺជាតំបន់ដែលមានកម្រិតទឹកភ្លៀងទាបជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាពិសេស ដើមត្នោតដែលអាចផ្តល់ទឹកត្នោតសម្រាប់ផលិត "ស្ករត្នោតកំពង់ស្ពឺ" ត្រូវស្ថិតនៅក្នុងស្រុកទាំង៣ខាងលើ ហើយត្រូវស្ថិតនៅលើប្រភេទដីខ្សាច់ដែលមានជម្រៅយ៉ាងតិច ៨០ សង់ទីម៉ែត្រ នៅបាតក្រោមមានគ្រួស និងជាប្រភេទដីស

78 *"Single document of Skor Thont Kampong Speu"*, Official Journal of European Union, October 2017, ចូលមើលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០

79 *"Single Document of Mrech Kampot"*, Department of Intellectual Property Rights, 2010, ចូលមើលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០

80 *"Geographical Indications: An Introduction"*, WIPO, 2017, P.19, ចូលមើលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០

ម្រោះទឹកល្អ[81]។ ទន្ទឹមនឹងនេះ ទិន្នន័យប្រវត្តិសាស្ត្រ និងប្រភពឯកសារកត់ត្រា (អត្ថបទស្រាវជ្រាវ ច្បាប់ និងសៀវភៅមុខម្ហូប) ព្រមទាំងប្រភពចេញពីមាត់ ដូចជា រឿងព្រេង និងការនិទានផងដែរ ការលើកឡើងនូវទំនិញ និងប្រភពភូមិសាស្ត្រពីអតីតកាល គឺជាផ្តល់នូវហេតុផល ក៏ដូចជាភស្តុតាងដ៏សំខាន់មួយអំពីឫសគល់នៃផលិតផល។ ប៉ុន្តែគ្រប់ឯកសារបញ្ជាក់ភស្តុតាង គឺចាំបាច់ត្រូវតែមានការបញ្ជាក់ពីអ្នកវិទ្យាសាស្ត្រ ឬអ្នកជំនាញដែលជាប់ព័ន្ធពាក់។

## ខ. នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ការចុះបញ្ជីសម្គាល់ភូមិសាស្ត្រទំនិញ គឺមានផលលំបាកមួយចំនួន និងត្រូវចំណាយពេលវេលាយូរ ក្នុងការសម្រេចយកផលិតផលណាមួយឱ្យក្លាយទៅជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ នៅកម្ពុជាមានផលិតផលមួយចំនួន ដែលត្រូវបានចុះបញ្ជីការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដូចជា ម្រេចកំពត ស្ករត្នោតកំពង់ស្ពឺ និងក្រូចថ្លុងកោះទ្រង់ ហើយក្រសួងពាណិជ្ជកម្ម គ្រោងនឹងដាក់បញ្ចូលផលិតផលរហូត ២០មុខផ្សេងទៀត[82] ចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម បានបញ្ជាក់ថា[83] "ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ លើផលិតផលណាមួយ គឺត្រូវចំណាយពេលវេលាយូរ ជាក់ស្តែងក្រូចថ្លុងកោះទ្រង់ខេត្តក្រចេះ បានប្រើរយៈពេលប្រហែល២ឆ្នាំ ដើម្បីសិក្សាលម្អិត ហើយប្រើប្រាស់ថវិកាប្រមាណជាងកន្លះលានដុល្លារអាមេរិក មុនទទួលបានការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ"។ ដូច្នេះហើយ ផលិតផលមួយ អាចត្រូវបានចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវគោរពតាមនីតិវិធីដូចខាងក្រោមនេះ៖

### ខ.១. ការដាក់ពាក្យស្នើសុំចុះបញ្ជី

ការដាក់ពាក្យស្នើសុំចុះបញ្ជី[84] គឺជាដំណាក់កាលដំបូងនៃនីតិវិធីស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ នៅក្នុងដំណាក់កាលនេះ អ្នកដាក់ស្នើសុំចុះបញ្ជី ឬភ្នាក់ងារតំណាង ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម[85]។ ពាក្យស្នើសុំចុះបញ្ជីត្រូវធ្វើជាភាសាខ្មែរ ឬភាសាអង់គ្លេស។ ឯកសារតម្រូវសម្រាប់ការស្នើសុំចុះបញ្ជី ប្រសិនបើមិនបានធ្វើឡើងជាភាសាខ្មែរ ឬ

---

[81] *"Single document of Skor Thont Kampong Speu"*, Official Journal of European Union, October 2017, ចូលមើលថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០២០

[82] *"ផ្កាអំបិលកំពត និងក្រូចថ្លុងខេត្តក្រចេះនឹងដាក់ចូលជាផលិតផលសម្គាល់ភូមិសាស្ត្រឆាប់ៗនេះ"*, ខេមបូណ្ឌមីស, ២០១៨, https://bit.ly/2BlJzKX, ចូលមើលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០

[83] *"ក្រសួងពាណិជ្ជកម្មគ្រោងយកក្រូចពោធិ៍សាត់ទៅចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ"*, Fresh News, កុម្ភៈ ២០១៩, https://bit.ly/3fICYcd, ចូលមើលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០

[84] មាត្រា៨ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[85] ប្រការ៨ ចំណុចទី១ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ភាសាអង់គ្លេស ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាខ្មែរ ឬភាសាអង់គ្លេស[86]។ ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានឯកសារដូចតទៅ[87]៖

(ក) ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ

(ខ) ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ

(គ) ឈ្មោះម៉ាកសម្គាល់ភូមិសាស្ត្រ

(ឃ) គម្រូប្រភេទទំនិញដែលគ្រប់ដណ្តប់ដោយពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ

(ង) សៀវភៅបន្ទុកដូចមានចែងក្នុងប្រការ១០ នៃប្រកាសនេះ

(ច) សេចក្តីសង្ខេបនៃសៀវភៅបន្ទុក

(ឆ) វិក័យបត្របង់កម្រៃសេវា

(ជ) ឯកសារពាក់ព័ន្ធផ្សេងៗ ទៀតទាក់ទងនឹងការស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។

នៅក្នុងពាក្យស្នើសុំចុះបញ្ជីសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានព័ត៌មានសំខាន់ៗ[88] ដូចតទៅ៖

(ក) ព័ត៌មានពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដោយមន្ត្រីកាន់កាប់បញ្ជី

- សេចក្តីយោងរបស់មន្ត្រីត្រួតពិនិត្យ
- ភ្នាក់ងារតំណាងក្នុងស្រុកសម្រាប់ទំនាក់ទំនង
- កាលបរិច្ឆេទនៃការដាក់ពាក្យ
- លេខដាក់ពាក្យ

(ខ) ព័ត៌មានពាក់ព័ន្ធនឹងអ្នកដាក់ពាក្យស្នើសុំ

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ
- ឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារតំណាង ប្រសិនបើពាក្យស្នើសុំចុះបញ្ជីដាក់តាមរយៈភ្នាក់ងារតំណាង

(គ) ប្រភេទផ្សេងៗនៃពាក្យស្នើសុំ

- ពាក្យស្នើសុំចុះបញ្ជី
- ពាក្យស្នើសុំកែតម្រូវ ឬកែសម្រួលម៉ាកសម្គាល់ភូមិសាស្ត្រ
- ពាក្យស្នើសុំធ្វើមោឃភាព ឬលុបម៉ាកសម្គាល់ភូមិសាស្ត្រចេញពីបញ្ជី

[86] ប្រការ៨ ចំណុចទី២ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[87] ប្រការ៨ ចំណុចទី៣ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[88] ប្រការ៩ ចំណុចទី២ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

- ពាក្យស្នើសុំផ្សេងៗពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ

(ឃ) ឈ្មោះ និមិត្តសញ្ញា ឬសញ្ញានៃម៉ាកសម្គាល់ភូមិសាស្ត្រ

(ង) ប្រភេទទំនិញដែលត្រូវការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រ

(ច) សេចក្តីពិពណ៌នាអំពីផលិតផល

(ឆ) ជំពូកដែលទំនិញនោះស្ថិតនៅ (ទីក្រុងនីស)

(ជ) តំបន់ភូមិសាស្ត្រនៃម៉ាកសម្គាល់ភូមិសាស្ត្រ

(ឈ) សេចក្តីពណ៌នាអំពីវិធីសាស្ត្រនៃផលិតកម្ម

(ញ) ចំណុចសំខាន់ៗ ដែលមានចំណងទាក់ទងគ្នា រវាងផលិតផលសម្គាល់ភូមិសាស្ត្រ និងប្រភទភូមិសាស្ត្រដើម

(ដ) វិធីសាស្ត្រត្រួតពិនិត្យផលិតផលសម្គាល់ភូមិសាស្ត្រ

(ឋ) ព័ត៌មានពាក់ព័ន្ធនឹងការដាក់ស្លាកសញ្ញានៃផលិតផលសម្គាល់ភូមិសាស្ត្រ

(ឌ) ឯកសារនានាភ្ជាប់នឹងពាក្យស្នើសុំ

(ឍ) ឯកសារផ្សេងៗទៀត

(ណ) កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកដាក់ពាក្យស្នើសុំ

លើសពីនេះ បើយោងទៅតាមប្រកាសស្តីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិករបស់ក្រសួងពាណិជ្ជកម្ម គឺបានធ្វើឱ្យការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ កាន់តែមានភាពងាយស្រួលជាងមុន។ ការដាក់ពាក្យស្នើសុំចុះបញ្ជី តាមប្រព័ន្ធអេឡិចត្រូនិក តម្រូវឱ្យមានឈ្មោះគណនី និងលេខកូដសម្ងាត់ ដែលកំណត់ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម[89]។ អ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងដែលដាក់ពាក្យស្នើសុំតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវភ្ជាប់មកជាមួយឯកសារតម្រូវ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ជាទម្រង់អេឡិចត្រូនិក ហើយអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងត្រូវធានាថា រាល់ឯកសារតម្រូវភ្ជាប់ជាទម្រង់អេឡិចត្រូនិកដែលផ្តល់មកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ជាឯកសារពិត និងគតក្លែងបន្លំ[90]។

ក្រោយការដាក់ពាក្យស្នើសុំចុះបញ្ជី តាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តល់ឯកសារតម្រូវជាទម្រង់ច្បាប់ដើម ឬទម្រង់ច្បាប់ចម្លងដោយមានបញ្ជាក់ពីភាពត្រឹមត្រូវ មកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម[91]។ អ្នកដាក់

[89] ប្រការ៨ កថាខណ្ឌទី១ នៃប្រកាសស្តីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក

[90] ប្រការ៧ កថាខណ្ឌទី៣ និងទី៤ នៃប្រកាសស្តីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក

[91] ប្រការ៨ កថាខណ្ឌទី២ នៃប្រកាសស្តីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក

ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិច ត្រូវបង់កម្រៃសេវាតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារ ដោយអនុលោមតាមប្រកាសរួមលេខ ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០១៧ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត[92]។ ការដាក់ពាក្យស្នើសុំបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវបង់កម្រៃសេវាចំនួន ៤២០,០០០រៀល រយៈពេលអតិបរមានៃការផ្តល់សេវាចន្លោះពី៦ខែ ទៅ ១២ខែ[93] (ពាក់ព័ន្ធនឹងគម្រូនៃពាក្យស្នើសុំចុះបញ្ជី សូមមើលឧបសម្ព័ន្ធ២)។

## ខ.២. ការដកពាក្យស្នើសុំចុះបញ្ជី

ការដាក់ពាក្យស្នើសុំចុះបញ្ជី គឺដើម្បីទទួលបានការការពារដ៏ពិតប្រាកដ និងស្របច្បាប់យ៉ាងណា ការដាក់ ឬ ដកពាក្យស្នើសុំ គឺជាសិទ្ធិសេរីភាពរបស់អ្នកដាក់ពាក្យស្នើសុំ។ ពាក្យស្នើសុំដែលបានដាក់រួចហើយ បើអ្នកដាក់ពាក្យស្នើសុំ យល់ថាខ្លួនមិនចង់ចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្ររបស់ខ្លួនទៀត ឬប្រសិនបើអ្នកដាក់ពាក្យស្នើសុំ យល់ថាស្នាដៃដែលខ្លួនផលិតនោះមានបញ្ហា ឬនៅតែមិនទាន់មានការជឿជាក់ថាផលផលិតអាចនឹងទទួលបានការការពារនោះអ្នកដាក់ពាក្យស្នើសុំអាចដកពាក្យស្នើសុំនៅពេលណាក៏បាន ដោយជូនដំណឹងពីការសម្រេចរបស់ខ្លួនជាលាយលក្ខណ៍អក្សរ មកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម[94]។ ក្នុងករណីដែលពាក្យស្នើសុំត្រូវបានដកនោះ រាល់កម្រៃសេវាដែលបានបង់មកក្រសួងពាណិជ្ជកម្ម មិនអាចដកវិញបានឡើយ[95]។

## ខ.៣. ការត្រួតពិនិត្យពាក្យស្នើសុំចុះបញ្ជី

ក្រោយពីអ្នកដាក់ពាក្យស្នើសុំ បានដាក់ពាក្យស្នើសុំរួចហើយ នីតិវិធីបន្ទាប់ គឺការត្រួតពិនិត្យពាក្យស្នើសុំចុះបញ្ជីដែលជាភារកិច្ចរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យពាក្យស្នើសុំ និងត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ[96]។ នាយកដ្ឋានកម្មសិទ្ធិបញ្ញានឹងធ្វើការផ្ទៀងផ្ទាត់ពាក្យស្នើសុំនេះ ត្រឹមត្រូវតាមលក្ខខណ្ឌ ដែលច្បាប់កំណត់ដែរឬទេ ហើយបន្ទាប់ពីពិនិត្យឃើញថា ពាក្យស្នើសុំចុះបញ្ជីបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌទម្រង់ដែលបានកំណត់ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យស្នើសុំ

[92] ប្រការ៩ នៃប្រកាសស្តីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក

[93] ឧបសម្ព័ន្ធ ត្រង់លេខរៀងទី២៤ នៃប្រកាសរួមលេខ១២១៧ សហវ.ប្រកចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម

[94] ប្រការ១១ ចំណុចទី១ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[95] ប្រការ១១ ចំណុចទី២ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[96] មាត្រា៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

នោះ[97]។ គួរឱ្យកត់សម្គាល់ថា ការត្រួតពិនិត្យពាក្យស្នើសុំនេះ គឺពិនិត្យតែលើទម្រង់នៃពាក្យស្នើសុំប៉ុណ្ណោះ មិនមែនជាការត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំនោះទេ។

ផ្ទុយមកវិញ ក្នុងករណីពិនិត្យឃើញថាពាក្យស្នើសុំមិនបានបំពេញគ្រប់គ្រាន់តាមលក្ខខណ្ឌដែលបានកំណត់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវចេញលិខិតឱ្យអ្នកដាក់ពាក្យស្នើសុំ ដើម្បីធ្វើការបំពេញបន្ថែម ឬកែតម្រូវដោយបញ្ជាក់ពីចំណុចខ្វះខាត។ អ្នកដាក់ពាក្យស្នើសុំអាចធ្វើការបំពេញបន្ថែម ឬកែតម្រូវពាក្យស្នើសុំក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែគិតចាប់ពីថ្ងៃចេញលិខិត។ ពាក្យស្នើសុំចុះបញ្ជីនោះត្រូវចាត់ទុកថាបានបោះបង់ចោល ប្រសិនបើគ្មានការបំពេញបន្ថែម ឬការមិនបានផ្តល់នូវការឆ្លើយតប ឬការពន្យល់ជាវិជ្ជមានក្នុងរយៈពេលដែលបានកំណត់ខាងលើ។ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម អាចពន្យារពេលបន្ថែម ០៦ (ប្រាំមួយ)ខែទៀតសម្រាប់ការកែតម្រូវពាក្យស្នើសុំ ប្រសិនបើមានសំណូមពរសមហេតុផលពីអ្នកដាក់ពាក្យស្នើសុំ[98]។

នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យឯកសារបំពេញបន្ថែម ឬឯកសារកែតម្រូវនេះ និងត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃទទួលឯកសារបំពេញបន្ថែម ឬឯកសារកែតម្រូវនេះ[99]។ នៅពេលដែលនាយកដ្ឋានកម្មសិទ្ធិបញ្ញា ពិនិត្យឯកសារបន្ថែម ឬឯកសារកែតម្រូវ ហើយប្រសិនបើពាក្យស្នើសុំនោះបានបំពេញតាមលក្ខខណ្ឌទម្រង់ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យជាផ្លូវការ។ ប្រសិនបើពាក្យស្នើសុំមិនបានបំពេញតាមលក្ខខណ្ឌតម្រូវ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវធ្វើការបដិសេធ[100]។

### ខ.៤. ការត្រួតពិនិត្យខ្លឹមសារពាក្យស្នើសុំចុះបញ្ជី

ដំណាក់កាលនេះ គឺជាដំណាក់កាលដ៏សំខាន់ ដើម្បីឈានទៅដល់ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំ ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបំពេញតាមលក្ខខណ្ឌតម្រូវ និងការចេញលិខិតទទួលស្គាល់ការដាក់ពាក្យរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី[101]។ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំលើចំណុចសំខាន់ៗដូចជា៖ (១) ភាពត្រឹមត្រូវនៃព័ត៌មានលម្អិតក្នុងពាក្យស្នើសុំអាចមាន ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ ឈ្មោះទំនិញ និងតំបន់ភូមិសាស្ត្រ ប្រភេទទំនិញ និងចំណាត់ថ្នាក់ទំនិញ ការ

---

[97] មាត្រា៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងប្រការ១៣ ចំណុចទី១ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[98] មាត្រា៩ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[99] មាត្រា៩ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[100] ប្រការ១៣ ចំណុចទី២ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[101] ប្រការ១៤ ចំណុចទី១ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ពិពណ៌នាអំពីទំនិញ ព្រំដែននៃតំបន់ភូមិសាស្ត្រ ការពិពណ៌នាអំពីប្រព័ន្ធកត់ត្រាស្វែងរកតឹងតាង សេចក្ដីអធិប្បាយ និងឯកសារបញ្ជាក់ភស្តុតាង ជាដើម (២) ចំណុចទាំងឡាយដូចមានចែងក្នុងមាត្រា៤ ត្រង់ចំណុចនិយមន័យលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និង មាត្រា១០ (ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមិនអាចចុះបញ្ជីបាន) នៃច្បាប់នេះ (៣) ភាពជាក់ស្ដែងនៅមូលដ្ឋានផលិតកម្ម ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា និង (៤) ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលមានសូរសំឡេងដូចគ្នា ត្រូវអនុវត្តតាមលក្ខខណ្ឌដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម[102]។

ដូចបានលើកឡើងពីខាងលើនេះ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវតែត្រួតពិនិត្យទៅលើប្រភេទម៉ាកមួយចំនួនដែលត្រូវបានច្បាប់ចាត់ទុកថា ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមិនអាចចុះបញ្ជីបាន។ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមិនអាចចុះបញ្ជីបាន[103] ប្រសិនបើ៖ (ក) ម៉ាកនោះផ្ទុយនឹងច្បាប់ បទប្បញ្ញត្តិ តម្លៃសីលធម៌ សង្គមសាសនា ប្រពៃណីល្អរបស់ជាតិ ឬសណ្ដាប់ធ្នាប់សាធារណៈ (ខ) ម៉ាកនោះធ្វើឱ្យសាធារណជនយល់ខុស ឬភាន់ច្រឡំពីចរិតលក្ខណៈ ដូចជាប្រភេទ គុណភាព ទីកន្លែងនៃប្រភពដើមដំណើរការផលិត ឬការប្រើប្រាស់ (គ) ម៉ាកនោះត្រូវបានគេប្រើប្រាស់ជាឈ្មោះពូជដំណាំ ឬពូជសត្វ និង (ឃ) ម៉ាកនោះជានាមទូទៅ។ បន្ថែមទៀត ម៉ាកសម្គាល់ភូមិសាស្ត្រដែលមានសូរសំឡេងដូចគ្នា [104] ដែលបំភ័ន្តអ្នកប្រើប្រាស់ឱ្យជឿជាក់ថា ផលិតផលនោះមានប្រភពមកពីដែនដីផ្សេងទៀត មិនត្រូវអនុញ្ញាតឱ្យចុះបញ្ជីឡើយ ទោះបីឈ្មោះនោះមានពិតប្រាកដក្នុងដែនដី តំបន់ ឬទីកន្លែងប្រភពដើមជាក់ស្ដែងនៃផលិតផលនោះមែនក៏ដោយ។ ទន្ទឹងនឹងនេះ ឈ្មោះដែលបានស្នើសុំចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រ មិនត្រូវចុះបញ្ជីជូនឡើយ ក្នុងករណីការចុះបញ្ជីឈ្មោះដែលបានស្នើសុំនោះ អាចបំភ័ន្តអ្នកប្រើប្រាស់ចំពោះអត្តសញ្ញាណពិតនៃផលិតផល ដោយសារតែកិត្តិសព្ទ ភាពល្បី និងរយៈពេលនៃការប្រើប្រាស់ម៉ាកនោះ[105]។

ប្រសិនបើពាក្យស្នើសុំនោះ បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការចុះបញ្ជី ដូចដែលច្បាប់កំណត់ នោះនាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវធ្វើការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រនោះក្នុងបញ្ជី[106]។ ក្នុងការត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំ នាយកដ្ឋានកម្មសិទ្ធិបញ្ញា អាចអញ្ជើញអ្នកដាក់ពាក្យស្នើសុំ ឬបុគ្គលដែលមានការពាក់ព័ន្ធមកពន្យល់ ឬផ្ដល់ភស្តុតាងបន្ថែម។ ក្នុងករណីចាំបាច់នាយកដ្ឋានកម្មសិទ្ធិបញ្ញា អាចស្នើសុំមតិពីអ្នកជំនាញក្នុងវិស័យពាក់

---

[102] មាត្រា១១ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[103] មាត្រា១០ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[104] ប្រការ៣៤ នៃប្រកាសស្ដីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[105] ប្រការ១៨ នៃប្រកាសស្ដីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[106] ប្រការ១៤ ចំណុចទី២ នៃប្រកាសស្ដីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ព័ន្ធ ដើម្បីធ្វើការពិចារណា និងសម្រេច[107]។ លើសពីនេះ ក្នុងករណីដែលនាយកដ្ឋានកម្មសិទ្ធិបញ្ញាពិចារណាឃើញថា ពាក្យស្នើសុំណាមួយត្រូវបដិសេធ ឬតម្រូវឱ្យមានការកែសម្រួល នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ ឬការកែសម្រួលនោះ[108]។

អ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង អាចឆ្លើយតបដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេលមិនលើសពី ៩០ (កៅសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទទទួលបាននូវសេចក្តីជូនដំណឹងពីនាយកដ្ឋានកម្មសិទ្ធិបញ្ញា។ ប៉ុន្តែក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង មិនឆ្លើយតបទៅនឹងសេចក្តីជូនដំណឹង នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវធ្វើការបដិសេធពាក្យស្នើសុំនោះ[109]។ ផ្ទុយមកវិញ ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំ ឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្នុងរយៈពេលមិនលើសពី៣០ (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទទួលបាននូវការឆ្លើយតបនោះ ហើយនាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវធ្វើការត្រួតពិនិត្យពាក្យស្នើសុំឡើងវិញ និងធ្វើសេចក្តីសម្រេចក្នុងរយៈពេលមិនលើសពី៦ (ប្រាំមួយ) ខែគិតចាប់ពីកាលបរិច្ឆេទទទួលបាននូវការឆ្លើយតប[110]។

សម្គាល់៖ នៅក្នុងដំណាក់កាលនៃការត្រួតពិនិត្យខ្លឹមសារ ត្រូវតែធ្វើការបង់កម្រៃសេវា តាមការកំណត់នៃបទប្បញ្ញត្តិគតិយុត្តដែលនៅជាធរមាន[111]។ ប៉ុន្តែក្នុងករណីពាក្យស្នើសុំត្រូវបានបដិសេធរាល់កម្រៃសេវាដែលបានបង់មកក្រសួងពាណិជ្ជកម្ម មិនអាចដកវិញបានឡើយ[112]។ លើសពីនេះ ក្នុងករណីកម្រៃនៃការត្រួតពិនិត្យខ្លឹមសារមិនត្រូវបានបង់ ពាក្យស្នើសុំត្រូវចាត់ទុកថាបានដកវិញ។

### ខ.៥. ការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ

បន្ទាប់ធ្វើការត្រួតពិនិត្យបែបបទ និងការត្រួតពិនិត្យខ្លឹមសារ ត្រឹមត្រូវតាមច្បាប់កំណត់អស់ហើយ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការចុះបញ្ជី និងចេញវិញ្ញាបនបត្រជូនដល់អ្នកដាក់ពាក្យស្នើសុំ[113]។ បន្ទាប់ពីបានចុះបញ្ជី នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងព្រឹត្តិបត្រផ្លូវការ ក្នុងរយៈពេលមិនលើសពី ៣០(សាមសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី ហើយការបោះពុម្ពផ្សាយនេះ ត្រូវរួមបញ្ចូលទាំងសេចក្តីសង្ខេបនៃសៀវភៅបន្ទុក ដោយត្រូវតម្កល់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា[114]

---

107 មាត្រា១១ កថាខណ្ឌទី២ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

108 ប្រការ១៤ ចំណុចទី៣ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

109 ប្រការ១៤ ចំណុចទី៤ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

110 ប្រការ១៤ ចំណុចទី៥ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

111 ប្រការ១៤ ចំណុចទី១០ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

112 ប្រការ១៤ ចំណុចទី៨ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

113 មាត្រា១២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

114 ប្រការ១៥ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

។ ការបោះពុម្ពផ្សាយនេះក្នុងគោលបំណងចង់បង្ហាញដល់សាធារណៈអំពីការសម្រេចនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញជាស្ថាពរ ដើម្បីទុកលទ្ធភាពឱ្យភាគីពាក់ព័ន្ធដែលមានផលប្រយោជន៍អាចធ្វើការប្តឹងជំទាស់ទៅនឹងការចុះបញ្ជី[115]។ នៅពេលធ្វើការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្រនៃម៉ាកសម្គាល់ភូមិសាស្ត្រជូនម្ចាស់សិទ្ធិ ហើយនៅក្នុងវិញ្ញាបនបត្រនេះ ត្រូវមានព័ត៌មាន ដូចទៅនឹងបទប្បញ្ញត្តិនៃច្បាប់កំណត់[116]។

**កថាខណ្ឌទី២៖ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស**

ព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យទំនិញ ឬផលិតផលបរទេស អាចធ្វើការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដើម្បីទទួលបាននូវការការពារតាមបទដ្ឋានគតិយុត្តរបស់កម្ពុជា។ ប៉ុន្តែទំនិញបរទេស ដែលអាចចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺចាំបាច់ត្រូវតែបំពេញនូវលក្ខខណ្ឌនៃការចុះបញ្ជី និងត្រូវបំពេញនូវលំហូរនីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស ទៅតាមបទប្បញ្ញត្តិរបស់កម្ពុជា។

**ក. លក្ខខណ្ឌនៃការចុះបញ្ជី**

បច្ចុប្បន្ននេះ កម្ពុជាទើបតែទទួលចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសមួយប៉ុណ្ណោះ គឺផលិតផលស្រាមួយប្រភេទរបស់បារាំង (ស្រាសំប៉ាញ ឬ Champagne) ដែលធ្វើឱ្យផលិតផលនេះ បានក្លាយជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសដំបូងគេនៅកម្ពុជា នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩[117]។ ស្រាសំប៉ាញនេះ គឺជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដ៏ល្បីរបស់ប្រទេសបារាំង ដែលបង្កើតដោយតភ្ជាប់កត្តាធម្មជាតិ និងប្រពៃណីរបស់ជនជាតិបារាំង ហើយស្រានេះ ត្រូវបានទទួលស្គាល់ជាសម្បត្តិបេតិកភណ្ឌពិភពលោក នៅឆ្នាំ២០១៥ ដោយអង្គការយូណេស្កូ (UNESCO)[118] និងបានចុះបញ្ជីការពារម៉ាកនៅក្នុងប្រទេសចំនួន ១១៧ ហើយតាមរយៈការធ្វើពាណិជ្ជកម្ម ស្រានេះបានផ្តល់ប្រាក់ចំណូលប្រចាំឆ្នាំប្រមាណជាង ៥ពាន់លានអឺរ៉ូ ដល់ប្រជាជន និងប្រទេសបារាំង។ លើសពីនេះ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បាន[119] "អំពាវដល់សមាគម និងក្រុមហ៊ុនបរទេស ធ្វើការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់ខ្លួន ដោយយកគំរូតាមស្រាសំប៉ាញ «Champagne» បារាំង ដើម្បីទទួលបានការគាំពារផ្លូវ

---

115 មាត្រា១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

116 ប្រការ១៦ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

117 *"ស្រាសំប៉ាញបារាំងត្រូវបានចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅកម្ពុជា"*, អង្គភាពព័ត៌មានៈថ្មីៗ, មេសា ២០១៩, https://bit.ly/2NhqyvL, ចូលមើលថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០

118 *"Champagne vineyards granted World Heritage status by UNESCO"*, The Economic Times, 2015, https://bit.ly/2AMAeMh, ចូលមើលថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០

119 *"រដ្ឋមន្ត្រីពាណិជ្ជកម្ម អំពាវនាវឱ្យពាណិជ្ជករបរទេស ធ្វើការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ដើម្បីទទួលបានការគាំពារផ្លូវច្បាប់"*, Fresh News, មេសា ឆ្នាំ២០១៩, https://bit.ly/317SB91, ចូលមើលថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០

ច្បាប់ ដោយសារតែកម្ពុជា គឺជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលមានទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន សម្រាប់ការពារទាំងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា និងបរទេស"។

ដូច្នេះ រាល់ម៉ាកសម្គាល់ភូមិសាស្ត្ររបស់បរទេសទាំងឡាយដែលមានបំណងចង់ចុះបញ្ជីនៅកម្ពុជា ត្រូវតែបំពេញនូវលក្ខខណ្ឌសំខាន់ៗ[120]មួយចំនួនៈ **ទី១** លុះត្រាតែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសនោះ បានចុះបញ្ជីស្របតាមបទប្បញ្ញត្តិនានាក្នុងប្រទេសដើមរបស់ខ្លួន **ទី២** ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសនោះ នៅមានសុពលភាពនៅឡើយ ពោលគឺមិនមែនជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសដែលមិនបានទទួលកិច្ចការពារ ឬត្រូវបានបញ្ឈប់កិច្ចការពារ ឬត្រូវបានឈប់ប្រើប្រាស់ក្នុងប្រទេសដើមរបស់ខ្លួន និង**ទី៣** ការដាក់ពាក្យស្នើសុំនោះត្រូវធ្វើឡើងដោយតំណាងស្របច្បាប់ ឬតំណាងរដ្ឋបាល ឬអាជ្ញាធរបរទេសនៃប្រទេស តាមរយៈភ្នាក់ងារតំណាងស្របច្បាប់ដែលមានលំនៅដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកតំណាងដែលជាភ្នាក់ងារក្នុងការដាក់ពាក្យសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងប្រកាសស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រសួងពាណិជ្ជកម្ម[121]។

### ខ. នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

ចំពោះនីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស គឺមិនមានលក្ខណៈខុសគ្នាអ្វីឡើយពីការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា គឺអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសត្រូវដាក់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ហើយនីតិវិធីផ្សេងៗទៀតដូចជា ការត្រួតពិនិត្យពាក្យស្នើសុំ ការត្រួតពិនិត្យខ្លឹមសារ ការកែតម្រូវ ការបោះពុម្ពផ្សាយ និងនីតិវិធីដទៃទៀត គឺអនុវត្តដូចគ្នាទៅនឹងនីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជាដែរ[122]។ លើសពីនេះចំពោះការស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្របរទេស ត្រូវភ្ជាប់បន្ថែមមកជាមួយនូវភស្តុតាងបញ្ជាក់ថា ឈ្មោះផលិតផលនោះត្រូវបានការពារក្នុងប្រទេសដើម[123]។ ក្រោយពេលដាក់ពាក្យ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម មានសិទ្ធិតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំបញ្ជូនរាល់ព័ត៌មានផ្សេងទៀតទាក់ទងនឹងការចុះបញ្ជីនៅបរទេស ដែលអាចជាមូលដ្ឋានសម្រាប់ការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

---

[120] មាត្រា១៩ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[121] មាត្រា៣៣ និងមាត្រា៣៤ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[122] មាត្រា២០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[123] ប្រការ៨ ចំណុច៤ នៃប្រកាសនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

### កថាខណ្ឌទី៣៖ ការកែប្រែ និងបណ្ដឹង

ក្រោយពីបានចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រជាផ្លូវការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មរួចហើយ ក៏ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឬអ្នកដែលមានប្រយោជន៍ពាក់ព័ន្ធទាំងឡាយ នៅតែអាចមានសិទ្ធិស្នើសុំឱ្យកែប្រែនូវម៉ាកនេះ (ចំណុចទី១) និអាចធ្វើបណ្ដឹងមួយចំនួនក្នុងការជំទាស់ទៅនឹងការសម្រេចសេចក្ដីរបស់ក្រសួងពាណិជ្ជកម្ម (ចំណុចទី២) បាន។

#### ក. ការកែសម្រួល មោឃភាព និងការលុបចោល

អ្នកដាក់ពាក្យស្នើសុំ ឬបុគ្គលពាក់ព័ន្ធ អាចមានសិទ្ធិស្នើសុំធ្វើការកែសម្រួល មោឃភាព និងលុបចោលម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបាន ទោះបីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនេះ បានចុះបញ្ជីរួចហើយក៏ដោយ។

##### ក.១. ការកែសម្រួល

ការកែសម្រួល សំដៅលើរាល់ការកែសម្រួលទាំងឡាយណាទៅលើសៀវភៅបន្ទុក ដែលមិនប៉ះពាល់ដល់ចំណុចជាសារវន្តនៃការសម្រេចក្នុងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ អ្នកដែលមានសិទ្ធិស្នើសុំធ្វើការកែសម្រួល អាចជាម្ចាស់សិទ្ធិផ្ទាល់ ឬបុគ្គលដែលមានការពាក់ព័ន្ធ។ ក្រោយការចុះបញ្ជី ម្ចាស់សិទ្ធិអាចស្នើទៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដើម្បីសុំធ្វើការកែសម្រួលសៀវភៅបន្ទុកបាន ជាពិសេសលើចំណុចដែលទាក់ទងនឹងការវិវត្តចំណេះដឹងបច្ចេកទេស និងវិទ្យាសាស្ត្រ និងការកំណត់ព្រំដែនភូមិសាស្ត្រជាដើម[124]។

នៅក្នុងពាក្យស្នើសុំត្រូវពិពណ៌នា និងផ្ដល់មូលហេតុពីការស្នើសុំកែប្រែទាំងនោះ។ ប្រសិនបើការស្នើសុំកែប្រែនោះ មិនធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការសម្រេចចិត្តចំពោះការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវទទួលស្គាល់ ឬបដិសេធលើការស្នើសុំកែប្រែនោះ។ ចំពោះការកែប្រែដែលចាត់ទុកថាមានលក្ខណៈតូចតាចមិនត្រូវ[125]៖ **(ក)** ទាក់ទងនឹងចរិតលក្ខណៈចំបងនៃផលិតផល **(ខ)** ផ្លាស់ប្ដូរចំណងទាក់ទងដូចមានចែងក្នុងចំណុច (៦) នៃសៀវភៅបន្ទុក **(គ)** មានការផ្លាស់ប្ដូរឈ្មោះ ឬផ្នែកណាមួយនៃឈ្មោះផលិតផល **(ឃ)** ធ្វើឱ្យប៉ះពាល់ដល់តំបន់សម្គាល់ភូមិសាស្ត្រដែលបានកំណត់ និង **(ង)** ធ្វើឱ្យមានការកើនឡើងនូវការរិតត្បិតដល់ផ្នែកពាណិជ្ជកម្មលើផលិតផល ឬវត្ថុធាតុដើមនៃផលិតផលនោះ។

##### ក.២. មោឃភាព និងការលុបការចុះបញ្ជី

ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នមានសមត្ថកិច្ចតែមួយ ដែលមានសិទ្ធិក្នុងការមោឃភាព ឬការលុបការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ តាមរយៈគំនិតរបស់ក្រសួងពាណិជ្ជកម្មផ្ទាល់ ឬការស្នើសុំរបស់ភាគីដែលមានពាក់ព័ន្ធដោយមានបញ្ជាក់ពីមូលហេតុ និងភស្ដុតាង។ កាលដែលអាចមោឃភាពលើការចុះបញ្ជីម៉ាកសម្គាល់

124 មាត្រា២៨ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

125 ប្រការ៤១ ចំណុច៣ នៃប្រកាសនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ភូមិសាស្ត្រទំនិញ លុះត្រាមាន៖ **(ក)** លក្ខខណ្ឌណាមួយ ដែលមានចែងក្នុងមាត្រា៤ (និយមន័យលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ) មាត្រា៧ (អ្នកដាក់ពាក្យស្នើសុំ) និងមាត្រា១០ (ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមិនអាចចុះបញ្ជីបាន) នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មិនត្រូវបានបំពេញ និង **(ខ)** ក្នុងករណីមានភស្តុតាងណាមួយដែលបង្ហាញថា ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួចហើយ មិនមែនជាម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញស្របច្បាប់[126]។

ចំណែកឯ ការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួច អាចលុបបានក្នុងករណីដែល[127]៖ **(ក)** ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួចហើយ ស្នើសុំលុប **(ខ)** ទំនិញសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួចហើយ បានបាត់បង់លក្ខណៈសម្បត្តិពិសេស ជាទំនិញសម្គាល់ភូមិសាស្ត្រ **(គ)** ម្ចាស់សិទ្ធិមិនគោរព និងមិនអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងពាក្យស្នើសុំ **(ឃ)** ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសដែលមិនបានការពារ ឬបញ្ឈប់កិច្ចការពារ ឬមិនបានប្រើប្រាស់បន្តបន្ទាប់នៅប្រទេសដើម **(ង)** អាសយដ្ឋានទំនាក់ទំនងរបស់ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មិនអាចទាក់ទងបានយ៉ាងតិចចំនួនបីដងតាមគ្រប់មធ្យោបាយក្នុងរយៈពេលបីខែ **(ច)** ម្ចាស់សិទ្ធិអនុវត្តផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលជាប់ពាក់ព័ន្ធ និងករណីផ្សេងៗទៀតដែលមានកំណត់នៅក្នុងច្បាប់។

ចំពោះនីតិវិធីនៃការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជី គឺមានចែងនៅក្នុងប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់ក្រសួងពាណិជ្ជកម្ម។ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យភាពដែលអាចទទួលយកបាននៃសំណើសុំលុបនោះ ក្នុងរយៈពេល៩០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃសំណើសុំលុប។ បន្ទាប់ពីបានដោះស្រាយរួច នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវបោះពុម្ពផ្សាយនូវសេចក្តីសម្រេចដែលទាក់ទងនឹងការលុបចោលម៉ាកសម្គាល់ភូមិសាស្ត្រចេញពីបញ្ជី ក្នុងព្រឹត្តបត្រផ្លូវការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា[128]។ រីឯនីតិវិធីនៃការមោឃភាពការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺមិនមាននូវបទប្បញ្ញត្តិគតិយុត្តយ៉ាងណាមួយ ចែងកំណត់ទុកឡើយ។

នៅពេលដែលមានមោឃភាព ឬការលុបការចុះបញ្ជីនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកើតឡើងនោះ នឹងធ្វើឱ្យម្ចាស់សិទ្ធិបាត់នូវសិទ្ធិ និងការការពារតាមផ្លូវច្បាប់។ ចំពោះអានុភាពមោឃភាពនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី (អានុភាពប្រតិសកម្ម)។ ចំណែកឯ អានុភាពនៃការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេច

[126] មាត្រា២៩ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[127] មាត្រា២៩ កថាខណ្ឌទី៤ នៃច្បាប់ស្តីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[128] ប្រការ៤២ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

(អានុភាពមិនប្រតិសកម្ម)។ លើសពីនេះ រាល់ការធ្វើមោឃភាព និងការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវកត់ត្រា និងបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ និងផ្សព្វផ្សាយជាសាធារណៈភ្លាម[129]។

### ខ. បណ្ដឹងពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

នៅក្នុងនីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ភាគីដែលមានការពាក់ព័ន្ធ អាចធ្វើនូវបណ្ដឹងពីរប្រភេទ គឺ៖ បណ្ដឹងជំទាស់ (ក) និងបណ្ដឹងតវ៉ា (ខ)។

#### ខ.១. បណ្ដឹងជំទាស់

បណ្ដឹងជំទាស់ សំដៅដល់បណ្ដឹងជំទាស់ទៅនឹងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញណាមួយពីសំណាក់បុគ្គលពាក់ព័ន្ធ [130] ។ ភាគីដែលមានការពាក់ព័ន្ធ (រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដែលមានផលប្រយោជន៍ស្របច្បាប់) អាចប្ដឹងជំទាស់នឹងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញទៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយការចុះបញ្ជីក្នុងព្រឹត្តិបត្រផ្លូវការ [131] ។ ពាក្យបណ្ដឹងជំទាស់ ត្រូវភ្ជាប់ជាមួយសេចក្ដីប្រកាសថា ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រនោះ ដែលស្ថិតក្រោមមូលដ្ឋាននៃបណ្ដឹងជំទាស់ ហើយមូលដ្ឋានដែលអាចធ្វើបណ្ដឹងជំទាស់រួមមាន៖ មិនស្របតាមនិយមន័យនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឬម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីនោះជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមិនអាចចុះបញ្ជី[132]។

បន្ទាប់ពីទទួលបានពាក្យបណ្ដឹងជំទាស់ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីបណ្ដឹងជំទាស់ដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ហើយអ្នកដាក់ពាក្យស្នើសុំមានរយៈពេល ៤៥ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទជូនដំណឹងដើម្បីធ្វើសេចក្ដីថ្លែងតប។ នាយកដ្ឋានកម្មសិទ្ធិបញ្ញា អាចពន្យារពេល ៤៥ ថ្ងៃទៀត ប្រសិនបើមានសំណូមពរពីអ្នកស្នើសុំ។ ក្នុង ករណីចាំបាច់ ឬតាមការស្នើសុំពីភាគីណាមួយ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវរៀបចំឱ្យមានសវនាការលើបណ្ដឹងជំទាស់នេះ [133] ។ បន្ទាប់ពីដោះស្រាយលើបណ្ដឹងជំទាស់ចប់ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវជូនដំណឹងពីសេចក្ដីសម្រេចរបស់ខ្លួន ដោយមានបញ្ជាក់ពីហេតុផលសមស្របទៅអ្នកដាក់ពាក្យស្នើសុំ និងអ្នកបណ្ដឹងជំទាស់។ បន្ថែមពីនេះ ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំ និង/ឬអ្នកបណ្ដឹងជំទាស់ មិនពេញចិត្តនឹងសេចក្ដីសម្រេចនេះ អាចប្ដឹងតវ៉ាបាន។ សេចក្ដីសម្រេចពាក់ព័ន្ធនឹងបណ្ដឹងជំទាស់របស់

[129] មាត្រា៣០ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[130] មាត្រា៤ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[131] មាត្រា១៥ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងប្រការ២៦ ចំណុចទី១ នៃប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[132] មាត្រា១៦ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងប្រការ២៥ ចំណុចទី១ នៃប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[133] ប្រការ២៦ ចំណុចទី៦ នៃប្រកាសស្ដីពីការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ[134]។ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវតម្កល់ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រនេះ ក្នុងករណីមានការចេញសេចក្តីសម្រេចស្ថាពរតាមបណ្តឹងតវ៉ា ឬសាលក្រមស្ថាពរទាត់ចោលបណ្តឹងជំទាស់។

### ខ.២. បណ្តឹងតវ៉ា

បណ្តឹងតវ៉ា សំដៅដល់ការប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចចុងក្រោយរបស់ក្រសួងពាណិជ្ជកម្ម ឬក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ[135]។ បុគ្គលពាក់ព័ន្ធ ឬតំណាងរបស់ខ្លួន អាចដាក់ពាក្យបណ្តឹងតវ៉ា ទៅក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ឬទៅតុលាការមានសមត្ថកិច្ច ប្រឆាំងនឹងសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម[136]។ លើសពីនេះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មិនមែនជាសេចក្តីសម្រេចចងភ្ជាប់កាតព្វកិច្ច ឬជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ដែលភាគីត្រូវអនុវត្តតាមនោះទេ គឺបុគ្គលពាក់ព័ន្ធក៏អាចប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ទៅតុលាការមានសមត្ថកិច្ចបាន[137]។ បណ្តឹងតវ៉ាត្រូវធ្វើឡើងក្នុងរយៈពេល ៩០ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួល ដំណឹងពីសេចក្តីសម្រេច[138] ហើយនៅពេលធ្វើបណ្តឹងតវ៉ា គឺត្រូវដាក់ជាលាយលក្ខណ៍អក្សរ និងត្រូវបង់កម្រៃសេវាតាមការកំណត់នៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។ ជាក់ស្តែង បើផ្អែកតាមប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម តម្លៃកម្រៃសេវាក្នុងការដាក់ពាក្យបណ្តឹងជំទាស់ ឬបណ្តឹងតវ៉ា គឺ៣០០,០០០រៀល។

ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ត្រូវពិនិត្យភាពដែលអាចទទួលយកបាន ឬមិនបាននៃពាក្យបណ្តឹងតវ៉ានោះ ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹងតវ៉ា។ បន្ទាប់មក ក្រុមប្រឹក្សានេះ ត្រូវពិនិត្យខ្លឹមសារនៃបណ្តឹងតវ៉ាក្នុងរយៈពេល ៩០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹងតវ៉ាជាផ្លូវការ។ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ឬតុលាការមានសមត្ថកិច្ច[139]។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញលើបណ្តឹងតវ៉ា ត្រូវបោះពុម្ពផ្សាយនៅក្នុងព្រឹត្តបត្រផ្លូវការ និងផ្សព្វផ្សាយជាសាធារណៈ។

---

134 មាត្រា១៧ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

135 មាត្រា៤ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

136 មាត្រា១៨ កថាខណ្ឌទី១ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងប្រការ២៧ ចំណុចទី១ នៃប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

137 មាត្រា១៨ កថាខណ្ឌទី២ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

138 មាត្រា១៨ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

139 ប្រការ២៨ នៃប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

**កថាខណ្ឌទី៤៖ ការប្រើប្រាស់រូបសញ្ញាជាតិ**

គ្រប់ផលិតផលទាំងអស់ ដែលបានចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅកម្ពុជា គឺត្រូវតែបិទនូវរូបសញ្ញាជាតិមួយដែលបង្កើតឡើងដោយក្រសួងពាណិជ្ជកម្ម សម្រាប់ប្រើក្នុងការបញ្ជាក់ថា ផលិតផល ឬទំនិញនោះបានចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរួចរាល់ និងត្រូវទទួលបានការការពារតាមបទប្បញ្ញត្តិច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា[140]។ រូបសញ្ញាជាតិ សំដៅដល់ និមិត្តសញ្ញាដែលប្រើប្រាស់សម្រាប់បញ្ជាក់លើទំនិញសម្គាល់ភូមិសាស្ត្រ និងម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដើម្បីអាចប្រើប្រាស់រូបសញ្ញាជាតិនេះបានលុះត្រាតែបំពេញនូវលក្ខខណ្ឌក្នុងការប្រើប្រាស់ (ចំណុចទី១) និងអ្នកដែលមានសិទ្ធិប្រើប្រាស់ (ចំណុចទី២)។

**ក. លក្ខខណ្ឌក្នុងការប្រើប្រាស់**

ម៉ាកសម្គាល់ភូមិសាស្ត្រដែលបានការពារនិងរូបសញ្ញាជាតិ ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ចំពោះតែផលិតករ ឬប្រតិបត្តិករណាមួយដែលកំពុងផលិត និង/ឬធ្វើទីផ្សារទំនិញសម្គាល់ភូមិសាស្ត្រណាដែលអនុវត្តតាមសៀវភៅបន្ទុកប៉ុណ្ណោះ[141]។ ក្នុងករណីផលិតផលមានប្រភពក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវធ្វើទីផ្សារក្រោមម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានចុះបញ្ជីស្របតាមនីតិវិធីដែលមានកំណត់ ត្រូវរំលេចឱ្យឃើញរូបសញ្ញាជាតិលើស្លាកសញ្ញាផលិតផលសម្គាល់ភូមិសាស្ត្រ។ លើសពីនេះម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីចំពោះផលិតផលណាមួយ ត្រូវរំលេចឱ្យឃើញដូចគ្នាក្នុងការដាក់ស្លាកសញ្ញានោះ។ ការបញ្ជាក់ឃ្លាថា "ម៉ាកសម្គាល់ភូមិសាស្ត្រដែលបានការពារ" ឬ PGI អាចរំលេចឱ្យឃើញក្នុងការដាក់ស្លាកសញ្ញានោះផងដែរ។

ក្នុងករណីផលិតផលនោះមានប្រភពមកពីប្រទេសទីបី ដែលធ្វើទីផ្សារក្រោមម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជី អាចប្រើប្រាស់រូបសញ្ញាជាតិ ដូចផលិតផលមានប្រភពក្នុងព្រះរាជាណាចក្រកម្ពុជាដែរ។ អ្នកប្រើប្រាស់រូបសញ្ញាជាតិ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ជាមុន នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា។

**ខ. អ្នកប្រើប្រាស់រូបសញ្ញាជាតិ**

បុគ្គលដែលមានសិទ្ធិប្រើប្រាស់រូបសញ្ញាជាតិ ត្រូវមានលក្ខណៈសម្បត្តិ៖ (ក) ជាផលិតករ ឬប្រតិបត្តិករដែលជាសមាជិកនៃសមាគមសម្គាល់ភូមិសាស្ត្រ និង(ខ) អនុវត្តទៅតាមសៀវភៅបន្ទុកនៃម៉ាកសម្គាល់ភូមិសាស្ត្រ។ ដើម្បីទទួលបានការអនុញ្ញាតក្នុងការប្រើប្រាស់រូបសញ្ញាជាតិ បុគ្គលដែលមានសិទ្ធិ ត្រូវបង់កម្រៃដូចមានចែងក្នុងប្រកាសរួម រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម។ លើសពីនេះ អ្នកប្រើប្រាស់មានសិទ្ធិផលិតដោយផ្ទាល់ខ្លួន នូវស្ទិគ័រសញ្ញាជាតិ ស្លាកសញ្ញា ឬសំបកវេចខ្ចប់ ទៅតាមលក្ខខណ្ឌដែលបានកំណត់ដោយនាយក

[140] មាត្រា១៤ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[141] ប្រការ២១ នៃប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ដ្ឋានកម្មសិទ្ធិបញ្ញា[142] ហើយ ចំពោះរយៈពេលនៃការអនុញ្ញាតឱ្យប្រើប្រាស់រូបសញ្ញាជាតិ គឺនៅតែមានសុពលភាពដរាបណាបុគ្គលដែលទទួលបានការអនុញ្ញាតនោះ អនុវត្តតាមវិធាននានានៃម៉ាកសម្គាល់ភូមិសាស្ត្រដែលពាក់ព័ន្ធ[143]។

**កថាខណ្ឌទី៥៖ អានុភាពនៃការចុះបញ្ជី**

បន្ទាប់ពីម៉ាកសម្គាល់ភូមិសាស្ត្រមួយ ត្រូវបានចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មរួចហើយ អ្នកពាក្យស្នើសុំបញ្ជី នឹងក្លាយជាម្ចាស់សិទ្ធិលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយទទួលបាននូវសិទ្ធិក្នុងការគ្រប់គ្រង (ចំណុចទី១) រយៈពេលនៃកិច្ចការពារ និងកាតព្វកិច្ចមួយចំនួន (ចំណុចទី២) និងទទួលបាននូវកិច្ចការពារពីច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា (ចំណុចទី៣)។

**ក. សិទ្ធិដែលទទួលបានពីការចុះបញ្ជី**

នៅពេលដែលម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមួយ ត្រូវបានចុះបញ្ជីនៅក្រសួងពាណិជ្ជកកម្ម ស្របតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ សមាជិកសមាគមសម្គាល់ភូមិសាស្ត្រទំនិញដែលជាផលិតករ និង/ឬប្រតិបត្តិករដែលអនុវត្តស្របតាមសៀវភៅបន្ទុក មានសិទ្ធិប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះ។ សិទ្ធិប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមិនអាចផ្ទេរបានឡើយ។ បន្ថែមពីនេះ ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះបុគ្គលណាម្នាក់ដែលបានប្រើប្រាស់ដោយរំលោភនូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់នោះ ហើយក៏មានសិទ្ធិប្តឹងចំពោះសមាជិកណាម្នាក់នៃសមាគមសម្គាល់ភូមិសាស្ត្រទំនិញ ដែលបានប្រើប្រាស់ដោយរំលោភនូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ[144]។ ប៉ុន្តែសិទ្ធិនេះ មិនរាប់បញ្ចូលនូវការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់សិទ្ធិដែលបានចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះទេ។

ទន្ទឹមនឹងនេះ សមាគមសម្គាល់ភូមិសាស្ត្រ ដែលជាម្ចាស់សិទ្ធិនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ[145] គឺមានសិទ្ធិធ្វើសកម្មភាពផ្សេងៗ ដោយមិនធ្វើឱ្យប៉ះពាល់បទប្បញ្ញត្តិជាក់លាក់ស្តីពីអង្គភាព ផលិតករ និងអន្តរសាខានៃអង្គភាព[146] រួមមាន៖ (ក) ចូលរួមចំណែកក្នុងការធានាថា គុណភាព កិត្តិសព្ទ និងភាពត្រឹមត្រូវតែនៃផលិតផលរបស់អង្គភាពត្រូវបានធានានៅលើទីផ្សារ តាមរយៈការត្រួតពិនិត្យការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រក្នុងវិស័យពាណិជ្ជកម្ម (ខ) ចាត់វិធានការដើម្បីធានាឱ្យកិច្ចការពារតាមផ្លូវច្បាប់ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រ (គ) ចាត់វិធាន

[142] ប្រការ២២ នៃប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[143] ប្រការ២៤ នៃប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[144] មាត្រា២២ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[145] ប្រការ៨ នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[146] ជំពូកទី២ ដល់ជំពូកទី៣ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា

ការកែលំអផ្សេងៗជូនផលិតករ និងចាត់វិធានការលើកកម្ពស់តម្លៃផលិតផល ទប់ស្កាត់ ឬប្រឆាំងនឹងវិធានការណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់ផលិតផល ជាដើម។ លើសពីនេះ សមាគមសម្គាល់ភូមិសាស្ត្រអាចបង្កើតវិធាន ស្ដីពីការអនុវត្តល្អៗតាមបទប្បញ្ញត្តិកំណត់ ដើម្បីថែរក្សាចរិតលក្ខណៈបរិស្ថានជាក់ស្ដែងនៃដី ឬបទប្បញ្ញត្តិជាក់លាក់ស្ដីពីសុខុមាលភាពសត្វ[147]។

**ខ. រយៈពេលនៃកិច្ចការពារ និងកាតព្វកិច្ច**

ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានសុពលភាពចាប់ពីកាលបរិច្ឆេទនៃការទទួលស្នើចុះបញ្ជី ប្រសិនបើគ្មានការលុប ឬមោឃភាព ស្របតាមច្បាប់នេះ[148]។ បានសេចក្ដីថា ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នឹងមានសុពលភាពជាអចិន្ត្រៃយ៍ ប្រសិនបើមិនមាននូវការមោឃភាព ឬការលុបចោលណាមួយ។ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលបានចុះបញ្ជីត្រឹមត្រូវរួច ហើយមុនច្បាប់នេះចូលជាធរមានត្រូវមានសុពលភាពបន្ត។ លើសពីនេះ បន្ទាប់ពីទទួលបានសិទ្ធិដែលបានមកពីការចុះបញ្ជីហើយ អ្នកដាក់ពាក្យស្នើសុំ (ម្ចាស់ទំនិញ) ត្រូវតែបំពេញនូវកាតព្វកិច្ចមួយចំនួនផងដែរ។ រាល់កាតព្វកិច្ចទាំងអស់នោះ អ្នកដាក់ពាក្យស្នើសុំ ត្រូវតែគោរពតាមទើបអាចការពារទៅលើម៉ាកសម្គាល់ភូមិសាស្ត្រឱ្យកាន់តែមានប្រសិទ្ធភាព។ កាតព្វកិច្ចទាំងនោះរួមមាន៖ (ក) កាតព្វកិច្ចបង់ប្រាក់កម្រៃរដ្ឋបាល និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម[149] (ខ) ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវអនុវត្តតាមលក្ខខណ្ឌនៃសៀវភៅ[150] និង (គ) ម្ចាស់សិទ្ធិដែលជាសមាគមម៉ាកសម្គាល់ភូមិសាស្ត្រ ត្រូវត្រួតពិនិត្យនូវរាល់សមាជិកនៃសមាគមរបស់ខ្លួនឱ្យគោរពតាម ការណែនាំរបស់សៀវភៅបន្ទុក និងការកំណត់របស់ច្បាប់[151]។

**គ. កិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ**

ក្រោយពីបានចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជារួចហើយ មិនថាទំនិញនោះមានប្រភពក្នុងស្រុក ឬបរទេសក៏ដោយ គឺត្រូវទទួលបាននូវការការពារតាមបទដ្ឋានគតិយុត្តរបស់ព្រះរាជាណាចក្រកម្ពុជា ហើយការការពារទាំងនោះ រួមមាន៖

[147] ទាក់ទងនឹងបទប្បញ្ញត្តិស្ដីពីសុខុមាលភាពសត្វ សូមមើល, ច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ

[148] មាត្រា២៤ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[149] មាត្រា៣៥ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[150] មាត្រា២៦ កថាខណ្ឌទី៤ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[151] មាត្រា៧ កថាខណ្ឌទី៣ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

### គ.១. កិច្ចការពារចំពោះការរំលោភបំពាន

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា និងបរទេស ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានការពារទល់នឹង[152]៖ **(ក)** ការប្រើប្រាស់មិនត្រឹមត្រូវក្នុងគោលបំណងពាណិជ្ជកម្មដោយផ្ទាល់ ឬដោយប្រយោលនូវម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួចហើយ ចំពោះទំនិញដែលដូចគ្នា ឬទំនិញដែលអាចប្រៀបធៀបទៅនឹងទំនិញដែលបានចុះបញ្ជីដើម្បីឱ្យការប្រើប្រាស់នោះ ទទួលផលប្រយោជន៍ ឬអាចនឹងទទួលផលប្រយោជន៍ពីកេរ្តិ៍ឈ្មោះរបស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ **(ខ)** ការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការធ្វើត្រាប់តាម ការធ្វើឱ្យនឹកគិតទៅដល់ ឬការបកប្រែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ទោះបីប្រភពពិតប្រាកដនៃទំនិញត្រូវបានអមដោយពាក្យដូចជា ស្ទីល យថាប្រភេទ ប្រភេទ វិធីសាស្ត្រ របៀប ត្រាប់តាម ឬការបកប្រែនៃពាក្យទាំងនេះ ឬពាក្យប្រហាក់ប្រហែលធ្វើឱ្យសាធារណជនកាន់ច្រឡំក៏ដោយ **(គ)** ការក្លែងបន្លំ ឬការធ្វើឱ្យភាន់ច្រឡំអំពីប្រភពដើម ប្រភេទ ឬគុណភាពពិសេសនៃទំនិញដែលបង្ហាញលើសំបកវេចខ្ចប់គ្រប់ប្រភេទ ឬលើ ឯកសារផ្សាយពាណិជ្ជកម្ម ឬលើឯកសារផ្សេងទៀតដែលទាក់ទងនឹងទំនិញ ដែលអាចនាំឱ្យមានការយល់ខុសអំពីប្រភពដើមរបស់ផលិតផល និង **(ឃ)** ការអនុវត្តផ្សេងៗទៀតដែលអាចធ្វើឱ្យសាធារណជនទូទៅភាន់ច្រឡំអំពីប្រភពដើមពិតប្រាកដនៃទំនិញ។

លើសពីនេះ ក្រសួងពាណិជ្ជកម្មត្រូវបដិសេធការស្នើសុំចុះបញ្ជីម៉ាកណាដែលដូច ឬប្រហាក់ប្រហែលធ្វើឱ្យភាន់ច្រឡំនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលបានដាក់ពាក្យមុនកាលបរិច្ឆេទនៃការដាក់ពាក្យស្នើចុះបញ្ជីម៉ាកនេះ[153]។ ប៉ុន្តែប្រសិនបើ ម៉ាកដែលពាក់ព័ន្ធនឹងចំណុចណាមួយក្នុងចំណោមខាងលើនេះ ដែលបានចុះបញ្ជីម៉ាកដោយសុចរិតរួចហើយ មុនកាលបរិច្ឆេទនៃកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឬមុនកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតឱ្យបន្តប្រើប្រាស់ម៉ាកនោះបាន ប្រសិនបើគ្មានមូលដ្ឋានចាត់ទុកជាមោឃៈ[154]។

បន្ថែមពីនេះទៅទៀត ក្នុងករណីដែលម៉ាកសម្គាល់ភូមិសាស្ត្រ មានឈ្មោះផលិតផលជាពាក្យទូទៅ[155] នោះម៉ាកសម្គាល់ភូមិសាស្ត្រ មិនត្រូវបានការពារឡើយ ដោយសារតែការប្រើប្រាស់ឈ្មោះទូទៅក្នុងម៉ាកសម្គាល់ភូមិសាស្ត្រមិនត្រូវបានចាត់ទុកថាផ្ទុយនឹងចំណុច (ក) ឬ (ខ) ក្នុងមាត្រា២៣ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រឡើយ[156]។

[152] មាត្រា២៣ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[153] មាត្រា៣១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[154] មាត្រា៣១ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[155] ពាក់ព័ន្ធនឹងកំណត់ន័យ "ពាក្យទូទៅ" សូមមើល, ប្រការ៣១ នៃប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[156] ប្រការ២៩ នៃប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

## គ.២. វិធានការនៃការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ប្រសិនបើម្ចាស់សិទ្ធិ ត្រូវបានរំលោភបំពានសិទ្ធិពីសំណាក់បុគ្គលណាម្នាក់ ម្ចាស់សិទ្ធិអាចធ្វើការប្តឹងទៅតុលាការមានសមត្ថកិច្ច ឬអាជ្ញាធរក្នុងការចាត់វិធានការ ដើម្បីធ្វើការការពារម៉ាកសម្គាល់ភូមិសាស្ត្រនោះ ដោយម្ចាស់ម៉ាកត្រូវតែមានភស្តុតាងច្បាស់លាស់ក្នុងការបញ្ជាក់អំពីអំពើរំលោភបំពានសិទ្ធិនោះ ភ្ជាប់មកជាមួយ។

### គ.២.១ វិធានការជូនដំណឹង

វិធានការនេះ អាចត្រូវបានចាត់ទុកជាវិធានការទន់ភ្លន់របស់ម្ចាស់សិទ្ធិ នៅក្នុងការជូនដំណឹងដល់អ្នករំលោភសិទ្ធិបញ្ឈប់អំពើរំលោភនេះ និងទាមទារនូវសំណងសមរម្យ។ តាមរយៈវិធានការនេះ ម្ចាស់សិទ្ធិអាចធ្វើជាលិខិតព្រមាន ឬជូនដំណឹងអំពីការរំលោភសិទ្ធិ ទៅតតិយជនឱ្យធ្វើការបញ្ឈប់នូវអំពើរំលោភបំពាននោះ។ វិធានការនេះ គ្រាន់តែជាការរំលឹកដាស់តឿនទៅដល់ជនរំលោភបំពាន ដែលបានធ្វើការសកម្មភាពរំលោភបំពានដល់ម្ចាស់សិទ្ធិ និងចរចាក្នុងការបញ្ឈប់អំពើរំលោភតែប៉ុណ្ណោះ។ វិធានការស្របបន្តទៀត ត្រូវយកមកអនុវត្តដោយម្ចាស់សិទ្ធិ ប្រសិនបើមានភស្តុតាងច្បាស់លាស់បញ្ជាក់ថា អ្នករំលោភសិទ្ធិនោះ ពុំបានបញ្ឈប់ និងបន្តអំពើរំលោភបំពានដដែរ។

### គ.២.២. វិធានការបណ្តោះអាសន្ន

វិធានការបណ្តោះអាសន្ន គឺជាការដាក់ចេញរបស់តុលាការនូវសំណើរបស់អ្នកប្តឹង (ម្ចាស់ម៉ាក) ដើម្បីទប់ស្កាត់ការរំលោភបំពាន ដែលការរំលោភបំពាននោះប្រុងនឹងកើតមាន ឬរក្សាទុកនូវភស្តុតាងដែលពាក់ព័ន្ធអំពីការរំលោភកម្មសិទ្ធិបញ្ញារបស់ម្ចាស់ម៉ាក [157] ។ ជាក់ស្តែងនៅក្នុងវិធានការបណ្តោះអាសន្នដែលប្រើប្រាស់ក្នុងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺត្រូវអនុវត្តតាមវិធានការបណ្តោះអាសន្នដែលមានចែងនៅក្នុងច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់[158]។ វិធានការបណ្តោះអាសន្ន មានលក្ខណៈជាបន្ទាន់ និងមានប្រសិទ្ធភាពចំពោះម្ចាស់ម៉ាក ប៉ុន្តែវាអាចបណ្តាលឱ្យមានភាពអន្តរាយដែលមិនអាចជួសជុលបាន ចំពោះម្ចាស់សិទ្ធិ បើសិនជាម្ចាស់ម៉ាកមានការយឺតយ៉ាវនៅពេលភស្តុតាងអាចនឹងត្រូវបានគេបំផ្លាញចោល ដោយសារការប្រើរយៈពេលយូរ។

ដើមចោទ ត្រូវគោរពនូវលក្ខខណ្ឌចំពោះការការពារនូវកម្មសិទ្ធិបញ្ញារបស់ខ្លួន ដើម្បីដាក់ចេញនូវវិធានការបណ្តោះអាសន្ន ដែលមានលក្ខខណ្ឌ[159]ដូចជា៖ (ក) ភស្តុតាងត្រឹមត្រូវដែលមាន ហើយអាចធ្វើឱ្យតុលាការយល់ស្របក្នុងកម្រិតមួយគ្រប់គ្រាន់ សម្រាប់សន្និដ្ឋានបញ្ជាក់ថាដើមចោទ គឺជាម្ចាស់ពិតប្រាកដ ហើយសិទ្ធិរបស់អ្នកប្តឹងកំពុងត្រូវបានគេរំលោភ ឬការរំលោភនោះអាចនឹងកើតមានកើតឡើងក្នុងពេលឆាប់ៗ និង (ខ) ប្រាក់កក់ធានាដែលតម្រូវ ឬការធានាដែលមានតម្លៃស្មើនៃប្រាក់កក់គ្រប់គ្រាន់ ក្នុងការការពារចុងចម្លើយ និងទប់ស្កាត់មិនឱ្យមានការ

[157] មាត្រា២៩ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

[158] មាត្រា៣២ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[159] មាត្រា៣០ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

រំលោភបំពាន។ ប្រាកកក់ធានានេះ ត្រូវស្ថិតនៅក្រោមកំណត់របស់តុលាការ។ វិធានការបណ្តោះអាសន្ន ត្រូវចេញដោយដីកាសម្រេចរបស់តុលាការ។ ប្រសិនបើមានករណីចាំបាច់តុលាការអាចតម្រូវឱ្យដើមបណ្តឹងតម្កល់ប្រាក់ធានាសមស្រប ដើម្បីធានាការខូចខាតនានា ចំពោះចុងចម្លើយដែលអាចកើតមានឡើងដោយសារការអនុវត្តវិធានការនេះ (សូមមើលបន្ថែមចាប់មាត្រា៣១ ដល់ ៣៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់)។

## គ.២.៣. វិធានការតាមមាត់ច្រកព្រំដែន

វិធានការតាមមាត់ព្រំដែន គឺជាវិធានការដែលត្រូវបានប្រឆាំង និងទប់ស្កាត់នូវរាល់ទំនិញនាំចូលតាមច្រកព្រំដែនដែលម្ចាស់ម៉ាកបានដាក់ពាក្យប្តឹងទៅរដ្ឋបាលគយ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ឱ្យឃាត់ទុកនូវទំនិញណា ដែលសង្ស័យថាជាផលិតផលក្លែងបន្លំ ដោយមានបង្ហាញនូវភស្តុតាងច្បាស់លាស់ថា ជាម្ចាស់ម៉ាកដែលមានការចុះបញ្ជីយ៉ាងត្រឹមត្រូវ[160]។ ជាក់ស្តែងនៅក្នុងម៉ាកសម្គាល់ភូមិសាស្ត្រវិធានការនេះ ត្រូវអនុវត្តតាមវិធានការតាមមាត់ព្រំដែនដែលមានចែងក្នុងច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់[161]។ ម្ចាស់ម៉ាកត្រូវធ្វើពាក្យ បណ្តឹងទៅមន្ត្រីមានសមត្ថកិច្ចនៅតាមព្រំដែន ឱ្យជួយធ្វើអន្តរាគមន៍ទៅលើផលិតផលដែលក្លែងបន្លំម៉ាករបសខ្លួន ដើម្បីជួយទប់ស្កាត់រាល់ការរំលោភបំពានមកលើផលិតផលរបស់ខ្លួន ហើយនៅក្នុងពាក្យបណ្តឹងនោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងអមមកជាមួយលិខិតមួយចំនួន[162]ដែលបានកំណត់ដោយច្បាប់។

ទំនិញក្លែងក្លាយ ឬទំនិញដែលរំលោភលើម្ចាស់ម៉ាក នេះអាចត្រូវបានរក្សាទុកជាមួយរដ្ឋបាលគយ និងរដ្ឋាករក្នុងរយៈពេល ១០ថ្ងៃ នៃថ្ងៃធ្វើការចាប់ពីថ្ងៃជូនដំណឹងអំពីការឃាត់ទុកនេះ ហើយដើមបណ្តឹងត្រូវស្នើសុំទៅតុលាការ ឱ្យចាត់វិធានការរក្សាទុកទំនិញដែលរំលោភសិទ្ធិនៃម្ចាស់ម៉ាក ឬទំនិញក្លែងក្លាយ និងប្តឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ (សូមមើលបន្ថែមចាប់ពីមាត្រា៣៨ ដល់មាត្រា៤៧ នៃច្បាប់ពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់)។

## គ.២.៤. ការឃាត់ទុក និងការរឹបអូស

តុលាការមានសមត្ថកិច្ចមានអំណាចបញ្ជាឱ្យឃាត់ទុកទំនិញ ប្រសិនបើមានការសង្ស័យថា ទំនិញនេះមានការបំពានសិទ្ធិរបស់ម្ចាស់សិទ្ធិ។ លើសពីនេះ ប្រសិនបើមានការសង្ស័យថា សម្ភារៈ និងឧបករណ៍សំខាន់ៗដែលប្រើប្រាស់ក្នុងការផលិតទំនិញនោះបំពានសិទ្ធិរបស់ម្ចាស់សិទ្ធិ តុលាការមានសមត្ថកិច្ចក៏អាចបញ្ជាឱ្យឃាត់ទុកទំនិញនោះបានដែរ។ ទំនិញដែលមានការបំពានសិទ្ធិរបស់ម្ចាស់ដែលត្រូវបាននាំចូល នាំចេញ លក់ ឬផ្តល់សម្រាប់លក់

[160] មាត្រា៣៥ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

[161] មាត្រា៣២ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[162] មាត្រា៣៦ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

ត្រូវរឹបអូសដោយអាជ្ញាធរមានសមត្ថកិច្ចតាមសេចក្តីសម្រេចរបស់តុលាការ ទោះជាមាន ឬគ្មានអ្នកណាម្នាក់ជាប់ទោសចំពោះបទល្មើសក៏ដោយ[163]។

### គ.២.៥. ទណ្ឌកម្ម

ការក្លែងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺកម្មវត្ថុដែលនាំឱ្យជនដែលបានក្លែងម៉ាកនេះ ត្រូវទទួលខុសត្រូវទាំងផ្នែកព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណី។ ចំពោះសំណងផ្នែករដ្ឋប្បវេណី គឺជាសិទ្ធិទាមទាររបស់ម្ចាស់ម៉ាក ហើយម្ចាស់ម៉ាកអាចធ្វើទាមទារសំណងនៃការខូចខាត ទៅតាមទំហំដែលខ្លួនបានរងការរំលោភបំពាន។ សំណងទាំងនោះរួមមាន៖ សំណងដែលកើតចេញពីការរំលោភបំពាន សំណងជាក់ស្តែងនាពេលបច្ចុប្បន្ន សំណងនាពេលអនាគត និងសំណងដែលរាប់ចាប់ពីពេលដែលអំពើរំលោភបំពានបានកើតមានឡើង។ ចំណែកឯផ្នែកព្រហ្មទណ្ឌវិញ គឺជាការផ្តន្ទាទោសពីសំណាក់ខាងតុលាការ ទៅកាន់ជនដែលបានក្លែងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ ជាក់ស្តែង បើផ្អែកទៅតាមមាត្រា៣៨ (បទក្លែងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ) នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជនដែលបានក្លែងម៉ាកនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ឆ្នាំ ទៅ ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ ២០លានរៀល ចំពោះអំពើដូចជា៖

- អំពើប្រើប្រាស់មិនត្រឹមត្រូវក្នុងគោលបំណងពាណិជ្ជកម្មដោយផ្ទាល់ ឬដោយប្រយោលនូវម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួចហើយ ចំពោះទំនិញដែលដូចគ្នា ឬទំនិញដែលអាចប្រៀបធៀបទៅនឹងទំនិញដែលបានចុះបញ្ជីដើម្បីឱ្យការប្រើប្រាស់នោះ ទទួលផលប្រយោជន៍ ឬអាចនឹងទទួលផលប្រយោជន៍ពីកេរ្តិ៍ឈ្មោះរបស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- ការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការធ្វើត្រាប់តាម ការធ្វើឱ្យនឹកគិតទៅដល់ ឬការបកប្រែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ទោះបីប្រភពពិតប្រាកដនៃទំនិញត្រូវបានអមដោយពាក្យដូចជា ស្ទីលយថាប្រភេទ ប្រភេទ វិធីសាស្ត្រ របៀប ត្រាប់តាម ឬការបកប្រែនៃពាក្យទាំងនេះ ឬពាក្យប្រហាក់ប្រហែលធ្វើឱ្យសាធារណជនកាន់ច្រឡំក៏ដោយ
- ការក្លែងបន្លំ ឬការធ្វើឱ្យភាន់ច្រឡំអំពីប្រភពដើម ប្រភេទ ឬគុណភាពពិសេសនៃទំនិញដែលបង្ហាញលើសំបកវេចខ្ចប់គ្រប់ប្រភេទ ឬលើឯកសារផ្សាយពាណិជ្ជកម្ម ឬលើឯកសារផ្សេងទៀតដែលទាក់ទងនឹងទំនិញ ដែលអាចនាំឱ្យមានការយល់ខុសអំពីប្រភពដើមរបស់ផលិតផល
- ការអនុវត្តផ្សេងៗទៀត ដែលអាចធ្វើឱ្យសាធារណជនទូទៅភាន់ច្រឡំអំពីប្រភពដើមពិតប្រាកដនៃទំនិញ។

[163] មាត្រា៣៧ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

មិនត្រឹមតែ ការទទួលខុសត្រូវរបស់រូបវន្តបុគ្គលតែម្នាក់ឯងនោះទេ គឺនីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសក្លែងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដូចរូបវន្តបុគ្គលផងដែរ។ នីតិបុគ្គលត្រូវផ្តន្ទាទោសដាក់ពិន័យជាប្រាក់ពី ២០លានរៀល ទៅ ៥០លានរៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន[164] ដូចតទៅនេះ៖

- ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០ (ការរំលាយនីតិបុគ្គល និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ
- ការដាក់ឱ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ
- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើនតាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ
- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈតាមបែបបទកំណត់ដោយមាត្រា១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមព្រហ្មទណ្ឌ
- រឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើសតាមបែបបទកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមព្រហ្មទណ្ឌ
- រឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស និងការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយ។

## ផ្នែកទី២៖ នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញតាមបទដ្ឋានគតិយុត្តអន្តរជាតិ

ដើម្បីទទួលបាននូវការការពារជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក្នុងកម្រិតអន្តរជាតិ ម្ចាស់ម៉ាក ត្រូវតែធ្វើការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅតាមប្រទេស ឬតំបន់ ដែលខ្លួនចង់ឱ្យទទួលបាននូវការការពារនូវម៉ាករបស់ខ្លួន។ ការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រជាលក្ខណៈអន្តរជាតិ គឺមានលក្ខណៈខុសប្លែកពីការចុះបញ្ជីនូវម៉ាកអន្តរជាតិ ព្រោះការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រ ធ្វើនៅក្នុងតំបន់មួយ គឺត្រូវបានការពារតែនៅក្នុងតំបន់

[164] មាត្រា៣៩ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

នោះតែប៉ុណ្ណោះ។ ដូចនេះ ការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងក្របខណ្ឌអន្តរជាតិ អាចធ្វើឡើងតាមរយៈ ការចុះបញ្ជីតាមកិច្ចព្រមព្រៀងពហុភាគី និងការចុះបញ្ជីតាមតំបន់ ឬតាមកិច្ចព្រមព្រៀងទ្វេភាគី ។

**កថាខណ្ឌទី១៖ ការចុះបញ្ជីតាមកិច្ចព្រមព្រៀងពហុភាគី**

ម្ចាស់ម៉ាកអាចធ្វើការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញស្របតាមក្របខណ្ឌគតិយុត្តអន្តរជាតិ តាមរយៈកិច្ចព្រមព្រៀងពហុភាគី (Multilateral Agreement) ដែលរួមមានប្រព័ន្ធទីក្រុងលីសប៊ន និងប្រព័ន្ធទីក្រុងម៉ាឌ្រីដ។

**ក. ប្រព័ន្ធទីក្រុងលីសប៊ន**

ច្បាប់ទីក្រុងហ្សឺណែវនៃកិច្ចព្រមព្រៀងទីក្រុងលីសប៊ន (Geneva Act of the Lisbon Agreement) ត្រូវបានអនុម័តនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ ដែលបានអនុញ្ញាតឱ្យមាននូវការចុះបញ្ជីអន្តរជាតិលើការការពារម៉ាកសម្គាល់ភូមិសាស្ត្រ និងឈ្មោះសម្គាល់នៃទីតាំងប្រភពដើម ដែលហៅថា "ប្រព័ន្ធទីក្រុងលីសប៊ន ឬ The Lisbon System"។ ប្រព័ន្ធទីក្រុងលីសប៊ន គឺជាប្រព័ន្ធសម្រាប់ធ្វើការចុះបញ្ជីអន្តរជាតិនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងឈ្មោះសម្គាល់នៃទីតាំងប្រភពដើម តាមរយៈនីតិវិធីនៃការចុះបញ្ជីតែមួយ (A Single Procedure) ជាមួយនឹងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ហើយនឹងត្រូវបានការពារនៅក្នុងរដ្ឋជាហត្ថលេខីនៃប្រព័ន្ធនេះ ដោយមិនចាំបាច់ចុះបញ្ជីការពារច្រើនដង។ ប្រទេសដែលជាសមាជិកនៅក្នុងប្រព័ន្ធចុះបញ្ជីអន្តរជាតិទីក្រុងលីសប៊ន រួមមានប្រទេសដែលជារដ្ឋលេខីនៃកិច្ចព្រមព្រៀងទីក្រុងលីសប៊ន (មានចំនួន ៣០ប្រទេស[165]) សហភាពអឺរ៉ុប[166] អង្គការកម្មសិទ្ធិបញ្ញាទ្វីបអាហ្វ្រិក និងប្រទេសកម្ពុជា។ ប្រទេសកម្ពុជា[167] បានដាក់តម្កល់លិខិតុបករណ៍នៃការចូលជាសមាជិកច្បាប់ទីក្រុងហ្សឺណែវស្តីពីកិច្ចព្រមព្រៀងទីក្រុងលីសប៊នអំពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងឈ្មោះសម្គាល់នៃទីតាំងប្រភពដើមទំនិញ នាថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ ហើយបានក្លាយជាសមាជិកពេញសិទ្ធិ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០២០។ ប្រព័ន្ធទីក្រុងលីសប៊ន បានផ្តល់នូវការការពារទៅលើឈ្មោះកំណត់សម្គាល់ប្រភពដើមភូមិសាស្ត្រទំនិញ ដូចជា កាហ្វេ តែ ផ្លែឈើ ស្រា កុម្ភការភណ្ឌ (គ្រឿងចានឆ្នាំង ភាជន៍) ភាជន៍ ឬកែវកញ្ចក់ និងសំលៀកបំពាក់។ **ឧទាហរណ៍** ផលិតផលដែលបានចុះបញ្ជីជាអន្តរជាតិនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងឈ្មោះសម្គាល់នៃទីតាំងប្រភពដើម រួមមាន៖ ម្រេចកំពត និងត្នោតដើមកំពង់ស្ពឺ ស្រាវីស្គីScotch តែDarjeeling កាហ្វេColombia នាឡិកាដៃ Swiss និងTequila។

165 *"Lisbon Agreement Contracting Treaties"*, WIPO, https://bit.ly/31dfCHA, ចូលមើលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

166 *"European Union joins Geneva Act of WIPO's Lisbon Agreement, Enabling Entry into Force"*, November 2019, https://bit.ly/2AjRUyy, ចូលមើលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

167 *"Cambodia first to join the Geneva Act of WIPO"s Lisbon Agreement"*, WIPO, March 2018, https://bit.ly/3dMgiX0, ចូលមើលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

បើយោងទៅតាម ច្បាប់ទីក្រុងហ្សឺណែវនៃកិច្ចព្រមព្រៀងទីក្រុងលីសប៊នដើម្បីទទួលបាននូវការការពារលក្ខណៈអន្តរជាតិ ត្រូវតែធ្វើការចុះបញ្ជីជាអន្តរជាតិ ទៅតាមនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់នេះ។ ដើម្បីបំពេញនូវលក្ខខណ្ឌចុះបញ្ជីជាអន្តរជាតិបាន ទាល់តែផលិតផលនោះ ត្រូវបានចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅក្នុងប្រទេសជាមុនសិន ទើបអាចយកផលិតផលនោះ ទៅចុះបញ្ជីជាអន្តរជាតិបាន។ ការចុះបញ្ជីជាអន្តរជាតិនូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបំពេញនីតិវិធីដូចតទៅ៖

### គ.១. ការដាក់ពាក្យសុំចុះបញ្ជី

ការដាក់ពាក្យសុំចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិ គឺជាដំណាក់កាលដំបូងនៃនីតិវិធីចុះបញ្ជីការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញជាលក្ខណៈអន្តរជាតិ។ ពាក្យសុំនេះ ត្រូវដាក់ទៅកាន់ការិយាល័យអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ហើយពាក្យសុំនេះ អាចធ្វើជាភាសាអងគ្លេស បារាំង ឬអេស្ប៉ាញ។ អ្នកដែលមានសិទ្ធិក្នុងការធ្វើពាក្យស្នើសុំចុះបញ្ជីនេះ ត្រូវតែជាភាគីពាក់ព័ន្ធនៃទីតាំងប្រភពដើម (Contracting of Origin) ឬអាជ្ញាធរមានសមត្ថកិច្ច ដែលមានសិទ្ធិអាចដាក់ពាក្យសុំដូចជា អ្នកទទួលផលប្រយោជន៍ ឬ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបាននូវសិទ្ធិស្របច្បាប់ពីភាគីពាក់ព័ន្ធនៃទីតាំងប្រភពដើម[168]។ ជាពិសេស អ្នកដាក់ពាក្យស្នើសុំនេះ ត្រូវតែបង់នូវថ្លៃសេវាសម្រាប់ការចុះបញ្ជី ទៅតាមការកំណត់របស់ការិយាល័យអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិនេះ ត្រូវតែបំពេញនូវលក្ខខណ្ឌកំណត់ ដូចទៅនឹងឧបសម្ព័ន្ធ២។

### គ.២. ការត្រួតពិនិត្យពាក្យស្នើសុំ

បន្ទាប់ពីទទួលបាននូវពាក្យស្នើសុំចុះបញ្ជី ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ត្រូវតែធ្វើការត្រួតពិនិត្យនូវពាក្យស្នើសុំនេះ[169]។ ក្នុងករណី ពាក្យស្នើសុំនេះ បានបំពេញគ្រប់លក្ខខណ្ឌកំណត់រួចហើយ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ត្រូវទទួលស្គាល់នូវពាក្យស្នើសុំនេះ ដោយត្រូវកត់ត្រាពាក្យស្នើសុំនេះ ទៅក្នុងបញ្ជីចុះឈ្មោះអន្តរជាតិ និងបោះពុម្ពផ្សាយនូវការចុះបញ្ជីនេះ។ ក្រោយមកទៀត ការិយាល័យអន្តរជាតិនេះ ត្រូវតែជូនដំណឹងពីការចុះបញ្ជីនេះ ទៅកាន់ភាគីនៃកិច្ចព្រមព្រៀង (ប្រទេសហត្ថលេខី) ទាំងអស់។

### គ.៣. ការឆ្លើយតបរបស់ភាគីនៃកិច្ចព្រមព្រៀង

ការឆ្លើយតបរបស់ភាគីនៃកិច្ចព្រមព្រៀង គឺជាដំណាក់កាលដ៏សំខាន់បំផុត ព្រោះប្រសិនបើមិនមាននូវការទទួលស្គាល់នូវការចុះបញ្ជីពីសំណាក់ភាគីនៃកិច្ចព្រមព្រៀងណាមួយនោះទេ នាំឱ្យការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺមិនអាចទទួលបាននូវការការពារក្នុងប្រទេសរបស់ភាគីនៃកិច្ចព្រមព្រៀងបដិសេធបានឡើយ។ ការ

---

[168] មាត្រា៣ នៃច្បាប់ទីក្រុងហ្សឺណែវនៃកិច្ចព្រមព្រៀងទីក្រុងលីសប៊ន និងវិធាន៥ នៃបទប្បញ្ញត្តិស្ថិតក្រោមច្បាប់ទីក្រុងហ្សឺណែវនៃកិច្ចព្រមព្រៀងទីក្រុងលីសប៊នស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងឈ្មោះសម្គាល់នៃទីតាំងប្រភពដើម

[169] មាត្រា៦ នៃច្បាប់ទីក្រុងហ្សឺណែវនៃកិច្ចព្រមព្រៀងទីក្រុងលីសប៊ន

ឆ្លើយតបនេះ ត្រូវធ្វើឡើងក្នុងថិរវេលាកំណត់មួយ គឺ១២ខែ បន្ទាប់ពីទទួលបាននូវការជូនដំណឹងពីសំណាក់ពីការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ ការឆ្លើយតបនេះ គឺភាគីនៃកិច្ចព្រមព្រៀងមានពីជម្រើសក្នុងការឆ្លើយតប ដោយជម្រើសទី១ បដិសេធនូវការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនេះក្នុងប្រទេសរបស់ខ្លួន និងជម្រើសទី២ ជូនដំណឹងពីការផ្តល់នូវការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងប្រទេសរបស់ខ្លួន។ ទោះបីជាភាគីនៃកិច្ចព្រមព្រៀង បានបដិសេធនូវការការពារក៏ដោយ ក៏ភាគីនៃកិច្ចព្រមព្រៀង នៅតែមានសិទ្ធិក្នុងការដកនូវការបដិសេធរបស់ខ្លួន ក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីបានធ្វើការបដិសេធ។ បន្ថែមពីនេះ ភាគីនៃកិច្ចព្រមព្រៀងដែលបានជូនដំណឹងថា នឹងផ្តល់នូវការការពារម៉ាកនេះ មានសិទ្ធិក្នុងការលុបចោល ឬមោឃភាពនៃការជូនដំណឹងនេះបានក្នុងរយៈពេល២ឆ្នាំ បន្ទាប់ពីបានធ្វើការជូនដំណឹង។

ក្រោយពីភាគីនៃកិច្ចព្រមព្រៀងនីមួយៗ បានឆ្លើយតបរួចហើយ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ត្រូវចេញវិញ្ញាបនបត្រជូន អ្នកដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីក្នុងប្រព័ន្ធទីក្រុងលីសបិន ដោយមានកំណត់នូវប្រទេសដែលទទួលស្គាល់នូវការចុះបញ្ជីនេះ។ ភាគីនៃកិច្ចព្រមព្រៀងនីមួយៗ ដែលបានទទួលស្គាល់នូវការចុះបញ្ជីនេះ ត្រូវតែធ្វើការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនេះ ដោយប្រើប្រាស់នូវប្រព័ន្ធច្បាប់របស់ខ្លួន និងបទដ្ឋានគតិយុត្តផ្សេងៗទៀត[170]។ ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ តាមប្រព័ន្ធទីក្រុងលីសបិន គឺមិនកំណត់ថិរវេលា ដូចការការពារតាមរយៈប្រព័ន្ធទីក្រុងម៉ាឌ្រីដ បានសេចក្តីថារយៈពេលនៃការការពារនឹងផុតរលត់ នៅពេលដែលម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបានលុបចេញពីការចុះបញ្ជី។

### ខ. ប្រព័ន្ធទីក្រុងម៉ាឌ្រីដ

ក្រៅពីការចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិតាមប្រព័ន្ធទីក្រុងលីសបិន ដើម្បីទទួលបាននូវការការពារជាលក្ខណៈអន្តរជាតិសម្រាប់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺម្ចាស់ម៉ាកនេះ អាចធ្វើការចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិតាមប្រព័ន្ធទីក្រុងម៉ាឌ្រីដ (The Madrid System) ក្នុងគោលបំណងទទួលបាននូវការការពារ ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រ នៅក្នុងប្រទេសដែលមិនមែនជារដ្ឋហត្ថលេខីនៃប្រព័ន្ធទីក្រុងលីសបិន។ កាលដែលចុះបញ្ជីតាមប្រព័ន្ធទីក្រុងម៉ាឌ្រីដ គឺម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវចុះបញ្ជីជាពាណិជ្ជនាម ដែលពាណិជ្ជនាមនេះ គឺគ្រប់ដណ្តប់ទៅម៉ាកសមូហភាព និងម៉ាកវិញ្ញាតកម្ម ហើយជាទូទៅការចុះបញ្ជីតាមប្រព័ន្ធនេះ ទទួលបាននូវការការពារបានតែដប់ឆ្នាំតែប៉ុណ្ណោះ ប៉ុន្តែអាចបន្តនូវរយៈពេលការពារបានបន្ថែមទៀត។

ប្រព័ន្ធទីក្រុងម៉ាឌ្រីដសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបានគ្រប់គ្រងដោយសន្ធិសញ្ញាចំនួន២៖ ទី១-កិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដឆ្នាំ១៨៩១ និងទី២-ពិធីសារដែលជាប់ទាក់នឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដនៅឆ្នាំ១៩៨៩។ ប្រព័ន្ធចុះបញ្ជីម៉ាកអន្តរជាតិទីក្រុងម៉ាឌ្រីដ អាចប្រើប្រាស់បានក្នុងចំណោមប្រទេសដែលជា

[170] ជំពូកទី៣ នៃច្បាប់ទីក្រុងហ្សឺណែវនៃកិច្ចព្រមព្រៀងទីក្រុងលីសបិន

ភាគីនៃកិច្ចព្រមព្រៀង ឬពិធីសារទីក្រុងម៉ាឌ្រីដ។ ប្រព័ន្ធទីក្រុងម៉ាឌ្រីដ ប្រព័ន្ធនេះបានផ្តល់ឱ្យនូវម្ចាស់នៃពាណិជ្ជនាម ទទួលបានការការពារម៉ាករបស់ខ្លួន នៅក្នុងប្រទេសមួយចំនួនដោយគ្រាន់តែដាក់ពាក្យសុំមួយទៅកាន់ការិយាល័យចុះបញ្ជីពាណិជ្ជនាម ហើយប្រើប្រាស់ភាសាតែមួយ និងកំណត់ថ្លៃសេវាជារូបិយប័ណ្ណមួយប្រភេទ។ ប្រព័ន្ធទីក្រុងម៉ាឌ្រីដនេះ ដែលចុះបញ្ជីតែមួយ អាចទទួលបាននូវការការពារពីប្រទេសដែលជាភាគីនៃកិច្ចព្រមព្រៀង ឬពិធីសារ លើសពីនេះ១២២ប្រទេស ហើយប្រទេសក៏ក្លាយជាភាគីនៃប្រព័ន្ធចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិនេះ នាថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥[171]។ ដូចនេះ ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញជាលក្ខណៈអន្តរជាតិ តាមប្រព័ន្ធទីក្រុងម៉ាឌ្រីដ ត្រូវអនុវត្តដូចគ្នានឹងការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ។

### ខ.១. ដំណាក់កាលទី១

មុននឹងអាចដាក់ពាក្យស្នើសុំក្នុងក្របខណ្ឌអន្តរជាតិ ម្ចាស់ម៉ាកត្រូវតែបានចុះបញ្ជី ឬបានដាក់ពាក្យស្នើសុំការពារម៉ាក នៅក្នុងប្រទេសខ្លួនរួចសិន ពីការិយាល័យទទួលបន្ទុកកម្មសិទ្ធិបញ្ញា[172] (ពាក់ព័ន្ធនឹងគម្រូនៃពាក្យស្នើសុំសូមមើលឧបសម្ព័ន្ធ២)។ ការចុះបញ្ជី ឬការដាក់ពាក្យសុំស្នើ ត្រូវបានគេស្គាល់ថា ជាការចុះបញ្ជីគោល បានន័យថា ការចុះបញ្ជីម៉ាកនៅការិយាល័យទទួលបន្ទុកកម្មសិទ្ធិបញ្ញា ដែលប្រើប្រាស់ពាក្យស្នើសុំនោះធ្វើជាមូលដ្ឋានសម្រាប់ការដាក់ពាក្យចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិតាមប្រព័ន្ធទីក្រុងម៉ាឌ្រីដ។ បន្ទាប់មក ម្ចាស់ម៉ាកត្រូវបញ្ជូនពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ទៅតាមការិយាល័យទទួលបន្ទុកកម្មសិទ្ធិបញ្ញាក្នុងប្រទេសរបស់ខ្លួន (ការិយាល័យដើម) ដែលការិយាល័យនេះត្រូវទទួលបន្ទុកត្រួតពិនិត្យពាក្យសុំ [173] និងធ្វើការបញ្ជូនបន្តទៅកាន់ការិយាល័យចុះបញ្ជីអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ នៅក្នុងពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិនេះ ត្រូវតែបំពេញនូវលក្ខខណ្ឌសំខាន់ៗមួយចំនួនដែលមានកំណត់នៅក្នុងពិធីសារទីក្រុងម៉ាឌ្រីដ [174] ។ ពាក្យស្នើសុំនេះ អាចធ្វើជាភាសាអង់គ្លេស បារាំង ឬអេស្ប៉ាញ នៅពេលដែលបញ្ជូនទៅកាន់ការិយាល័យដើម ហើយកាន់ការិយាល័យនេះ ត្រូវតែកំណត់ឱ្យបានច្បាស់លាស់ ដែលអនុញ្ញាតឱ្យជ្រើសរើសភាសាតែមួយ[175]។ លើសពីនេះ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវតែបង់នូវកម្រៃសេវា ទៅតាមការកំណត់របស់អង្គការកម្មសិទ្ធិបញ្ញាអន្តរជាតិ។

---

[171] *"Memberships of Madrid System"*, WIPO, 2020, https://bit.ly/2AFz84K, ចូលមើលនៅខែមិថុនា ឆ្នាំ២០២០

[172] វិធាន១៤ នៃបទប្បញ្ញត្តិទូទៅក្រោមកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងពិធីសារទាក់ទងនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ

[173] ពាក់ព័ន្ធនឹងចំណុចនេះ សូមមើល, ប្រកាសស្តីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ របស់ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ជាគម្រូសម្រាប់លំហូរនីតិវិធីក្នុងការការិយាល័យដើម

[174] វិធាន៩ នៃបទប្បញ្ញត្តិទូទៅក្រោមកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងពិធីសារទាក់ទងនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ

[175] វិធាន៦ នៃបទប្បញ្ញត្តិទូទៅក្រោមកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងពិធីសារទាក់ទងនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ

### ខ.២. ដំណាក់កាលទី២

អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ត្រូវធ្វើការត្រួតពិនិត្យជាផ្លូវការនូវពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តជាតិរបស់អ្នកដាក់ពាក្យស្នើសុំ (ម្ចាស់ម៉ាក) តែប៉ុណ្ណោះ។ នៅពេលដែលការត្រួតពិនិត្យត្រូវបានទទួលស្គាល់ នោះម៉ាករបស់អ្នកដាក់ពាក្យស្នើសុំ ត្រូវកត់ត្រាទៅក្នុងបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ[176] ហើយត្រូវបានបោះពុម្ពផ្សាយ នៅក្នុងព្រឹត្តបត្រផ្លូវការនៃបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក[177]។ បន្ទាប់មក អង្គការកម្មសិទ្ធិបញ្ញាពិភពលោកនឹងធ្វើនូវវិញ្ញាបនបត្រនៃការចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិ និងជូនដំណឹងដល់ការិយាល័យទទួលបន្ទុកកម្មសិទ្ធិបញ្ញាគ្រប់តំបន់ទាំងអស់ ដែលអ្នកដាក់ពាក្យស្នើសុំ ចង់ទទួលនូវការការពារនៃម៉ាករបស់ខ្លួន។

### ខ.៣. ដំណាក់កាលទី៣

ដំណាក់កាលនេះ គឺជាដំណាក់កាលសំខាន់បំផុត ដែលជាការត្រួតពិនិត្យធ្វើឡើងដោយការិយាល័យទទួលបន្ទុកកម្មសិទ្ធិបញ្ញាថ្នាក់ជាតិ ឬតំបន់ (ការិយាល័យនៃប្រទេសហត្ថលេខីដែលបានជ្រើសរើសសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ) ដែលអ្នកដាក់ពាក្យស្នើសុំដើម្បីទទួលបាននូវការការពារ។ ការិយាល័យទទួលបន្ទុកកម្មសិទ្ធិបញ្ញានៃប្រទេសដែលអ្នកដាក់ពាក្យស្នើសុំ ចង់ទទួលបាននូវការការពារនៃម៉ាករបស់ខ្លួន នឹងធ្វើការសម្រេចចិត្តចំពោះពាក្យស្នើសុំនេះ ក្នុងថិរវេលាកំណត់[178] (១២ខែ ឬ១៨ខែ) ស្របទៅតាមបទដ្ឋានគតិយុត្តរបស់ខ្លួន។ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក នឹងធ្វើការកត់ត្រានូវការសម្រេចចិត្តរបស់ការិយាល័យទទួលបន្ទុកកម្មសិទ្ធិបញ្ញាទាំងនោះ ចូលទៅក្នុងការចុះបញ្ជីក្របខណ្ឌអន្តរជាតិ និងជូនដំណឹងមកកាន់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី (ម្ចាស់ម៉ាក)។

ប្រសិនបើការិយាល័យទទួលបន្ទុកកម្មសិទ្ធិបញ្ញាណាមួយ បដិសេធមិនទទួលនូវការការពារទាំងស្រុង ឬដោយផ្នែកនៃម៉ាករបស់អ្នកដាក់ពាក្យស្នើសុំ ដែលនាំឱ្យការសម្រេចចិត្តបែបនេះ គឺមិនប៉ះពាល់ដល់ការសម្រេចចិត្តរបស់ការិយាល័យទទួលបន្ទុកកម្មសិទ្ធិបញ្ញាផ្សេងទៀតឡើយ។ ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ទទួលបាននូវការការពារក្នុងរយៈពេល ១០ឆ្នាំ ហើយម្ចាស់ម៉ាកអាចបន្តនូវរយៈពេលការពារថ្មីបាន ១០ឆ្នាំ បន្ទាប់ពីបញ្ចប់នូវរយៈពេលការពារ ដោយគ្រាន់តែជូនដំណឹងដោយផ្ទាល់ទៅកាន់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក៏មានប្រសិទ្ធភាពទៅ

---

176 វិធាន៣១ នៃបទប្បញ្ញត្តិទូទៅក្រោមកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងពិធីសារទាក់ទងនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ

177 វិធាន៣២ នៃបទប្បញ្ញត្តិទូទៅក្រោមកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងពិធីសារទាក់ទងនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ

178 មាត្រា៥ នៃពិធីសារទាក់ទងនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដលើការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ

ដល់ប្រទេសហត្ថលេខីដែលបានជ្រើសរើសផងដែរ។ ពាក់ព័ន្ធនឹងឧទាហរណ៍ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលត្រូវបានការពារនៅក្រោមប្រព័ន្ធទីក្រុងម៉ាឌ្រីដ សូមមើលឧបសម្ព័ន្ធ៤។

**កថាខណ្ឌទី២៖ ការចុះបញ្ជីតាមតំបន់ និងតាមកិច្ចព្រមព្រៀងទ្វេភាគី**

ក្រៅពី ការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងក្របខណ្ឌអន្តរជាតិតាមរយៈកិច្ចព្រមព្រៀងអន្តរជាតិពីរខាងលើនេះ ក៏មាននូវការចុះបញ្ជីជាអន្តរជាតិផ្សេងទៀត សម្រាប់ចុះបញ្ជីការពារជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញផងដែរ ដែលក្នុងនោះអាចមាន៖ ការចុះបញ្ជីតាមតំបន់ និងតាមកិច្ចព្រមព្រៀងទ្វេភាគី ។

**ក. ការចុះបញ្ជីតាមតំបន់** (**សហភាពអឺរ៉ុប**)

ទំនិញ ឬផលិតផល ដែលទទួលបាននូវការការពារជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងការក្របខណ្ឌអន្តរជាតិ ភាគច្រើនជាផលិតផលស្រា ឬស្រាទំពាំងបាយជូរ ហើយក្នុងចំណោមផលិតផលដែលជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញទាំងអស់ ប្រហែលជាង៨០ភាគរយ[179] គឺជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលចេញពីសហភាពអឺរ៉ុប។ ការដែលសហភាពអឺរ៉ុប ជាកន្លែងដែលសម្បូរម៉ាកសម្គាល់ភូមិសាស្ត្រទំនិញច្រើនជាងតំបន់ផ្សេងៗទៀត ព្រោះដើមកំណើតនៃការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺចេញពីទ្វីបអឺរ៉ុប និងជាកន្លែងដែលមាននូវផលិតផលប្រពៃណីច្រើនជាងគេផងដែរ។ ដូច្នេះ ពាក់ព័ន្ធនឹងការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញតាមតំបន់ គឺយើងនឹងសិក្សាពីសហភាពអឺរ៉ុប ព្រោះតំបន់នេះ មាននូវមូលដ្ឋានច្បាប់រឹងមាំ និងធ្វើការការពារយ៉ាងខ្លាំងទៅលើទំនិញ ឬផលិតផលប្រចាំតំបន់ ព្រមទាំងប្រទេសកម្ពុជាយើង ក៏ទើបនឹងចុះបញ្ជីនូវផលិតផលរបស់ខ្លួន គឺម្រេចកំពត និងស្ករត្នោតកំពង់ស្ពឺ ទៅចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅសហភាពអឺរ៉ុប ដើម្បីទទួលបាននូវការការពារក្នុងក្របខណ្ឌបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុប។

ម៉ាកសម្គាល់ភូមិសាស្ត្ររបស់សហភាពអឺរ៉ុប ត្រូវបានគ្រប់គ្រងដោយអគ្គនាយកដ្ឋានកសិកម្ម ដែលជាផ្នែកគោលការណ៍នៃគុណភាពផ្នែកម្ហូបអាហារ។ ស្ថិតក្រោមប្រព័ន្ធនេះ ផលិតផលកសិកម្មដែលបានចុះបញ្ជី នឹងទទួលបាននូវការការពារពីការចម្លងតាមតាមរយៈសហភាពអឺរ៉ុប។ ដំណើរការចុះបញ្ជី សម្រាប់អ្នកដាក់ពាក្យសុំដែលមិនមែនជាសមាជិករបស់សហគមន៍ គឺដូចគ្នាទៅនឹងសមាជិក ប៉ុន្តែត្រូវបញ្ចូលនូវលក្ខខណ្ឌជាក់លាក់មួយចំនួន។ ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មានពីរទម្រង់សំខាន់ៗគឺ៖ ការការពារឈ្មោះនៃទីតាំងប្រភពដើម និងការការពារម៉ាកទីតាំងភូមិសាស្ត្រទំនិញ។ ពាក្យសុំសម្រាប់ ឈ្មោះទីតាំងប្រភពដើម ត្រូវធ្វើឡើងដោយក្រុមនៃផលិតករដែលជាអ្នកត្រូវកំណត់ដោយច្បាស់លាស់នូវផលិផលដោយយោងតាមក្រមនៃការអនុវត្ត (Code of practices) ដែលមានផ្ទុកនូវព័ត៌មានលំអិត។ ព័ត៌មានទាំងនោះរួមមាន វិធីសាស្ត្រក្នុងការផលិត ដែលមានរួម ប្រភព ប្រភេទ និង

179 "Geographical Indications: A European treasure worth €75 billion", European Commission, April 2020, https://bit.ly/2CCbyaf, ចូលមើលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

លក្ខណៈនៃវត្ថុធាតុដើម ស្លាកសញ្ញា និងការវេចខ្ចប់។ ភស្តុតាងប្រវត្តសាស្ត្រ ដែលជាប់ទាក់ទងនឹងផលិតផល ឬ ដំណើរការទៅនឹងទីតាំងភូមិសាស្ត្រ ឬដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់នូវលក្ខណៈ ឬកេរ្តិ៍ឈ្មោះនៃផលិតផល ជាអាទិ៍។ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលស្ថិតនៅក្រៅសហភាពអឺរ៉ុបត្រូវតែផ្តល់ភស្តុតាងនៃការការពារនៅក្នុង ប្រទេសដែលជាប្រភពដើម។ ឈ្មោះប្រភពដើម ត្រូវតែមានការគ្រប់គ្រងដោយប្រព័ន្ធនៃការត្រួតពិនិត្យបង្កើតឡើង ដោយ សហភាពអឺរ៉ុប និងស្តង់ដាអន្តរជាតិ សម្រាប់ធានាបាននូវការប្រតិបត្តិតាមក្រមនៃការអនុវត្ត ដែលបង្កើតឡើង សម្រាប់ឈ្មោះប្រភពដើមជាពិសេស។

ជាធម្មតា ពាក្យសុំត្រូវដាក់ស្នើដោយរដ្ឋដែលជាសមាជិក បន្ទាប់មក ប្រសិនបើឈ្មោះនោះត្រូវនឹងលក្ខខណ្ឌ ចុះបញ្ជីរួចហើយ ត្រូវបញ្ជូនពាក្យសុំនេះ ទៅកាន់គណៈកម្មការអឺរ៉ុប។ ចាប់ពីឆ្នាំ ២០០៦ ផលិតករនៅប្រទេសទីបី (ដែលមិននៅក្នុងសហភាពអឺរ៉ុប) អាចដាក់ពាក្យសម្រាប់ទទួលស្គាល់ និងការពារជាការការពារឈ្មោះនៃទីតាំង ប្រភពដើម ឬការការពារម៉ាកទីតាំងភូមិសាស្ត្រទំនិញ ដោយផ្ទាល់ជាមួយនឹងគណៈកម្មការអឺរ៉ុប។ លក្ខខណ្ឌនៃការ ដាក់ពាក្យ គឺស្រដៀងនឹងអ្នកស្នើដាក់ពាក្យសុំទៅសហភាពអឺរ៉ុប លើកលែងតែភស្តុតាងបង្ហាញពីការការពារក្នុង ប្រទេសដែលជាប្រភពដើម។ នៅពេលគណៈកម្មការអឺរ៉ុបទទួលបាននូវពាក្យសុំដែលបានគោរពតាមលក្ខខណ្ឌ សម្រាប់ការចុះបញ្ជី នឹងធ្វើបោះផ្សាយនូវឯកសារមួយ នៅក្នុងព្រឹត្តិប័ត្រផ្លូវការនៃសហភាពអឺរ៉ុប ហើយបើកផ្លូវឱ្យមាន ការតវ៉ាប្រឆាំងទៅការចុះបញ្ជីក្នុងរយៈពេល៦ខែ ចាប់ពីថ្ងៃបោះពុម្ពផ្សាយ។ ការតវ៉ាប្រឆាំងទៅការចុះបញ្ជីអាចនឹង កើតមានឡើង និងត្រូវចាត់ចែងដោយរដ្ឋដែលជាសមាជិករបស់សហភាពអឺរ៉ុប ឬ ផ្ញើទៅដោយផ្ទាល់ទៅកាន់គណៈ កម្មការអឺរ៉ុបដោយអាជ្ញាធរថ្នាក់ជាតិ ឬដោយបុគ្គល។ ដោយយោងតាមការ អនុវត្តនូវវិធានរបស់គណៈកម្មការ អឺរ៉ុប ១៨៩៦/២០០៦ ការប្រឆាំងជំទាស់អាចធ្វើឡើងដោយផ្អែកលើផលិតផលមិនគោរពតាមលក្ខខណ្ឌដែល ទាមទារៈ

- ឈ្មោះផលិតផលមានភាពស្រដៀងគ្នា ឬអាចធ្វើឱ្យយល់ច្រលំជាមួយនឹងពូជដំណាំនានា ឬពូជសត្វ
- ឈ្មោះដែលមានលក្ខណៈសទិសសព្ទមួយផ្នែក ឬទាំងមូល(ការប្រកប និងការបញ្ចេញសម្លេងដូចគ្នា តែ អត្ថន័យ និងប្រភពខុសគ្នា) ជាមួយនឹងឈ្មោះដែលបានចុះបញ្ជីរួចរាល់
- ឈ្មោះត្រូវបានចុះបញ្ជីក្រោមពាណិជ្ជនាមដែលមានរួចរាល់
- ឈ្មោះដែលមិនមានភាពច្បាស់លាស់ ដែលមិនអាចទទួលបានការចុះបញ្ជី
- ត្រូវបានបង្ហាញថាការចុះបញ្ជីម៉ាកនឹងអាចធ្វើឱ្យប៉ះពាល់ដល់វត្តមានទាំងស្រុង ឬមួយផ្នែកនៃម៉ាកឬឈ្មោះ ដែលមានលក្ខណៈស្រដៀងគ្នា ឬវត្តមាននៃផលិតផលស្របច្បាប់ណាមួយនៅលើទីផ្សារដែលឈរលើទី ផ្សារយ៉ាងតិចចាប់ពី៥ឆ្នាំឡើង គិតចាប់ពីថ្ងៃដែលបានចេញលក់។

នៅពេលបណ្តឹងជំទាស់ត្រូវបានទទួលយក គណៈកម្មការអឺរ៉ុបនឹងផ្ញើរបាយការណ៍នៃបណ្តឹងជំទាស់ទៅកាន់អ្នកដែលដែលជាប់ពាក់ព័ន្ធ ឬអាជ្ញាធរថ្នាក់ជាតិ ដែលនឹងត្រូវបានអញ្ជើញមកដើម្បីធ្វើការពិគ្រោះយោបល់គ្នាជាមួយអ្នកជំទាស់នឹងស្វែងរកដំណោះស្រាយក្នុងរយៈពេល៦ខែ ចាប់គិតពីពេលដែលគណៈកម្មការ បានផ្ញើបន្តនូវរបាយការណ៍បណ្តឹងជំទាស់។ គណៈកម្មការ មិនចូលរួមក្នុងដំណើរការនេះឡើយ។ នៅចុងបញ្ចប់នៃថិរវេលាគណៈកម្មការត្រូវផ្តល់ដំណឹងអំពីលទ្ធផលនៃការពិគ្រោះយោបល់ ឬការជជែកពិភាក្សា ព្រមទាំងការផ្លាស់ប្តូរផ្សេងៗទៅនឹងការដាក់ពាក្យសុំ។ គណៈកម្មការ នឹងអាចផ្សព្វផ្សាយនូវការផ្លាស់ប្តូរផ្សេងៗទៅការដាក់ពាក្យសុំទៅក្នុងព្រឹត្តិប័ត្រផ្លូវការរបស់សហភាពអឺរ៉ុប និងអាចបើកឱ្យមានការបណ្តឹងជំទាស់លើកទីពីរ។ គណៈកម្មការទទួលបានអំណាចក្នុងការធ្វើការសម្រេច ថាការព្រមព្រៀងសម្របសម្រួលគ្នាអាចទទួលយកបាន ឬក៏មិនបាន។ មិនមែនជារឿងធម្មតាទេ ដែលដំណើរការនៃចុះបញ្ជីប្រើរយៈពេលមួយឆ្នាំ ប៉ុន្តែពេលខ្លះអាចប្រើរយៈពេលយូរជាងនេះទៅទៀត។

នៅពេលដែលត្រូវបានចុះបញ្ជីរួច ភាគីពាក់ព័ន្ធទាំងអស់នោះ ត្រូវគោរពប្រតិបត្តិទៅតាមលក្ខខណ្ឌដែលខ្លួនបានដាក់ភ្ជាប់មកជាមួយនឹងពាក្យស្នើសុំ។ ផ្នែកដែលសំខាន់មួយនៃនីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់សហភាពអឺរ៉ុប គឺការដាក់ការត្រួតពិនិត្យ ដែលជាមធ្យោបាយមួយដើម្បីធានាការប្រព្រឹត្តទៅតាមលក្ខខណ្ឌកំណត់។ ប្រទេសទីបី ត្រូវតែដាក់ពាក្យស្នើសុំរបស់ខ្លួនតាមរយៈអាជ្ញាធរដែលមានសមត្ថកិច្ចដោយការចាត់តាំងដោយប្រទេសនោះ និងគណៈវិនិច្ឆ័យ ឬអាជ្ញាធរដែលមានសមត្ថកិច្ចដោយការចាត់តាំង ដោយប្រទេសនោះ ឬគណៈវិនិច្ឆ័យ ដើម្បីធ្វើការបញ្ជាក់ផលិតផល ថាបានគោរពទៅតាមលក្ខខណ្ឌកំណត់ យោងទៅតាមបទដ្ឋានរបស់សហគមន៍អឺរ៉ុប។ ដោយសារតែប្រទេសកំពុងអភិវឌ្ឍ មិនអាចនឹងមាននូវសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យទទួលស្គាល់ អ្នកដែលមានចំណែកនឹងត្រូវអាចប្រើប្រាស់គណៈវិនិច្ឆ័យទទួលស្គាល់អន្តរជាតិ ដែលនឹងអាចបង្កើននូវតម្លៃស្វែងរក និងនីតិវិធី។

គណៈកម្មការអឺរ៉ុប មិនអាចអាចចាត់ការត្រួតពិនិត្យដោយខ្លួនឯងបានទេ លើកលែងតែមានកំហុសរំលោភបំពានធ្ងន់ធ្ងរ។ អ្នកដាក់ពាក្យសុំ ដែលជារដ្ឋជាសមាជិក ឬប្រទេសដែលមិនមែនជាសមាជិកនៃសហភាពអឺរ៉ុប មានតួនាទីទទួលខុសត្រូវទាំងស្រុងលើបញ្ហានេះ។ ឱ្យតែមានការគោរពទៅតាមលក្ខខណ្ឌកំណត់ដែលចែងក្នុងពាក្យស្នើសុំ ដោយមានការទទួលស្គាល់ពីអ្នកត្រួតពិនិត្យឈ្មោះសម្គាល់នឹងត្រូវមានសុពលភាព។ ឈ្មោះដែលចុះបញ្ជីរួច ត្រូវបានការពារដោយស្របច្បាប់តាមរយៈសហភាពអឺរ៉ុប ទប់ទល់នឹងការចម្លងតាម និងអាចប្រើប្រាស់ឡូហ្គោសហភាពអឺរ៉ុបមកធ្វើជាស្លាកសញ្ញាសម្រាប់ម៉ាកសញ្ញាដែលទទួលបានការការពារ។ ស្លាកសញ្ញាក៏អាចសម្គាល់ផងដែរ ដែលផលិតផលចុះបញ្ជីរួច ផលិតករណាមួយដែលស្ថិតក្នុងតំបន់ដែលបានកំណត់ និងមានការបញ្ជាក់ថាបានគោរពទៅតាមលក្ខខណ្ឌកំណត់ នោះនឹងត្រូវអនុញ្ញាតឱ្យប្រើប្រាស់ឈ្មោះ។ ដូច្នេះ ឈ្មោះនោះនឹងទទួលបានសិទ្ធិផ្តាច់មុខសម្រាប់តែតំបន់ភូមិសាស្ត្រនោះ ប៉ុន្តែមិនមែនសម្រាប់ផលិតករ ឬ ក្រុមហ៊ុនណាមួយឡើយ។

សហភាពអឺរ៉ុប អាស្រ័យលើរដ្ឋដែលជាសមាជិក ដើម្បីដាក់ចេញនូវការការពារម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រនៅក្នុងវិសាលភាពទឹកដីរបស់ខ្លួន និងមិនពឹងពាក់ស្ថាប័នណាមួយដាច់ដោយឡែកសម្រាប់ការតាមដាននិងពង្រឹងការអនុវត្ត នោះទេ។ ទោះបីប្រទេសនីមួយៗ មាននូវរចនាសម្ព័ន្ធពិសេសដាច់ដោយឡែក ក៏ប្រទេសមួយចំនួនគោរពតាមគោលការណ៍ទូទៅ ដែលនៅពេលចាត់វិធានការលើការរំលោភបំពាន។ ការរំលោភបំពាននៅក្នុងប្រទេសមួយ គឺត្រូវចាត់វិធានការនៅក្នុងប្រទេសដែលជាប្រភពដើម ឬកន្លែងដែលការរំលោភបំពានកើតឡើង។ ការរំលោភបំពានជាអន្តរជាតិ ដែលរាប់បញ្ចូលនូវជំនួញពីប្រទេសមួយទៅប្រទេសមួយទៀត ឬបទល្មើស ដែលត្រូវចាត់វិធានការដោយប្រទេសរៀងៗខ្លួន ប៉ុន្តែក៏អាចត្រូវយកមកដោះស្រាយដោយគណៈកម្មការអឺរ៉ុប ដែលមានអំណាចក្នុងការសម្របសម្រួលជាមួយនឹងប្រទេសដែលមាននូវបទល្មើសកើតឡើង និងអាចដាក់ទណ្ឌកម្មផងដែរ។

ច្បាប់គណៈកម្មការអឺរ៉ុប អនុញ្ញាតឱ្យរដ្ឋជាសមាជិក គិតនូវថ្លៃសេវាក្នុងការប៉ះប៉ូវសម្រាប់ការចំណាយលើការពិនិត្យលើពាក្យស្នើសុំសម្រាប់ការចុះបញ្ជី ពាក្យបណ្តឹងជំទាស់ ពាក្យសុំសម្រាប់ការធ្វើវិសោធនកម្ម និង សំណើសម្រាប់ការលុបចោល។ ថ្លៃសេវាប្រែប្រួលទៅតាមរដ្ឋដែលជាសមាជិក។ ទោះបីជាយ៉ាងណា រដ្ឋចំនួនពីរដូចជាចក្រភពអង់គ្លេស និងអៀឡង់ មិនយកថ្លៃសេវាសម្រាប់ សេវាកម្មដាក់ពាក្យសុំ PDO ឬPGI។ មិនមាននូវការកំណត់ថ្លៃសេវាសម្រាប់ការដាក់ពាក្យស្នើសុំដោយផ្ទាល់ទៅកាន់គណៈកម្មការ ដោយប្រទេសដែលមិនមែនជាសមាជិកសហភាពអឺរ៉ុប (Third country)។

នៅក្នុងសហភាពអឺរ៉ុប ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបានរៀបចំដាច់ដោយឡែកពីប្រព័ន្ធពាណិជ្ជនាម និងការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយមិនចាំបាច់ប្រើប្រាស់ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាឯកជន (Private Intellectual Property Laws)។ អ្នកដែលចុះបញ្ជី ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញភាគច្រើននៅសហភាពអឺរ៉ុប គឺចុះបញ្ជីពាណិជ្ជនាមជានិមិត្តសញ្ញា។ Cheese Roquefort ជាឧទាហរណ៍មួយ ដែលជាការការពារឈ្មោះនៃទីតាំងប្រភពដើម និងការការពារជាពាណិជ្ជនាម សម្រាប់ម៉ាកពីរផ្សេងគ្នាដែលរាប់បញ្ចូលឈ្មោះសម្គាល់។

### ខ. ការចុះបញ្ជីតាមកិច្ចព្រមព្រៀងទ្វេភាគី

លើសពីនេះ ការចុះបញ្ជីជាអន្តរជាតិ ក៏អាចធ្វើឡើងតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី (Bilateral Agreement) ផងដែរ។ កិច្ចព្រមព្រៀងនេះ គឺអាចធ្វើឡើងរវាងប្រទេសជាមួយប្រទេសដែលមានព្រំប្រទល់ជាប់គ្នា ឬរវាងប្រទេសដែលធ្វើពាណិជ្ជកម្មសេរីជាមួយគ្នា ជាដើម។ ជាក់ស្តែង ប្រទេសដែលបានធ្វើនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីច្រើនជាងគេ គឺសហរដ្ឋអាមេរិក ដែលជាប្រទេសមហាអំណាចសេដ្ឋកិច្ចទី១ ក្នុងពិភពលោក ហើយក៏ជាប្រទេសដែលបាននាំចេញនូវទំនិញ ឬផលិតផល ជាច្រើនទៅកាន់ទីផ្សារពិភពលោកផងដែរ។ សហរដ្ឋអាមេរិក មានទំនិញ ឬផលិតផលដែលបានចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ប្រហែល ១,០០០ផលិតផល ហើយក្នុងចំណោមផលិតផលទាំងអស់នោះ ភាគច្រើនជាផលិតផលស្រា ប៉ុន្តែជាផលិតផលដែលមានប្រភពមកពីបរទេស

ច្រើនជាងផលិតផលក្នុងស្រុក។ ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅសហរដ្ឋអាមេរិក គឺធ្វើឡើងតាមរយៈការចុះបញ្ជីពាណិជ្ជនាម ឬម៉ាកវិញ្ញាតកម្ម ឬក៏ម៉ាកសមូហភាព ដោយមិនមាននូវច្បាប់ពិសេសណាមួយ ដាច់ដោយឡែកសម្រាប់ការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដូចនៅបណ្តាប្រទេសមួយចំនួនឡើយ។ ដូច្នេះ នៅពេលដែលប្រទេសណាមួយ ចង់ធ្វើការចុះបញ្ជីការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់ខ្លួន ក្នុងសហរដ្ឋអាមេរិក គឺចាំបាច់ត្រូវតែធ្វើការជ្រើសរើសយកប្រព័ន្ធចុះបញ្ជីការពារមួយណាដែលខ្លួនចង់បាន។ នីតិវិធីការចុះបញ្ជីសម្រាប់ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបំពេញតាមលំហូរដូចខាងក្រោមនេះ៖

ពាក្យស្នើសុំសម្រាប់ម៉ាកវិញ្ញាតកម្ម ឬម៉ាកសមូហភាព ត្រូវផ្ញើរទៅកាន់ទីស្នាក់ការប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជនាមប្រចាំសហរដ្ឋអាមេរិក (USPTO) ដែលត្រូវចាត់ទុកជាប្រភេទពាក្យស្នើសុំពាណិជ្ជនាមមួយប្រភេទដែលធ្វើឡើងដោយភាគីដែលជាប់ពាក់ព័ន្ធ ឬតាមរយៈសេវាកម្មមេធាវី។ នៅពេលពាក្យស្នើសុំចុះបញ្ជីម៉ាកត្រូវបានទទួល ស្ថាប័នទទួលបន្ទុកត្រូវធ្វើការពិនិត្យទៅលើផ្នែកទម្រង់ និងគតិយុត្តផ្សេងៗ ដើម្បីធានាឱ្យបាននូវការប្រព្រឹត្តស្របច្បាប់ និងស្ថិតក្រោមកម្មវត្ថុនៃការបោះផ្សាយជាសាធារណៈសម្រាប់ការត្រួតពិនិត្យ និងការជំទាស់នានាមុននឹងការចុះបញ្ជី។ សម្រាប់ ម៉ាកវិញ្ញាតកម្ម(Certification mark) ត្រូវបន្ថែមលើការគោរពទៅតាមលក្ខខណ្ឌនៃពាណិជ្ជនាម ទីស្នាក់ការប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជនាមប្រចាំសហរដ្ឋអាមេរិក(USPTO) ទាមទារឱ្យអ្នកដាក់ពាក្យស្នើសុំត្រូវប្រគល់ឯកសារបទដ្ឋាននៃការទទួលស្គាល់មួយច្បាប់ ថតចម្លងមួយច្បាប់ និងមធ្យោបាយក្នុងការដាក់ឱ្យអនុវត្ត រួចរក្សាទុកនូវឯកសារទាំងនេះជាកំណត់ត្រាផ្លូវការ។ ដូចគ្នានេះដែរ ពាក្យសុំសម្រាប់ម៉ាកសមូហភាព ត្រូវបន្ថែមពីលើការបញ្ជាក់ឱ្យច្បាស់ និងផ្ទុកនូវចំណុចសំខាន់ៗក្នុងពាក្យសុំសម្គាល់ម៉ាក ហើយនោះក៏ត្រូវកំណត់បញ្ជាក់ឱ្យច្បាស់លាស់អំពីទំនាក់ទំនងរវាងក្រុម និងសមាជិក ហើយបង្ហាញឱ្យឃើញថាតើ អ្នកដាក់ពាក្យស្នើសុំ (ជាក្រុម ឬសមូហភាព) ធ្វើការត្រួតពិនិត្យទៅលើការប្រើប្រាស់ម៉ាកដោយសមាជិករបស់ពួកគេ តាមវិធីបែបណា។

នៅអំឡុងពេលដំណើរការដាក់ពាក្យស្នើសុំ មេធាវីរបស់ទីស្នាក់ការប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជនាមប្រចាំសហរដ្ឋអាមេរិក នឹងធ្វើការត្រួតពិនិត្យឡើងវិញលើពាក្យស្នើសុំ ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅតាមច្បាប់ជាមួយលក្ខខណ្ឌបញ្ញត្តិមួយចំនួន។ ដំណើរការនេះរាប់បញ្ចូលទាំង ការជំទាស់ប្រឆាំង ដែលអនុញ្ញាតឱ្យមាននូវតតិយជនធ្វើការប្រឆាំងទៅនឹងពាក្យស្នើសុំ មុនពេលមាននូវការសេចក្តីរបស់ទីស្នាក់ការប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជនាមប្រចាំសហរដ្ឋអាមេរិក ព្រមទាំងគណៈកម្មការវិនិច្ឆ័យ និងបណ្តឹងឧទ្ធរណ៍ម៉ាក(TTAB)។ វិធានការសម្រាប់បណ្តឹងជំទាស់ដែលស្វែងរកការពារការចុះបញ្ជីម៉ាក ត្រូវដាក់ពាក់ជាមួយនឹងគណៈកម្មការវិនិច្ឆ័យ និងបណ្តឹងឧទ្ធរណ៍ម៉ាក ដោយយោងតាមការជឿជាក់របស់ភាគីជំទាស់ថា នឹងមានការខូចខាតដោយសារតែការចុះបញ្ជីម៉ាក។

ពាក្យបណ្តឹងជំទាស់ អាចនឹងដាក់បានសម្រាប់តែការឆ្លើយតបនឹងការផ្សព្វផ្សាយជាសាធារណៈក្នុងព្រឹត្តិប័ត្រផ្លូវការក្នុងអំឡុងពេលដំណើរការដាក់ពាក្យស្នើសុំ។ ទម្រង់ការសម្រាប់ការប្តឹងជំទាស់ ឬលុបចោលនូវម៉ាក ទៅកាន់គណៈកម្មការវិនិច្ឆ័យ និងបណ្តឹងឧទ្ធរណ៍ម៉ាក គឺស្រដៀងទៅនឹងបណ្តឹងស៊ីវិលទៅកាន់តុលាការថ្នាក់ស្រុក។ សកម្មភាពទាំងនោះមួយដូចជា ការជជែកតវ៉ាក្តី និងការស្នើដាក់ញត្តិសម្រាប់ការសំណើរផ្សេងៗ ការប្តូរ ឬឯកសារសំណុំរឿងរវាងគូក្តី និងសេចក្តីសង្ខេបលើអង្គហេតុនៃរឿងក្តី និងភ្ជាប់ជាមួយការសម្រេចសេចក្តីទៅលើសំណុំរឿងក្តី។ ភាគីដែលចាញ់នៅត្រឹមគណៈកម្មការវិនិច្ឆ័យ និងបណ្តឹងឧទ្ធរណ៍ម៉ាក អាចបន្តប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេច ឬសាលក្រមរបស់គណៈកម្មការវិនិច្ឆ័យ និងបណ្តឹងឧទ្ធរណ៍ម៉ាក រួចមធ្យោបាយចុងក្រោយគេគឺ ភាគីចាញ់ក្តីត្រូវបន្តប្តឹងសាទុក្ខទៅកាន់តុលាការកំពូលនៃសហរដ្ឋអាមេរិក។

ជាទូទៅ រយៈពេលកម្មសិទ្ធិនៃម៉ាកក្នុងសហរដ្ឋអាមេរិក គឺគ្មានដែនកំណត់ឱ្យតែម្ចាស់កម្មសិទ្ធិធ្វើការដាក់លិខិតបញ្ជាក់ ឬលិខិតដែលជូនដំណឹងដែលអាចយកជាការបានសម្រាប់ការបន្តរយៈពេល ទៅកាន់ទីស្នាក់ការប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជនាមប្រចាំសហរដ្ឋអាមេរិក រួមជាមួយនឹងថ្លៃសេវាដែលបានកំណត់ និងសមស្របទៅតាមលក្ខខណ្ឌបទដ្ឋានសម្រាប់ការការពារពាណិជ្ជនាម (ការការពារដោយយកចិត្តទុកដាក់ ឬការដាក់ការត្រួតពិនិត្យលើម៉ាក)។ ការដាក់ពាក្យស្នើសុំ ដើម្បីទទួលបាននូវម៉ាកវិញ្ញាតកម្ម គឺមិនតម្រូវទាមទារឱ្យការធ្វើពាណិជ្ជកម្មដំបូង ប្រើប្រាស់លក្ខខណ្ឌភូមិសាស្ត្រជាការសម្គាល់ប្រភពដើម។ ម៉ាកវិញ្ញាតកម្មត្រូវតែបំពេញលក្ខខណ្ឌបទដ្ឋានបន្ថែម ដើម្បីរក្សានូវសុពលភាពនៃការចុះបញ្ជី។ ការខកខានមិនបានគោរពតាមនោះ នឹងអាចប្រឈមនឹងការលុបចោលនូវការចុះបញ្ជី ប្រសិនបើមាននូវពាក្យបណ្តឹងណាមួយដាក់ទៅកាន់គណៈកម្មការវិនិច្ឆ័យ និងបណ្តឹងឧទ្ធរណ៍ម៉ាក។ បទដ្ឋាននោះអាចនឹងមានភាពសាមញ្ញ ឬស្មុគស្មាញ អាស្រ័យតាមការស្នើរបស់អ្នកដាក់ពាក្យ។ ក្រោមច្បាប់សហរដ្ឋអាមេរិក ម្ចាស់ម៉ាកវិញ្ញាតកម្មអាចនឹងប្រឈមមុខផ្លូវច្បាប់ ដូចជា ការបាត់បង់នូវម៉ាក ដោយសារតែអ្នកប្រើប្រាស់ ឬអ្នកនឹងប្រើប្រាស់ ប្រសិនបើអ្នកបញ្ជាក់ ប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ។ ជាក់ស្តែង មិនបានត្រួតពិនិត្យលើការប្រើប្រាស់លើម៉ាក ការប្រកាន់ ឬបដិសេធការបញ្ជាក់ ឬអនុញ្ញាតនូវការប្រើប្រាស់ម៉ាកសម្រាប់គោលបំណងផ្សេងទៀតក្រៅពីអ្វីដែលបានចុះបញ្ជី។ ម៉ាកសមូហភាព នឹងរក្សាការគ្រប់គ្រង ប៉ុន្តែមាននូវលក្ខខណ្ឌតិចតួចសម្រាប់ការរក្សានូវសុពលភាពចុះបញ្ជី និងត្រូវបានចាត់ទុកដូចជាពាណិជ្ជនាមធម្មតាស្ថិតក្រោមការបន្តធ្វើជាថ្មី។

តម្លៃសម្រាប់ការចុះបញ្ជីម៉ាកវិញ្ញាតកម្ម ឬម៉ាកសមូហភាពមានកម្រិតទាប ដែលចាប់ពីឆ្នាំ២០០៩ គឺ ២៧៥ ទៅ ៣៧៥ដុល្លារអាមេរិក។ ទីស្នាក់ការប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជនាម បោះផ្សាយនូវកាលវិភាគតម្លៃសេវា។ ទោះយ៉ាងណាក៏ដោយ តម្លៃសេវាផ្សេងៗទៀត ស្ថិតលើសកម្មភាព និងប្រតិបត្តិការជំនួញផ្សេងៗរបស់បុគ្គលដែលមានតម្លៃចាប់ពី ៥០ ទៅ៤០០ ដុល្លារអាមេរិក។ ដំណើរការនៃការដាក់ពាក្យស្នើសុំ អាចប្រើរយៈពេលជាច្រើនខែ ដោយអាស្រ័យលើប្រភេទនៃការដាក់ពាក្យស្នើសុំ និងបញ្ហាផ្នែកច្បាប់ដែលអាចកើតឡើងនៅពេលធ្វើការត្រួតពិនិត្យ

ឬការជំទាស់។ ទោះបីជា អង្គភាពមួយដាក់ពាក្យសម្រាប់ការចុះបញ្ជីដោយផ្ទាល់ ការណែនាំ ឬការតំណាងដោយមេធាវីផ្នែកពាណិជ្ជនាមដែលមានអាជ្ញាបណ្ណ គឺគួរតែមានភាពស្មុគស្មាញនៃការចុះបញ្ជី ជាពិសេសគឺនៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍន៍។ ថ្លៃសេវាផ្នែកច្បាប់ គឺមានភាពខុសគ្នាអាស្រ័យលើប្រភេទ និងការវិវត្ត ក្នុងអំឡុងពេលនៃការដាក់ពាក្យស្នើសុំ។

ម៉ាកវិញ្ញាតកម្ម (ព្រមទាំងម៉ាកសមូហភាពដោយតាមការសន្មត) អាចកើតឡើងជាបញ្ហាសម្រាប់ប្រព័ន្ធច្បាប់ឥតសរសេរ (Common law) ដោយគ្មានការចុះបញ្ជីត្រឹមត្រូវនៅទីស្នាក់ការប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជនាមប្រចាំសហរដ្ឋអាមេរិក។ ប្រសិនបើម៉ាក ត្រូវបានគ្រប់គ្រងនៅតាមតំបន់ក្នុងទីផ្សារបរទេស ផលិតផលត្រូវបានដាក់លក់នៅតាមទីផ្សារសហរដ្ឋអាមរិក ហើយគ្មានអ្នកណាម្នាក់ប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញសម្រាប់ផលិតផលនោះ វានឹងអាចកើតមាននូវការការពារពាណិជ្ជនាមតាមប្រព័ន្ធឥតសរសេរ សម្រាប់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះ។ ជាក់ស្តែង ផលិតករអឺរ៉ុប អាចទទួលបានការការពារតាមប្រព័ន្ធច្បាប់ឥតសរសេរនៃម៉ាកសម្គាល់ភូមិសាស្ត្ររបស់ពួកគេនៅក្នុងសហរដ្ឋអាមេរិកដោយមិនចាំបាច់ជាប់ទាក់ទងថា តើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវបានការពារក្រោមច្បាប់ការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់រដ្ឋដែលជាសមាជិករបស់សហភាពអឺរ៉ុប។ ការអនុវត្ត គឺអាចអនុវត្តនៅក្នុងប្រព័ន្ធយុត្តាធិការផ្សេងៗដែរ។ ឧទាហរណ៍ដូចជា ស្រា Cognac ដែលជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នៅក្នុងសហរដ្ឋអាមេរិក ដែលជាទំនិញទទួលបានភាពជោគជ័យ ប៉ុន្តែមាននូវបទពិសោធន៍ ឬករណីយុត្តិសាស្ត្រតិចតួចណាស់ ព្រោះសំណុំរឿង និងបណ្តឹងវិវាទ សម្រាប់ប្រភេទបញ្ហាគឺកម្រ។

ជាចុងក្រោយ នៅពេលម៉ាកត្រូវបានចុះបញ្ជី វាត្រូវតែបានការពារដោយម្ចាស់ម៉ាក ឬអ្នកកាន់អាជ្ញាបណ្ណដែលទទួលបានពីតតិយជន។ បទល្មើសម៉ាក គឺត្រូវបានចង្អុលបង្ហាញតាមរយៈវិស័យឯកជន( ដូចជា វិធីសាស្ត្រមជ្ឈត្តការ ឬនីតិវិធីតុលាការ)។ ការតាមដានពីការរំលោភបំពាន ឬការល្មើស និងសំណុំរឿងបណ្តឹង គឺត្រូវធ្វើឡើងក្រោមឆន្ទៈ និងការចំណាយរបស់ម្ចាស់ម៉ាក ហើយរដ្ឋាភិបាល គឺមិនចូលរួមចំណែកនោះទេ។ ប្រសិនបើមានតតិយជនដែលគ្មានសិទ្ធិក្នុងការប្រើប្រាស់ត្រូវបានទទួលការសង្ស័យ នោះម្ចាស់ម៉ាកគួរតែស្វះស្វែងរកអ្នកប្រឹក្សាឯកទេសជំនាញច្បាប់ពាណិជ្ជនាម ពីព្រោះការអូសបន្លាយឱ្យអ្នកដទៃប្រើប្រាសនឹងធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការការពារនៃម៉ាក។

សហរដ្ឋអាមេរិក គឺជាភាគីនៃពិធីសារទីក្រុងម៉ាឌ្រីដ ដែលម្ចាស់ម៉ាកអាចនឹងស្វះស្វែងធ្វើការចុះបញ្ជីនៅក្នុងប្រទេសណាមួយក្នុងចំណោម១០៦ប្រទេស ដែលជាម្ចាស់ហត្ថលេខីនៃពិធីសារដោយដាក់ពាក្យសុំមួយច្បាប់ ដែលហៅថាពាក្យស្នើសុំលក្ខណៈអន្តរជាតិ។ ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅទីក្រុងហ្សឺណែវគ្រប់គ្រងលើប្រព័ន្ធចុះបញ្ជីអន្តរជាតិ។ ឧទាហរណ៍ អ្នកដាក់ពាក្យស្នើសុំអាចប្រគល់នូវពាក្យស្នើសុំពាក្យស្នើសុំលក្ខណៈអន្តរជាតិទៅកាន់ទីស្នាក់ការប្រកាសនីយបត្រតក្កកម្ម និងពាណិជ្ជនាម ប្រចាំសហរដ្ឋអាមេរិក ផ្នែកការចុះ

បញ្ជីម៉ាករបស់សហរដ្ឋអាមេរិក ឬពាក្យសុំ បន្ទាប់ដាក់ស្នើទៅកាន់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ ការចុះបញ្ជីបែបអន្តរជាតិ គឺមិនដូចទៅនឹងការចុះបញ្ជីនៅក្នុងបណ្តាប្រទេសណាមួយឡើយ។ អ្នកដាក់ពាក្យសុំ ឬអ្នកចុះបញ្ជី ត្រូវតែជាអ្នកមានលំនៅអចិន្ត្រៃយ៍ ឬមានសញ្ជាតិអាមេរិក ឬមាននូវទីតាំងពាណិជ្ជកម្មនៅទីនោះ។

ប្រទេសបែបកសិកម្ម ឬកសិ-ឧស្សាហកម្ម គួរតែធ្វើការចុះបញ្ជីនូវផលិតផលរបស់ខ្លួន ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជាមួយបណ្តាប្រទេសធំៗក្នុងពិភពលោក ជាក់ស្តែងក្រៅពីសហរដ្ឋអាមេរិក អាចធ្វើការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ តាមរយៈកិច្ចព្រមព្រៀងទ្វេភាគីជាមួយនឹងប្រទេសចិន និងឥណ្ឌា ជាដើម។ ចំពោះប្រទេសចិន ការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺធ្វើឡើងតាមរយៈការចុះបញ្ជីជាពាណិជ្ជនាម ដូចសហរដ្ឋអាមេរិកផងដែរ ចំណែកឯប្រទេសឥណ្ឌា គឺធ្វើឡើងតាមរយៈប្រព័ន្ធពិសេសមួយ ដែលមានកំណត់នៅក្នុងច្បាប់ស្តីពីការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឆ្នាំ១៩៩៩។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "**ក្របខណ្ឌគតិយុត្តសម្រាប់ការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញតាមបទបរិជាតិ និងអន្តរជាតិ**" រួចមក អាចបញ្ជាក់ឱ្យឃើញថា ប្រធានបទមួយនេះបានបង្ហាញពីតួនាទីដ៏សំខាន់របស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនទៅដល់កសិករ ផលិតករ ឬពាណិជ្ជករក្នុងតំបន់ភូមិសាស្ត្រ និងជួយលើកតម្កើងនូវវិស័យកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា កាន់តែល្អប្រសើរឡើងតាមរយៈការជំរុញឱ្យមាននូវការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់ម្ចាស់សិទ្ធិ និងភាគីដែលជាប់ពាក់ព័ន្ធ។ ដូចដែលបានបកស្រាយខាងលើនេះ គឺផលិតផល ឬទំនិញណាមួយ ដែលស្ថិតនៅក្នុងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ដែលចង់ទទួលបាននូវការការពារស្របច្បាប់ តាមរយៈបទប្បញ្ញត្តិជាធរមាន ចាំបាច់ត្រូវតែធ្វើការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ទៅតាមលក្ខខណ្ឌកំណត់របស់ច្បាប់។ ការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវធ្វើឡើងតាមរូបភាពពីរបែបនេះ គឺការចុះបញ្ជីតាមបរិបទជាតិ (ការការពារក្នុងប្រទេស) និងការចុះបញ្ជីតាមបរិបទអន្តរជាតិ (ការការពារក្នុងក្របខណ្ឌអន្តរជាតិ)។

ការដែលបង្កើតឱ្យមាននូវប្រព័ន្ធចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដើម្បីទទួលបាននូវការការពារតាមផ្លូវច្បាប់ គឺបានស្តែងចេញឱ្យឃើញពីការជំរុញនូវការបង្កើតស្នាដៃថ្មីៗ ដែលអាចជួយឱ្យជីវភាពរបស់ប្រជាជនក្នុងតំបន់ កាន់តែប្រសើរឡើង និងធ្វើឱ្យផលិតផល ឬទំនិញរបស់ផលិតករ កាន់តែមានតម្លៃខ្ពស់ជាងពីមុន។ លើសពីនេះ ចំពោះវិស័យពាណិជ្ជកម្ម ការការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គឺធ្វើឱ្យទំហំនៃការនាំចេញផលិតផលទៅកាន់បណ្តាប្រទេស មានការកើនឡើងខ្ពស់ ព្រោះនៅពេលដែលផលិតផលមួយ ត្រូវបានទទួលនូវការការពារនៅក្នុងប្រទេសណាមួយ នាំឱ្យអ្នកប្រើប្រាស់ កាន់តែមានទំនុកចិត្តខ្ពស់ ជឿជាក់ និងអាចទិញនូវផលិតផលដែលមានគុណភាពខ្ពស់ ដែលប្រើប្រាស់ទៅមិនប៉ះពាល់ដល់សុខភាព។ ទន្ទឹងនឹងនេះ ការចុះបញ្ជី អាចជួយការពារ និងអភិរក្សប្រពៃណី ទំនៀមទម្លាប់ ឬប្រវត្តិសាស្ត្រនៃការផលិតទំនិញរបស់ប្រជាជនក្នុងតំបន់ភូមិសាស្ត្រណាមួយ ជៀសផុតពីការបាត់បង់ ហើយក៏អាចជួយឱ្យផលិតផលប្រពៃណី អាចក្លាយជាសម្បត្តិបេតិកភណ្ឌពិភពលោក។ ជាក់ស្តែងដូចផលិតផលស្រាស្រំប៉ាញរបស់ប្រទេសបារាំង ត្រូវបានចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោក ដោយសារតែប្រពៃណីនៃការផលិតនោះមានអាយុកាលច្រើនឆ្នាំ និងមានលក្ខណៈពិសេសខុសពីការផលិតស្រាផ្សេងៗទៀត។

ក៏ប៉ុន្តែ ទោះបីជាទំនិញ ឬផលិតផលនេះ បានចុះបញ្ជីការពាររួចហើយ ក៏នៅតែជួបប្រទះនូវការរំលោភបំពានមួយចំនួនផងដែរ តាមរយៈការលួចចម្លងផលិតផល ដែលធ្វើឱ្យខូចប្រយោជន៍យ៉ាងខ្លាំងដល់ម្ចាស់ម៉ាក និងភាគីដែលជាប់ពាក់ព័ន្ធនឹងផលិតផលនេះ។ យ៉ាងណាក្តី វាក៏ជាប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈផងដែរ ដូចជាផលិតផលចំណីអាហារដែលអាចប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ ជាពិសេសប្រជាពលរដ្ឋក្នុងសង្គមជាតិទាំងមូល។ ដើម្បីដោះស្រាយនូវបញ្ហាទាំងអស់នោះ អាជ្ញាធរមានសមត្ថកិច្ចក៏បានធ្វើការសម្របសម្រួល និងប្រើ

ប្រាស់នូវយន្តការដោះស្រាយតាមផ្លូវច្បាប់ ដែលមានកំណត់នៅក្នុងបទប្បញ្ញត្តិច្បាប់នៅជាធរមាន អាចជាវិធានការណែនាំ ការរឹបអូសនៃទំនិញដែលរំលោភបំពានលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជី ឬការដោះស្រាយតាមផ្លូវតុលាការក្នុងករណីមានការរំលោភបំពានកាន់តែធ្ងន់ធ្ងរឡើងៗ។

# អនុសាសន៍

# អនុសាសន៍

ទោះបីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដោយបទប្បញ្ញត្តិស្តីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នាឆ្នាំ២០១៤ក៏ដោយ ក៏ម៉ាកនេះនៅតែជាម៉ាកថ្មីសន្លាងនៅក្នុងវិស័យកម្មសិទ្ធិបញ្ញារបស់ព្រះរាជាណាចក្រកម្ពុជា ព្រោះមកដល់សព្វថ្ងៃនេះ មានតែទំនិញ ឬផលិតផលរបស់កម្ពុជាមួយចំនួនតែប៉ុណ្ណោះ ដែលត្រូវបានចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយមានការសម្របសម្រួលពីខាងនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ហើយនៅក្នុងចំណោមទំនិញទាំងបីមុខនេះ គឺមានតែ ម្រេចកំពត និងស្ករត្នោតកំពង់ស្ពឺ ដែលត្រូវបានចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជាកម្រិតអន្តរជាតិ នៅក្នុងសហគមន៍អឺរ៉ុប។ លើសពីនេះ នាដើមឆ្នាំ២០២០ ប្រទេសកម្ពុជា ទើបនឹងក្លាយជាភាគីនៃកិច្ចព្រមព្រៀងលើច្បាប់ទីក្រុងហ្សឺណែវនៃកិច្ចព្រមព្រៀងទីក្រុងលីសបិនស្តីពីការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងក្របខណ្ឌអន្តរជាតិ។

ដូច្នេះក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "**ក្របខណ្ឌគតិយុត្តសម្រាប់ការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញតាមបទបរិជាតិ និងអន្តរជាតិ**" យើងខ្ញុំ សូមផ្តល់ជាអនុសាសន៍ក្នុងន័យកែលម្អ ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍវិស័យកម្មសិទ្ធិបញ្ញា ជាពិសេសម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចតទៅះ

- ជំរុញឱ្យកសិករ ផលិតករ ឬប្រតិបត្តិករ នៃផលិតផល ឬទំនិញណាមួយដែលជាផលិតផលប្រចាំតំបន់ គួរឱ្យធ្វើការចុះបញ្ជីនូវផលិតផលរបស់ខ្លួន ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមិនថាការចុះបញ្ជីក្នុងកម្រិតជាតិ ឬអន្តរជាតិ ដើម្បីទទួលបាននូវអត្ថប្រយោជន៍យ៉ាងច្រើន ជាពិសេស គឺធ្វើឱ្យទំនិញនៃផលិតផលនោះ មានការកើនឡើង និងទទួលបាននូវការការពារស្របច្បាប់ ព្រមទាំងអាចជួយផ្សព្វផ្សាយ ឬអភិរក្សនៃប្រពៃណីផលិតបែបបុរាណ ឬប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា។
- ស្ថាប័នដែលជាប់ពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជាពិសេសនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម បន្តនូវសកម្មភាពផ្សព្វផ្សាយពីការចុះបញ្ជីទំនិញ ឬផលិតផលរបស់តំបន់ណាមួយ (ប្រចាំតំបន់) នៃព្រះរាជាណាចក្រកម្ពុជា ធ្វើការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដើម្បីទទួលបាននូវការការពារតាមផ្លូវច្បាប់ ក្នុងករណីមានការរំលោភបំពាន និងអាចទទួលបាននូវអត្ថប្រយោជន៍យ៉ាងច្រើន ពីការចុះបញ្ជីនេះ និងធ្វើការផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឱ្យបានកាន់តែទូលាយច្រើនជាងមុន ទៅដល់ប្រជាជននៅតាមតំបន់ដែលឈានមុខក្នុងវិស័យកសិកម្ម។
- ក្រសួងស្ថាប័នដែលពាក់ព័ន្ធ គួរតែជួយសហការបន្ថែមជាមួយនឹងកសិករ ផលិតករ ឬប្រតិបត្តិករដែលក្លាយ ជាម្ចាស់ម៉ាកនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងកម្រិតជាតិ ធ្វើយ៉ាងណាឱ្យ

ផលិតផលដែលទទួលបាននូវការការពារ ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងកម្រិតជាតិ អាចទទួលបាននូវការការពារក្នុងក្របខណ្ឌអន្តរជាតិ។ ការដែលធ្វើឱ្យផលិតផល ឬទំនិញណាមួយ ត្រូវទទួលបាននូវការការពារក្នុងក្របខណ្ឌអន្តរជាតិនេះ អាចធ្វើឱ្យវិស័យពាណិជ្ជកម្ម កាន់តែមានស្ទុះខ្លាំងជាងមុន តាមរយៈនូវការនាំចេញនូវផលិតផលដែលត្រូវបានទទួលស្គាល់គុណភាពជាកម្រិតអន្តរជាតិ។

- អាជ្ញាធរដែលមានសមត្ថកិច្ច ក្នុងការទទួលបន្ទុកបង្ក្រាបអំពើរំលោភបំពានលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ បន្តនូវសកម្មភាព និងពង្រឹងនៃវិធានការដោះស្រាយតាមផ្លូវច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាព និងតាក់តែងនូវបទប្បញ្ញត្តិបន្ថែមសម្រាប់សម្របសម្រួលក្នុងការដោះស្រាយពេលមានអំពើរំលោភបំពានកាន់តែធ្ងន់ធ្ងរ។
- ជាពិសេស ស្នើសុំឱ្យរាជរដ្ឋាភិបាល និងអង្គភាពពាក់ព័ន្ធគួរតែជំរុញ និងសម្រួលដល់នីតិវិធីក្នុងការទទួលបានម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្រិតជាតិ ឱ្យកាន់តែមានភាពងាយស្រួល ដើម្បីសម្រួលដល់នីតិវិធីនៃការចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិ ដែលមានលក្ខណៈស្មុគស្មាញ និងបច្ចេកទេស។

# ឯកសារយោង

# ឯកសារយោង

## ក. បទដ្ឋានគតិយុត្តអន្តរជាតិ

- អនុសញ្ញាទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ឆ្នាំ១៨៨៣
- កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ឆ្នាំ១៩៩៤
- កិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដទាក់ទងនឹងការចុះបញ្ជីអន្តរជាតិនៃម៉ាក ឆ្នាំ១៨៩១
- កិច្ចព្រមព្រៀងទីក្រុងបង់ហ្គីស្តីពីអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក ឆ្នាំ១៩៧៧
- កិច្ចព្រមព្រៀងរវាងសហគមន៍អឺរ៉ុប និងអូស្ត្រាលីស្តីពីការជំនួញស្រាទំពាំងបាយជូរ ឆ្នាំ១៩៩៤
- កិច្ចព្រមព្រៀងសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក ស្តីពីជំនួញស្រាទំពាំងបាយជូរ ឆ្នាំ២០០៦
- កិច្ចព្រមព្រៀងទីក្រុងលីសប៊នស្តីពីការការពារឈ្មោះសម្គាល់ទីតាំងនៃប្រភពដើម និងការចុះបញ្ជីលក្ខណៈអន្តរជាតិ ឆ្នាំ១៩៥៨
- កិច្ចព្រមព្រៀងម៉ាឌ្រីដស្តីពីការបង្ក្រាបនៃការក្លែងបន្លំ ឬការបោកបញ្ឆោតនៃសញ្ញាសម្គាល់ប្រភពទំនិញ ឆ្នាំ១៨៩១
- កិច្ចព្រមព្រៀងរវាងសហគមន៍អឺរ៉ុប និងកាណាដាស្តីពីការជំនួញស្រាទំពាំងបាយជូរ និងស្រាដបឆ្នាំ២០០៣
- កិច្ចព្រមព្រៀងរវាងសហគមន៍អឺរ៉ុប និងម៉ិកស៊ិកស្តីពីការជ្រើសរើសនូវប្រភេទស្រាដែលមានកម្រិតអាកុលខ្ពស់ ឆ្នាំ១៩៩៨
- ពិធីការទីក្រុងបង់ហ្ស៊ុលស្តីពីម៉ាក ឆ្នាំ១៩៩៣
- ពិធីការទាក់ទងនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដលើការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឆ្នាំ១៩៨៩
- បទប្បញ្ញត្តិទូទៅក្រោមកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងពិធីសារទាក់ទងនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ ឆ្នាំ២០០៩
- ច្បាប់ទីក្រុងហ្សឺណែវនៃកិច្ចព្រមព្រៀងទីក្រុងលីសប៊នឆ្នាំ២០១៥

## ខ. បទដ្ឋានគតិយុត្តជាតិ

- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៤/០០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤

- ច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦
- ច្បាប់ស្ដីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២
- ច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០

**គ. ប្រកាស**

- ប្រកាសលេខ៤២២ ពណ.កសប.ប្រក ស្ដីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦
- ប្រកាសលេខ១០៥ ពណ.កសប.ប្រក ស្ដីពីនីតិវិធីណែនាំការចុះបញ្ជី និងការការពារម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩
- ប្រកាសលេខ១២៥ ពណ.កសប.ប្រក ស្ដីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧
- ប្រកាសលេខ៣៦៨ ពណ.កសប.ប្រក ស្ដីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦
- ប្រកាសរួមលេខ១២១៧ សហវ.ប្រក ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧

**ឃ. សៀវភៅពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ**


- Daniele Giovannnucci, Tim Josling, William Kerr, Bernard O'Connor and May T. Yeung, *"Guide to geographical indications: linking products and their origins"*, International Trade Centre, Geneva, 2009.
- *"Geographical indications and TRIPs: 10 Years Later…A roadmap for EU GI holders to get protection in other WTO Members",* O'CONNOR AND COMPANY (EUROPEAN LAWYERS), 2006, p.2-18.
- Louis Augustin-Jean, Héléne Ilbert, and Neantro Saavedra-Rivano, *"Geographical Indications and International Agricultural Trade: The challenge for Asia"*, Palgrave Macmillan, London, 1st edition, 2012.
- "Appellations of Origin", World Intellectual Property Organization (WIPO), 2018
- "World Intellectual Property Indicators 2019", World Intellectual Property Organization (WIPO), Geneva, 2019.

- *“Records of Diplomatic Conference for the Adoption of New Act of the Lisbon Agreement for the Protection of Appellations of Origin and their International Registration”*, World Intellectual Property Organization, Geneva, 2019.
- *“Guide to the International Registration of Marks under the Madrid Agreement and the Madrid Protocol”,* World Intellectual Property Organization, Geneva, 2019.

## ខ. អត្ថបទស្រាវជ្រាវផ្សេងៗ

- *“Geographical Indications: An Introduction”,* World Intellectual Property Organization (WIPO), Geneva, 2017.
- “Why Geographical Indications for Least Developed Countries (LDCs)?”, UNCTAD, 2015.
- Irina Kireeva, and Wang Xiaobing, *“European Legislation on Protection of Geographical Indications: Overview of the EU Member States’ Legal Framework for Protection of Geographical Indications”*, IPKEY, China, February 2011.
- *“Main Provisions and Benefits of the Geneva Act of the Lisbon Agreement”,* World Intellectual Property Organization (WIPO), 2015.
- R. M. Williams, *“Do geographical indications promote sustainable rural development?”*, Lincoln and BOKU University, 2007.
- Anne Laumonier, *“A French point of view on geographical indications”*, Ministry of Agriculture and Food-France, 2016.
- *“The value of geographical indications for business”*, European IPR Helpdesk, September 2016.
- Jean-Marie Brun, *“The five pillars of a Protected Geographical Indication”, GRET Cambodia, 2019.*
- *“Protected Geographical Indication in Cambodia”, Ministry of Commerce and Ministry of Agriculture, Forestry and Fisher, May 2010.*
- *“Guide to Geographical Indications in China”*, China IPR, 2018.
- Alexandra Grazioli, *“Seeking Protection Abroad: The Madrid and Lisbon System”,* World Intellectual Property Organization and State Administration for Industry and Commerce, Yangzhoun, 2017.

## ខ. គេហទំព័រ

- ក្រសួងពាណិជ្ជកម្ម៖ http://www.moc.gov.kh/km-kh/
- នាយកដ្ឋានកម្មសិទ្ធិបញ្ញា៖ http://www.cambodiaip.gov.kh/Default.aspx
- អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)៖ https://www.wipo.int/portal/en/index.html
- អង្គការពាណិជ្ជកម្មពិភពលោក (WTO)៖ https://www.wto.org/
- អង្គភាពព័ត៌មាន Fresh News៖ http://www.freshnewsasia.com

- អង្គភាពព័ត៌មានថ្មីៗ៖ https://thmeythmey.com/
- ប្រតិបត្តិការទ្វីបអឺរ៉ុប៖ https://ec.europa.eu/info/index_en
- អង្គការយូណេស្កូ៖ https://en.unesco.org/
- អង្គភាពព័ត៌មាន RFI៖ https://www.rfi.fr/km/

## បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធ១ បទប្បញ្ញត្តិជាតិ និងអន្តរជាតិសំខាន់ៗពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ
- ឧបសម្ព័ន្ធ២ គម្រូនៃពាក្យស្នើសុំចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ
- ឧបសម្ព័ន្ធ៣ ស្លាកសញ្ញាសម្រាប់សម្គាល់ជាម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ
- ឧបសម្ព័ន្ធ៤ ឧទាហរណ៍ពាក់ព័ន្ធម៉ាកសម្គាល់ភូមិសាស្រ្តទំនិញចុះបញ្ជីតាមប្រព័ន្ធទីក្រុងម៉ាឌ្រីដ
- ឧបសម្ព័ន្ធ៥ វិញ្ញាបនបត្រជាម៉ាកសម្គាល់ភូមិសាស្រ្តទំនិញលើផលិតផលម្រេចកំពត

# ឧបសម្ព័ន្ធ១

## បទប្បញ្ញត្តិជាតិ និងអន្តរជាតិសំខាន់ៗពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
*Ministry of Commerce*
លេខ ៤៦២ ព.ណ.កសប.ប្រក

# ប្រកាស

## ស្តីពី

## នីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញព្រះរាជក្រមលេខនស/រកម/០១១៤/០០៦ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ/បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងអនុវត្តបទប្បញ្ញត្តិនៃច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឲ្យបាន កាន់តែមានប្រសិទ្ធភាព ។

**ប្រការ២.- គោលដៅ**

ប្រកាសនេះមានគោលដៅ៖

- កំណត់វិធាន និងនីតិវិធីស្តីពី ការគ្រប់គ្រង ការចុះបញ្ជី ការទទួលស្គាល់ និងកិច្ចការពារម៉ាក សម្គាល់ភូមិសាស្ត្រ
- ការពារកម្មសិទ្ធិបញ្ញារបស់ផលិតករ ប្រតិបត្តិករ និងអ្នកប្រើប្រាស់ផលិតផលសម្គាល់ភូមិសាស្ត្រ
- អភិរក្ស និងពង្រឹងចំណេះដឹង ចំណេះធ្វើតាមបែបប្រពៃណី និងអត្តសញ្ញាណជាតិ
- បង្កើតការងារនៅជនបទ អភិវឌ្ឍសហគមន៍ក្នុងស្រុក កាត់បន្ថយភាពក្រីក្រ និងទាក់ទាញភ្ញៀវ ទេសចរណ៍ ។

**ប្រការ៣.- វាក្យសព្ទបច្ចេកទេស**

វាក្យសព្ទបច្ចេកទេសដែលបានប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- "ច្បាប់" សំដៅដល់ច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- "ម៉ាកសម្គាល់ភូមិសាស្ត្រ" សំដៅដល់ " ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ" ដូចមានចែងក្នុងមាត្រា ៤ នៃច្បាប់
- "សមាគមសម្គាល់ភូមិសាស្ត្រ" សំដៅដល់ ក្រុមតំណាងផលិតករ អង្គភាពផលិតករ និង/ឬ ប្រតិបត្តិករ ដែលទទួលផលប្រយោជន៍ពីម៉ាកសម្គាល់ភូមិសាស្ត្រ ដូចមានចែងក្នុងមាត្រា ៧ នៃ ច្បាប់ និងត្រូវបានទទួលស្គាល់ជាម្ចាស់នៃម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួច
- "ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ" សំដៅដល់ "ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ ភូមិសាស្ត្រទំនិញ" ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់ គឺជាក្រុមប្រឹក្សាអន្តរក្រសួងដែលបង្កើតឡើង ដោយអនុក្រឹត្យ ដើម្បីសិក្សាជំរុញ និងអភិវឌ្ឍផលិតផលសក្តានុពលសម្រាប់ធ្វើការចុះបញ្ជីជាម៉ាក សម្គាល់ភូមិសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដោះស្រាយបណ្តឹងតវ៉ាទាក់ទងនឹងការចុះ បញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ
- "អ្នកដាក់ពាក្យស្នើសុំ" សំដៅដល់សមាគមសម្គាល់ភូមិសាស្ត្រ ក្នុងគោលបំណងដាក់ពាក្យស្នើសុំ ចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រណាមួយ
- "ទំនិញ" សំដៅដល់ទំនិញកសិផល ទំនិញកសិចំណីអាហារ ទំនិញសិប្បកម្ម ឬទំនិញផ្សេងៗ ទៀតដែលផលិត ឬកែច្នៃក្នុងតំបន់ភូមិសាស្ត្រនោះ
- "រូបសញ្ញាជាតិ" សំដៅដល់ និមិត្តសញ្ញាដែលប្រើប្រាស់សម្រាប់បញ្ជាក់លើទំនិញសម្គាល់ភូមិ សាស្ត្រ និងម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមាន

ចែងក្នុងមាត្រា ១៤ នៃច្បាប់

- "PGI" សំដៅដល់ "ម៉ាកសម្គាល់ភូមិសាស្ត្រដែលបានការពារ" ជាភាសាខ្មែរ ឬ "Protected Geographical Indication" ជាភាសាអង់គ្លេស ឬការបកប្រែទៅជាភាសាណាមួយ
- "មន្ត្រីកាន់កាប់បញ្ជី" សំដៅដល់មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដែលទទួលបន្ទុកពិនិត្យ និងសម្រេចចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ និងកិច្ចការពាក់ព័ន្ធ
- "អាជ្ញាធរមានសមត្ថកិច្ច" សំដៅដល់ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២
## អាជ្ញាធរមានសមត្ថកិច្ច

**ប្រការ៤.- ភារកិច្ចរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា**

នាយកដ្ឋានកម្មសិទ្ធិបញ្ញាជាសេនាធិការរបស់ក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចខាងក្រោម៖

- ទទួលនិងត្រួតពិនិត្យទម្រង់ និងខ្លឹមសារ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ
- ត្រួតពិនិត្យសៀវភៅបន្ទុក និងឯកសារពាក់ព័ន្ធ
- ទទួលពាក្យបណ្តឹងជំទាស់ សេចក្តីថ្លែងតប និងបណ្តឹងតវ៉ា
- ចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ កែតម្រូវ កែសម្រួល ធ្វើមោឃភាព និងលុបម៉ាកសម្គាល់ភូមិសាស្ត្រ
- សម្រុះសម្រួលវិវាទពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ ដូចជាសវនាការក្នុងនីតិវិធីបណ្តឹងជំទាស់
- ពិនិត្យ និងសម្រេចកិច្ចការផ្សេងៗទៀតពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ
- បោះពុម្ពផ្សាយរាល់ការចុះបញ្ជី ការកែតម្រូវ ការកែសម្រួល ការធ្វើមោឃភាព និងការលុបការចុះបញ្ជីនៃម៉ាកសម្គាល់ភូមិសាស្ត្រក្នុងព្រឹត្តិបត្រផ្លូវការ
- គ្រប់គ្រង និងផ្តល់ការអនុញ្ញាតឲ្យប្រើប្រាស់រូបសញ្ញាជាតិ
- ពិនិត្យ និងពិចារណាលើការណែនាំផ្សេងៗទៀតពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ ដែលទទួលបានដោយក្រសួងពាណិជ្ជកម្ម
- អនុវត្តតាមសេចក្តីណែនាំ អនុសាសន៍ ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ឬតុលាការ
- តម្កល់ទុករាល់បញ្ជីការ និងឯកសារពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ
- ជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ដែលអនុវត្តកិច្ចការផ្សេងៗទៀតពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ ។

## ជំពូកទី៣
## នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ

### ផ្នែកទី១
### ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ

**ប្រការ៥.- អ្នកដាក់ពាក្យស្នើសុំ**

១. ដោយអនុលោមតាមមាត្រា ៧ នៃច្បាប់ អ្នកដាក់ពាក្យស្នើសុំត្រូវផ្តល់ភស្តុតាងបញ្ជាក់ពីលទ្ធភាពរបស់ខ្លួន ដើម្បីការពារនិងគ្រប់គ្រងម៉ាកសម្គាល់ភូមិសាស្ត្រ ។

អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

ក. ព្រាងសៀវភៅបន្ទុកចូលរួមចំណែកដល់ការអនុវត្តតាមសៀវភៅបន្ទុក ពីបណ្តាផលិតករ សមាជិក និងប្រតិបត្តិករ ព្រមទាំងចូលរួមក្នុងការអនុវត្តផែនការត្រួតពិនិត្យ ជាពិសេសការត្រួតពិនិត្យផ្ទៃក្នុង

ខ. តម្កល់ទុកបញ្ជីផលិតករ និង/ឬប្រតិបត្តិករនៃម៉ាកសម្គាល់ភូមិសាស្ត្រ ហើយត្រូវបញ្ជូនបញ្ជីនោះទៅអង្គភាពត្រួតពិនិត្យ និងនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម

គ. ចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រ ជាពិសេស ឈ្មោះ និងដែនដី ការវាយតម្លៃអំពីផលិតផល ព្រមទាំងចំណេះដឹងផ្នែកស្ថិតិនៃចង្វាក់តម្លៃ ។

២. នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ អ្នកដាក់ពាក្យស្នើសុំត្រូវផ្តល់ឯកសារមួយចំនួនមកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម៖

ក. វិធាន និងបទបញ្ជាគ្រប់គ្រងផ្ទៃក្នុងរបស់អង្គភាព ឬសមាគម ប្រសិនបើមានព័ត៌មានដែលប្រើប្រាស់សម្រាប់វាយតម្លៃលើភាពជាអ្នកតំណាងនៃផលិតករ និង/ឬប្រតិបត្តិករ ហើយទ្រង់ទ្រាយតំណាងឲ្យប្រភេទផ្សេងៗគ្នានៃប្រតិបត្តិករសម្រាប់ផលិតផល ដែលកំពុងស្នើសុំត្រូវឲ្យមានតុល្យភាពនឹងគ្នា

ខ. ព័ត៌មានស្តីពីអង្គភាពនិងធនធាន ដែលបានលះបង់ចំពោះកិច្ចការ ដូចបានកំណត់ក្នុងកថាខណ្ឌ (១)

គ. អនុវត្តតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ ។

៣. នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម អាចតម្រូវឲ្យអ្នកស្នើសុំផ្តល់ព័ត៌មានបន្ថែម ដើម្បីពិចារណាអំពីការទទួលស្គាល់សមាគម ហើយប្រតិបត្តិករទាំងនោះ ត្រូវមានឆន្ទៈអនុវត្តតាមវិធាននៃម៉ាកសម្គាល់ភូមិសាស្ត្រ ដោយមិនត្រូវបង្កឧបសគ្គដល់ការចូលរួម ដែលនាំឲ្យមានការរើសអើង ឬលើកលែងតែមានគោលដៅផ្ទុយពីនេះ ។

**ប្រការ៦.- ផលិតករ ឬប្រតិបត្តិករតែមួយ**

១. ក្នុងករណីដែលរូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ អាចត្រូវបានចាត់ទុកជាសមាគមសម្គាល់ភូមិសាស្ត្រ ឬក្រុមបាន លុះត្រាតែសមាគមនោះបានបំពេញលក្ខខណ្ឌទាំងពីរដូចខាងក្រោម៖

ក. បុគ្គលពាក់ព័ន្ធជាផលិតករតែម្នាក់គត់ ដែលមានឆន្ទៈក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជី

ខ. ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រ តំបន់ភូមិសាស្ត្រដែលបានកំណត់ត្រូវមានចរិតលក្ខណៈដែលធ្វើឲ្យខុសគ្នាដាច់ពីបណ្តាតំបន់ភូមិសាស្ត្រជិតខាង ឬចរិតលក្ខណៈនៃផលិតផល ត្រូវមានលក្ខណៈខុសពីផលិតផលដែលបានផលិតក្នុងបណ្តាតំបន់ជិតខាងនោះ ។

២. យោងតាមកថាខ័ណ្ឌ១ សមាគមសម្គាល់ភូមិសាស្ត្រ ឬក្រុម ដែលស្ថិតក្រោមស្ថានភាពបែបនេះនៅតែបើកចំហរចំពោះផលិតករ ឬប្រតិបត្តិករថ្មី ដែលមានឆន្ទៈអនុវត្តតាមវិធាននៃម៉ាកសម្គាល់ភូមិសាស្ត្រ ។

**ប្រការ៧.- សមាគមសម្គាល់ភូមិសាស្ត្រ**

១. ដោយមិនធ្វើឲ្យប៉ះពាល់បទប្បញ្ញត្តិដាក់លាក់ស្តីពីអង្គភាពផលិតករ និងអន្តរសាខានៃអង្គភាព

នោះ សមាគមសម្គាល់ភូមិសាស្ត្រមានសិទ្ធិដើម្បី៖

ក. ចូលរួមចំណែកក្នុងការធានាថា គុណភាព កិត្តិសព្ទ និងភាពត្រឹមត្រូវនៃផលិតផលរបស់អង្គភាពត្រូវបានធានានៅលើទីផ្សារ តាមរយៈការត្រួតពិនិត្យការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រក្នុងវិស័យពាណិជ្ជកម្ម ហើយក្នុងករណីចាំបាច់ ត្រូវជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងជំពូកទី ២ នៃច្បាប់

ខ. ចាត់វិធានការដើម្បីធានាឲ្យមានកិច្ចការពារតាមផ្លូវច្បាប់ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានចុះបញ្ជីរួច និងសិទ្ធិកម្មសិទ្ធិបញ្ញាដែលពាក់ព័ន្ធផ្ទាល់ទៅនឹងម៉ាកសម្គាល់ភូមិសាស្ត្រទាំងនោះ

គ. បង្កើតព័ត៌មាន និងសកម្មភាពផ្សព្វផ្សាយនានាអំពីតម្លៃបន្ថែម ដែលផ្សារភ្ជាប់នឹងផលិតផលទៅកាន់អ្នកប្រើប្រាស់

ឃ. បង្កើតសកម្មភាពពាក់ព័ន្ធនឹងការធានាថា ផលិតផលនោះអនុលោមតាមសៀវភៅបន្ទុក

ង. ចាត់វិធានការកែលំអ ការអនុវត្តផែនការ រួមទាំងជំនាញអភិវឌ្ឍផ្នែកសេដ្ឋកិច្ច ការវិភាគផ្នែកសេដ្ឋកិច្ច ការផ្សព្វផ្សាយព័ត៌មានស្តីពីផែនការសេដ្ឋកិច្ច និងផ្តល់ការណែនាំដល់ផលិតករ

ច. ចាត់វិធានការលើកកម្ពស់តម្លៃផលិតផល ហើយក្នុងករណីចាំបាច់ ចាត់វិធានការទប់ស្កាត់ ឬប្រឆាំងនឹងវិធានការណាមួយ ដែលធ្វើឲ្យប៉ះពាល់ ឬបង្កហានិភ័យដល់រូបភាពផលិតផលទាំងនោះ ។

២. សមាគមសម្គាល់ភូមិសាស្ត្រ ត្រូវជូនដំណឹងអំពីព័ត៌មានណាមួយ ដែលពាក់ព័ន្ធទៅនឹងការបំពេញភារកិច្ចរបស់ខ្លួន តាមការតម្រូវរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

៣. សមាគមសម្គាល់ភូមិសាស្ត្រអាចបង្កើតវិធាន ស្តីពីការអនុវត្តល្អៗតាមបទប្បញ្ញត្តិកំណត់ ដើម្បីថែរក្សាចរិតលក្ខណៈបរិស្ថានជាក់ស្តែងនៃដី ឬបទប្បញ្ញត្តិជាក់លាក់ស្តីពីសុខុមាលភាពសត្វ ។

**ប្រការ៨.- ការស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ**

១. អនុលោមតាមមាត្រា៨ នៃច្បាប់ អ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

២. ពាក្យស្នើសុំចុះបញ្ជីត្រូវធ្វើជាភាសាខ្មែរ ឬភាសាអង់គ្លេស ។ ឯកសារតម្រូវសម្រាប់ការស្នើសុំចុះបញ្ជី ប្រសិនបើមិនបានធ្វើឡើងជាភាសាខ្មែរឬភាសាអង់គ្លេស ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាខ្មែរ ឬភាសាអង់គ្លេស ។

៣. ការស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រត្រូវមាន៖

ក. ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ

ខ. ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ

គ. ឈ្មោះម៉ាកសម្គាល់ភូមិសាស្ត្រ

ឃ. គំរូប្រភេទទំនិញដែលគ្របដណ្តប់ដោយពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ

ង. សៀវភៅបន្ទុកដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ

ច. សេចក្តីសង្ខេបនៃសៀវភៅបន្ទុក

ឆ. វិក័យបត្របង់កម្រៃសេវា

ជ. ឯកសារពាក់ព័ន្ធផ្សេងៗទៀតទាក់ទងទៅនឹងការស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ។

៤. ចំពោះការស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្របរទេសដូចមានចែងក្នុងជំពូកទី៥នៃច្បាប់ ត្រូវភ្ជាប់បន្ថែមមកជាមួយនូវភស្តុតាងបញ្ជាក់ថា ឈ្មោះផលិតផលនោះត្រូវបានការពារក្នុងប្រទេសដើម ។

**ប្រការ៩.- ចំណុចសំខាន់ៗនៃពាក្យស្នើសុំពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ**

